# ១- ផ្លូវកណ្តាល

លក្ខណៈម្យ៉ាងរបស់ព្រះពុទ្ធសាសនាគឺផ្លូវកណ្តាល ។

មនុស្សយើងច្រើនតែលម្អៀងទៅរកម្ខាងៗ ម្យ៉ាងលម្អៀងតាមបែបបដិបត្តិ និងម្យ៉ាងទៀត លម្អៀងតាមការយល់ឃើញ ។

**លម្អៀងតាមបែបបដិបត្តិ** គឺម្ខាងប្រឹងប្រែងស្វែងរកកាមសុខ ឱ្យសេចក្តីសំខាន់ក្នុងការសេពសោយកាមគុណ បម្រុងបម្រើរាងកាយ ហៅថា កាមសុខល្លិកានុយោគ ។ នេះមកអំពីមិនបានកំណត់ដឹងនូវការសេពសោយនោះ ដែលគ្រាន់តែជាតួវេទនាប៉ុណ្ណោះ សុខកាយសប្បាយចិត្ត អត់មានជាសត្វបុគ្គលណាអ្នកសោយឡើយ ពោលគឺសុខធាតុ សោមនស្សធាតុសុទ្ធៗ ។ ការដែលមិនបានកំណត់ដឹងនូវធម៌សោយអារម្មណ៍តាមពិត ធ្វើឱ្យមានការប្រព្រឹត្តស្វែងរកការសេពសោយ សម្គាល់ថាខ្លួនមានសេចក្តីសុខក្នុងកាម រហូតដល់ប្រព្រឹត្តបញ្ចវេរានិងឈ្លោះប្រកែកទាស់-ទែងគ្នាជាដើម ។ ក្នុងផ្នែកបដិបត្តិម្ខាងទៀត គឺលម្អៀងទៅរកការធ្វើរូបកាយឱ្យទុក្ខលំបាក ហៅថា អត្តកិលមថានុយោគ ។ ផ្នែកនេះ មានការរង្កៀសចំពោះសេចក្តីសុខក្នុងកាមគុណ បានលះបង់



ការសេពសោយវត្ថុកាមទាំងឡាយ ហើយប្រព្រឹត្តទុក្ករកិរិយា មានការប្រកាន់ថាធ្វើដូច្នេះនឹងបានដល់នូវសេចក្តីសម្រេច ចូលទៅរកភាពបរិសុទ្ធណាមួយ ។

ព្រះពុទ្ធសាសនាបានប្រកាសថា ការលម្អៀងទៅរកកាម គិតតែទំនុកបម្រុងរាងកាយ សប្បាយរីករាយជាមួយនឹងរបស់ក្នុងលោក ត្រេកអរនឹងរស់នៅក្នុងដែនរបស់មច្ចុរាជ ដូច្នេះមិនអាចរួចផុតចាកទុក្ខបានឡើយ ។ ឯការទៅធ្វើឱ្យខ្លួនទុក្ខលំបាកផ្នែករូបកាយដោយវិធីផ្សេងៗ ដោយគិតថាជាការលះបង់កិលេសកាមក៏មិនអាចរួចផុតចាកទុក្ខបានដែរ ។ ព្រះពុទ្ធសាសនាបានប្រកាសធម៌បដិបត្តិដែលហៅថា មជ្ឈិមប្បដិបទា គឺជាផ្លូវកណ្តាលនៃផ្លូវអមខាងទាំងពីរ ។ មជ្ឈិមប្បដិបទាមានសតិប្បដ្ឋាន ៤ ជាបុព្វភាគប្រព្រឹត្តទៅដើម្បីរួចផុតចាកទុក្ខទាំងពួង ។

ក្នុងបិដកលេខ ២៩ ,ទំព័រ ២០ សមិទ្ធិសូត្រ មានសម្តែងអំពីទេវតាមួយអង្គចូលគាល់ព្រះដ៏មានព្រះភាគនៅតបោទារាមជិតក្រុងរាជគ្រឹះ ។ ទេវតាអង្គនោះ បន្ទាប់ពីបានស្តាប់ព្រះធម៌សម្រេចនូវសោតាបត្តិផលហើយ បានពោលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដោយសេចក្តីសង្ខេបនេះ ខ្ញុំព្រះអង្គបានយល់សេចក្តីដោយពិស្តារយ៉ាងនេះថា

**បាបំ ន កយិរា វចសា មនសា**
**កាយេន វា កិញ្ចនំ សព្វលោកេ**
**កាមេ បហាយ សតិមា សម្បជានោ**
**ទុក្ខំ ន សេវេថ អនត្ថសញ្ហិតន្តិ ។**

បុគ្គលមិនគួរធ្វើនូវកង្វល់ដ៏លាមក ដោយវាចា ដោយចិត្ត ឬដោយកាយ ក្នុងលោកទាំងពួងឡើយ គួរមានសតិនិងសម្បជញ្ញៈ លះបង់នូវកាមទាំងឡាយ ហើយក៏មិនគួរគប្បីសេពនូវទុក្ខដែលមិនប្រកបដោយប្រយោជន៍នោះដែរ ។

## អដ្ឋកថា

ក្នុងវេលាចប់ធម៌ទេសនារបស់ព្រះដ៏មានព្រះភាគ ទេវតាអង្គនោះ កំពុងឈរនៅក្នុងទីនោះឯង បញ្ជូនញាណទៅតាមក្រសែនៃព្រះធម៌ទេសនា បានឃើញនូវមគ្គប្រកបដោយអង្គ ៨ ប្រការ ដែលខ្លួនបានសម្រេចហើយ ព្រោះការតាំងមាំក្នុងសោតាបត្តិផល ទើបក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ។

បណ្តាបទទាំងនោះ បទថា **វចសា** បានដល់សម្មាវាចា ។ **មនោ** មិនមែនជាអង្គមគ្គ ព្រោះដូច្នោះ ចិត្តដែលសម្បយុត្តដោយមគ្គ ទើបបានដល់មនោសុចរិត ៣ ។



បទថា **កាយេន វា កិញ្ចនំ** បានដល់សម្មាកម្មន្តៈ ។ ចំណែកសម្មាអាជីវៈ លោកកាន់យកសម្មាវាចានិងសម្មាកម្មន្តៈរួមគ្នានោះឯង ។

បទថា **សតិមា** បានដល់សម្មាវាយាមៈ សម្មាសតិ និង សម្មាសមាធិ ។

បទថា **សម្បជានោ** បានដល់សម្មាទិដ្ឋិ និង សម្មាសង្កប្បៈ។ ការវៀរផ្លូវអមខាងទាំង ២ លោកកាន់យកដោយបទទាំង ២ គឺ **កាមេ បហាយ** និង **ទុក្ខំ ន សេវេថ** ដូច្នេះឯង ។

**លម្អៀងតាមការយល់ឃើញ** គឺម្ខាងយល់ថា អត្តាទៀងទាត់ មានសត្វបុគ្គលតួខ្លួនស្លុះអន្ទោលទៅកើតទៀត ការយល់នេះហៅថា សស្សតទិដ្ឋិ ។ ម្ខាងទៀតយល់ថា អត្តាដាច់សូន្យ សត្វស្លាប់ទៅអត់កើតទៀតទេ ការយល់នេះហៅថាឧច្ឆេទទិដ្ឋិ ។

ផ្លូវកណ្តាល គឺទៅតាមសម្មាទិដ្ឋិ ឃើញការកើតឡើងនៃសង្ខារលោកអាស្រ័យបច្ច័យ ឃើញការរលត់អស់ទៅនៃសង្ខារលោក ព្រោះអស់បច្ច័យ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់អំពីសម្មាទិដ្ឋិនេះនៅក្នុងកច្ចានគោត្តសូត្រ ។

# កច្ចានគោត្តសូត្រ

(បិដកលេខ ៣១ ,ទំព័រ ៣៥)

**សាវត្ថិយំ វិហរតិ អថខោ អាយស្មា កច្ចានគោត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។**

ទ្រង់គង់នៅទៀបក្រុងសាវត្ថី។ គ្រានោះ ព្រះកច្ចានគោត្ត ដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

**ឯកមន្តំ និសិន្នោ ខោ អាយស្មា កច្ចានគោត្តោ ភគវន្តំ ឯតទវោច សម្មាទិដ្ឋិ សម្មាទិដ្ឋីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សម្មាទិដ្ឋិ ហោតីតិ ។**

លុះព្រះកច្ចានគោត្តដ៏មានអាយុ គង់អង្គុយក្នុងទីដ៏សមគួរហើយ ក៏ទូលសួរព្រះដ៏មានព្រះភាគដូច្នោះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងត្រាស់ថា សម្មាទិដ្ឋិ សម្មាទិដ្ឋិដូច្នោះ បពិត្រព្រះអង្គដ៏ចម្រើន ចុះសម្មាទិដ្ឋិកើតមាន ដោយហេតុប៉ុន្មានយ៉ាង ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា :



**ទ្វយនិស្សិតោ ខោយំ កច្ចាន លោកោ យេភុយ្យេន អត្ថិតញ្ចេវ នត្ថិតញ្ច ។**

ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែអាស្រ័យនូវចំណែកពីរយ៉ាង គឺអត្ថិភាព (សស្សតទិដ្ឋិ)១ និងនត្ថិភាព (ឧច្ឆេទទិដ្ឋិ)១ ។

**លោកសមុទយំ ច ខោ កច្ចាន យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា លោកេ នត្ថិតា សា ន ហោតិ ។**

ម្នាលកច្ចានៈ នត្ថិភាព (ឧច្ឆេទទិដ្ឋិ) ក្នុងលោក រមែងមិនមានដល់បុគ្គលដែលឃើញនូវហេតុជាទីកើតនៃលោក ដោយប្រាជ្ញាដ៏ប្រពៃតាមពិតឡើយ ។

**លោកនិរោធំ ខោ កច្ចាន យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា លោកេ អត្ថិតា សា ន ហោតិ ។**

ម្នាលកច្ចានៈ អត្ថិភាព (សស្សតទិដ្ឋិ) ក្នុងលោក រមែងមិនមានដល់បុគ្គលដែលឃើញនូវទីរលត់នៃលោក ដោយប្រាជ្ញាដ៏ប្រពៃតាមពិតឡើយ ។

**ឧបាយុបាទានាភិនិវេសវិនិពន្ធោ ខ្វាយំ កច្ចាន លោកោ យេភុយ្យេន តញ្ចាយំ ឧបាយុបាទានំ ចេតសោ**

**អធិដ្ឋានំ អភិនិវេសានុសយំ ន ឧបេតិ ន ឧបាទិយតិ នាធិដ្ឋាតិ អត្តា មេតិ ។**

ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែជាប់ជំពាក់ដោយឧបាយ ឧបាទាន និងសេចក្តីប្រកាន់មាំ ចំណែកខាងអរិយសាវ័កនេះ រមែងមិនចូលទៅដល់ មិនប្រកៀកប្រកាន់ មិនអធិដ្ឋាន នូវឧបាយនិងឧបាទាន នូវការតាំងទុកនៃចិត្ត នូវសេចក្តីប្រកាន់មាំ និងអនុសយក្កិលេសនោះៗថា ខ្លួនរបស់អាត្មាអញដូច្នេះឡើយ ។

**ទុក្ខមេវ ឧប្បជ្ជមានំ ឧប្បជ្ជតិ ទុក្ខំ និរុជ្ឈមានំ និរុជ្ឈតីតិ ន កង្ខតិ ន វិចិកិច្ឆតិ ។**

ឧបាទានក្ខន្ធទុក្ខ កាលកើត ក៏កើតឡើង ឧបាទានក្ខន្ធទុក្ខ កាលរលត់ ក៏រលត់ទៅ ព្រោះហេតុនោះ ទើបអរិយសាវ័កមិនសង្ស័យ មិនងឿងឆ្ងល់ឡើយ ។

**អបរប្បច្ចយា ញាណមេវស្ស ឯត្ថ ហោតិ ។**

ញាណរបស់អរិយសាវ័កនោះ រមែងមានក្នុងឧបាទានក្ខន្ធទុក្ខនោះ ដោយមិនបាច់ជឿពាក្យបុគ្គលដទៃឡើយ ។

**ឯត្តាវតា ខោ កច្ចាន សម្មាទិដ្ឋិ ហោតិ ។**

ម្នាលកច្ចានៈ សម្មាទិដ្ឋិ កើតមានដោយហេតុប៉ុណ្ណោះឯង។





បទថា **សម្មាទិដ្ឋិ សម្មាទិដ្ឋិ** ដោយសេចក្តីថា ទេវតា និងមនុស្សដែលជាបណ្ឌិត ពោលអំពីការឃើញដោយប្រពៃណាៗ ព្រះកច្ចានៈ ទូលសួរដោយសង្ខេបៗ ចំពោះការឃើញដោយប្រពៃនោះៗ ទាំងអស់ចូលក្នុងបទទាំងពីរ ។

បទថា **ទ្វយនិស្សិតោ** គឺអាស្រ័យចំណែកទាំងពីរ ។ ព្រះអង្គ ទ្រង់សម្តែងដល់មហាជនដទៃក្រៅអំពីព្រះអរិយបុគ្គល ដោយបទថា **យេភុយ្យេន** នេះឯង ។

បទថា **អត្ថិតំ** គឺទៀង ។

បទថា **នត្ថិតញ្ញ** គឺដាច់សូន្យ ។

សង្ខារលោក ឈ្មោះថា **លោក** ការកើតឡើងនៃសង្ខារលោកនោះឯង ឈ្មោះថា **លោកសមុទយ** ។

បទថា **សម្មប្បញ្ញាយ បស្សតោ** ដោយសេចក្តីថា មគ្គប្បញ្ញា ព្រមទាំងវិបស្សនា ។ ឈ្មោះថា សម្មប្បញ្ញា ការដឹងដោយប្រពៃ គឺជាអ្នកពិចារណាឃើញដោយសម្មប្បញ្ញានោះ ។

បទថា **យា លោកេ នត្ថិតា** គឺកាលបុគ្គលពិចារណាឃើញដោយបញ្ញា ចំពោះធម៌ដែលកើតឡើងក្នុងសង្ខារលោក

ឧច្ឆេទទិដ្ឋិ ដែលយល់ថាមិនមាន ក៏រមែងមិនកើតឡើងឡើយ ។

បទថា **លោកនិរោធំ** បានដល់ការបែកធ្លាយនៃសង្ខារទាំងឡាយ ។

បទថា **យា លោកេ អត្ថិតា** គឺកាលបុគ្គលពិចារណាឃើញដោយបញ្ញា ចំពោះធម៌ដែលកំពុងបែកធ្លាយក្នុងសង្ខារ-លោក សស្សតទិដ្ឋិ ដែលយល់ថាមាន ក៏រមែងមិនកើតឡើងដែរ ។

ម្យ៉ាងទៀត បទថា **លោកសមុទយំ** បានដល់បច្ចយាការដោយអនុលោម។ បទថា **លោកនិរោធំ** បានដល់បច្ចយាការខាងបដិលោម ។ កាលបុគ្គលពិចារណាឃើញការមិនដាច់សូន្យ នៃធម៌ដែលអាស្រ័យបច្ច័យកើតឡើង ព្រោះការមិនដាច់សូន្យនៃបច្ច័យទាំងឡាយ ឧច្ឆេទទិដ្ឋិ ដែលនឹងគប្បីកើតឡើង រមែងមិនមាន ។ កាលបុគ្គលពិចារណាឃើញការរលត់នៃបច្ច័យ គឺពិចារណាឃើញការរលត់នៃធម៌ដែលអាស្រ័យបច្ច័យកើតឡើង ព្រោះការរលត់ទៅនៃបច្ច័យ សស្សតទិដ្ឋិ ដែលនឹងគប្បីកើតឡើង ក៏រមែងមិនមានដែរ ។ សេចក្តីនេះ មានដូចពោលមកដូច្នេះឯង ។

ការជាប់ជំពាក់ដោយឧបាយ ឧបាទាន និងអភិនិវេស ឈ្មោះថា **ឧបាយុបាទានាភិនិវេសវិនិពន្ធោ**។ ក្នុងបទទាំងអស់នោះ បទថា **ឧបាយ** បានដល់ឧបាយមាន ២ យ៉ាង គឺតណ្ហា-



ឧបាយ និងទិដ្ឋិឧបាយ។ សូម្បី **ឧបាទាន** ជាដើមក៏មានន័យដូចគ្នាដែរ ។ តណ្ហា និងទិដ្ឋិ ព្រះអង្គត្រាស់ហៅថា **ឧបាយ** ព្រោះចូលដល់ គឺចូលទៅដល់ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយអាការជាដើមថា យើង ថា របស់យើង ។ ម្យ៉ាងទៀត ព្រះអង្គត្រាស់ថា **ឧបាទាន** និង **អភិនិវេស** ព្រោះការប្រកាន់មាំនិងការចាប់តោងមាំ នូវធម៌ទាំងនោះ ។ ដោយលោកនេះ ត្រូវតណ្ហា និងទិដ្ឋិទាំងនោះ ចាប់ចងទុកដូច្នោះឯង ទើបទ្រង់ត្រាស់ថា **ឧបាយុ-បាទានាភិនិវេសវិនិពន្ធោ** ។

បទថា **តញ្ចាយំ** គឺព្រះអរិយសាវ័កនេះ ... ។

បទថា **ន ឧបេតិ** គឺមិនចូលដល់ ។

បទថា **ន ឧបាទិយតិ** គឺមិនប្រកាន់មាំ ។

បទថា **នាធិដ្ឋាតិ** គឺមិនតាំងទុកក្នុងចិត្តមាំ (ដោយឧបាយ និងឧបាទាន ដោយការតាំងមាំនៃចិត្ត ដោយអភិនិវេស និងដោយអនុស័យថាអ្វីជាតួខ្លួនរបស់យើងនោះឡើយ) ។

ដោយអកុសលចិត្ត រមែងតាំងនៅក្នុងតណ្ហានិងទិដ្ឋិ និងព្រោះតណ្ហាព្រមដោយទិដ្ឋិ ក៏តាំងមាំ ហើយដេកសំងំនៅក្នុងអកុសលចិត្តនោះ ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ត្រាស់ធម៌

ទាំងពីរប្រការនេះថា **ចេតសោ អធិដ្ឋានំ អភិនិវេសានុសយំ**។

បទថា **នុក្ខមេវ** គឺត្រឹមតែឧបាទានក្ខន្ធ ៥ ប៉ុណ្ណោះ ។

បទថា **ន កង្ខតិ** បានដល់ការមិនងឿងឆ្ងល់ថា ទុក្ខនោះឯង រមែងកើតឡើង ទុក្ខនោះឯង រមែងរលត់ ដូចម្ដេចហ្ន៎ ។ ដែលឈ្មោះថា សត្វដទៃ ( ក្រៅពីទុក្ខ ) ក្នុងលោកនេះ រមែងមិនមានឡើយ ។

បទថា **ន វិចិកិច្ឆតិ** គឺមិនមានការសង្ស័យក្នុងចិត្តកើតឡើង ។

បទថា **អបរប្បច្ចយា** គឺមិនមែនចេះតែជឿតាមពាក្យអ្នកដទៃនោះទេ នេះគឺជាការឃើញច្បាស់ចំពោះខ្លួនឯង ។

ដោយបទថា **ឯត្តាវតា ខោ កច្ចាន សម្មាទិដ្ឋិ ហោតិ** ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដល់សម្មាទិដ្ឋិដែលលាយគ្នា[១] ថា ការឃើញដោយប្រពៃមានត្រឹមតែប៉ុណ្ណោះឯង ព្រោះលះបង់បាននូវសត្តសញ្ញា ដោយអាការយ៉ាងនេះ ។

១.វិបស្សនាសម្មាទិដ្ឋិ និងមគ្គសម្មាទិដ្ឋិ ព្រះអង្គទ្រង់ត្រាស់សម្ដែងក្នុងព្រះសូត្រនេះ ។



# ឋានៈអរិយមគ្គក្នុងបិដក

**១. មគ្គក្នុងឋានៈជាមជ្ឈិមប្បដិបទា** ក្នុងបិដកលេខ ៦, ទំព័រ ២៨ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ អ្នកទាំងឡាយចូរប្រុងនូវសោតប្បសាទចុះ តថាគតនឹងប្រៀនប្រដៅព្រះនិព្វានដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្ដែងធម៌ ។ កុលបុត្រទាំងឡាយចេញចាកផ្ទះបួសក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយប្រតិបត្តិគួរតាមពាក្យប្រដៅរបស់តថាគត ពុំយូរឡើយ មុខជានឹងបានធ្វើឱ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ព្រះដ៏មានព្រះភាគបានញ៉ាំងបញ្ចវគ្គិយភិក្ខុឱ្យយល់ច្បាស់ ក្នុងពេលនោះឯង ។ លុះគ្រាជាខាងក្រោយ បញ្ចវគ្គិយភិក្ខុបានតាំងចិត្តស្ដាប់ព្រះដ៏មានព្រះភាគ ផ្ទៀងនូវសោតប្បសាទ ហើយផ្ចង់ចិត្តដើម្បីដឹងច្បាស់ ។

គ្រានោះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុ

មកហើយព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌អមខាងទាំងពីរប្រការនេះ គឺបព្វជិតមិនគួរសេពគប់ឡើយ ។(ធម៌អមខាងទាំងពីរប្រការនោះគឺ ) ការប្រកបរឿយៗ នូវសេចក្តីជាប់ជំពាក់ដោយកាមសុខក្នុងកាមទាំងឡាយណា ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍នេះ ១ ការប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឱ្យលំបាកតែងនាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ឡើយនេះ ១ ម្នាលភិក្ខុទាំងឡាយ មជ្ឈិមប្បដិបទា (គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល ) មិនប៉ះពាល់នឹងធម៌អមខាងទាំងពីរនោះ តថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ (គឺធ្វើឱ្យកើតសេចក្តីចេះដឹង ) ប្រព្រឹត្តទៅដើម្បីសេចក្តីរំងាប់នូវកិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ក៏មជ្ឈិមប្បដិបទានោះ ដូចម្តេច ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ប្រព្រឹត្តទៅដើម្បីសេចក្តីរំងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីនិព្វាន (មជ្ឈិមប្បដិបទានោះ ) គឺអរិយមគ្គប្រកបដោយអង្គ ៨ នេះឯង អរិយមគ្គប្រកបដោយអង្គ ៨



ប្រការ ដូចម្តេច អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនោះគឺ សេចក្តីឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ស្មារតីត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ មជ្ឈិមប្បដិបទានេះឯងដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ តែងប្រព្រឹត្តទៅដើម្បីសេចក្តីរំងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីនិព្វាន ។

**២. មគ្គក្នុងឋានៈជាផ្លូវនៃជីវិត ទាំងបព្វជិត ទាំងគ្រហស្ថ** ក្នុងបិដកលេខ ៣៧, ទំព័រ ៤១ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសរសើរតែបដិបទាត្រូវរបស់គ្រហស្ថក្តី របស់បព្វជិតក្តី ។ ម្នាលភិក្ខុទាំងឡាយ គ្រហស្ថក្តី បព្វជិតក្តី តែប្រតិបត្តិត្រូវហើយ រមែងញុំាងធម៌ដែលបណ្ឌិតគប្បីដឹង គឺអរិយមគ្គជាកុសលឱ្យសម្រេចទៅបាន ព្រោះហេតុនៃអធិករណ៍គឺសេចក្តីប្រតិបត្តិត្រូវ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាត្រូវ តើដូចម្តេច ។ អ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ល។ សម្មាសមាធិ ១។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាបដិបទាត្រូវ ។ ម្នាលភិក្ខុ

ទាំងឡាយ តថាគតសរសើរតែបដិបទាត្រូវ របស់គ្រហស្ថក្តី របស់បព្វជិតក្តី ។ ម្នាលភិក្ខុទាំងឡាយ គ្រហស្ថក្តី បព្វជិតក្តី តែប្រតិបត្តិត្រូវហើយ រមែងញ៉ាំងធម៌ដែលបណ្ឌិតគប្បីដឹង គឺ អរិយមគ្គជាកុសលឱ្យសម្រេចទៅបាន ព្រោះហេតុនៃអធិករណ៍ គឺសេចក្តីប្រតិបត្តិត្រូវ ។

ក្នុងបិដកលេខ ៣៧ , ទំព័រ ១០០ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដូចជាទន្លេគង្គា ជាធម្មជាតិហូរទៅកាន់សមុទ្រ ទេរទៅកាន់សមុទ្រ ជ្រាលទៅកាន់សមុទ្រ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចម្រើននូវអរិយមគ្គប្រកបដោយអង្គ ៨ កាលធ្វើនូវអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង រមែងបង្អោនទៅរកព្រះនិព្វាន សសៀរទៅរកព្រះនិព្វាន ជម្រាលទៅរកព្រះនិព្វាន ក៏ដូច្នោះឯង ។

ក្នុងបិដកលេខ ២៤ , ទំព័រ ៣៧ វច្ឆគោត្តបរិព្វាជកបានពោលនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ដូចទន្លេគង្គាតែងមានទំនាបទៅរកសមុទ្រ ជម្រាលទៅរកសមុទ្រ ទេរទៅរកសមុទ្រ ទល់នឹងសមុទ្រ ទើបឈប់នៅ យ៉ាងណាមិញ បរិស័ទរបស់ព្រះគោតមដ៏ចម្រើន ទាំងគ្រហស្ថទាំងបព្វជិត រមែងមានទំនាបទៅរកព្រះនិព្វាន ជម្រាលទៅរកព្រះនិព្វាន ទេរទៅរក



ព្រះនិព្វាន ដរាបទល់នឹងព្រះនិព្វានទើបឈប់ ក៏យ៉ាងនោះដែរ ។

**៣- មគ្គក្នុងឋានៈជាព្រហ្មចរិយធម៌ អាស្រ័យនឹងកល្យាណមិត្ត** ក្នុងបិដកលេខ ៣៧,ទំព័រ ៣ មានសេចក្តីដូចតទៅ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងសក្ករនិគមរបស់ពួកសក្យៈ ក្នុងដែនសក្កៈ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គុណជាតឯណា គឺការមានមិត្តល្អ ការមានសម្លាញ់ល្អ និងការមានភ្លើល្អ គុណជាតនេះ ចាត់ជាពាក់កណ្តាលនៃព្រហ្មចរិយធម៌ ។

ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ គុណជាតឯណា គឺការមានមិត្តល្អ ការមានសម្លាញ់ល្អ និង ការមានភ្លើល្អ គុណជាតនេះឯង ចាត់ជាព្រហ្មចរិយធម៌ទាំងមូល ។ ម្នាលអានន្ទ ព្រហ្មចរិយធម៌នេះឯងប្រាកដដល់ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានភ្លើល្អ និងចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ និងធ្វើ

ឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។

ម្នាលអានន្ទ ចុះភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានក្លើល្អ ចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីនឿយណាយ អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ចម្រើននូវសម្មាសង្កប្បៈ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ ។ល។ ចម្រើននូវសម្មាវាចា ។ល។ ចម្រើននូវសម្មាកម្មន្តៈ ។ល។ ចម្រើននូវសម្មាអាជីវៈ ។ល។ ចម្រើននូវសម្មាវាយាមៈ ។ល។ ចម្រើននូវសម្មាសតិ ។ល។ ចម្រើននូវសម្មាសមាធិ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីនឿយណាយ អាស្រ័យនូវសេចក្តីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ។ ម្នាលអានន្ទ ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានក្លើល្អ ចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ យ៉ាងនេះឯង ។

ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្តីនោះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការ



មានសម្លាញ់ល្អ និងការមានក្លើល្អ ។ ម្នាលអានន្ទ ព្រោះអាស្រ័យតថាគតដែលជាមិត្តល្អ បានជាពួកសត្វដែលមានជាតិជាធម្មតា រួចស្រឡះចាកជាតិទៅបាន ពួកសត្វដែលមានជរាជាធម្មតា រួចស្រឡះចាកជរាទៅបាន ពួកសត្វដែលមានមរណៈជាធម្មតា រួចស្រឡះចាកមរណៈទៅបាន ពួកសត្វដែលមានសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និង សេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា រួចស្រឡះចាកសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និង សេចក្តីចង្អៀតចង្អល់ចិត្តទៅបាន ។ ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្តីនោះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសម្លាញ់ល្អ និង ការមានក្លើល្អ ។

ក្នុងបិដកលេខ ៣៧ , ទំព័រ ៦៣ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណ នេះជាប្រធាន នេះជាបុព្វនិមិត្ត នៃព្រះអាទិត្យដែលរះឡើង ។ ម្នាលភិក្ខុទាំងឡាយ ការមានមិត្តល្អ នេះជាប្រធាន នេះជាបុព្វនិមិត្ត ប្រព្រឹត្តទៅដើម្បីញ៉ាំងអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យកើតឡើងដល់ភិក្ខុ ដោយប្រការយ៉ាងនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះជាទីសង្ឃឹមនៃភិក្ខុដែលមានមិត្តល្អ ភិក្ខុនោះនឹងចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ នឹងធ្វើអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង ។

**៤. មគ្គក្នុងឋានៈជាផ្លូវឱ្យដល់នូវការអស់កម្ម** ក្នុងបិដកលេខ ៣៥, ទំព័រ ៣០៦ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់ទីរលត់កម្ម តើដូចម្តេច គឺមគ្គដែលប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរនេះឯង។

**៥. មគ្គក្នុងឋានៈជាក្បូន** ក្នុងបិដកលេខ ២១,ទំព័រ ៤៥ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកដើរផ្លូវឆ្ងាយ បុរសនោះឃើញនូវអន្លង់ទឹកដ៏ធំ មានត្រើយខាងអាយប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យ មានត្រើយខាងនាយដ៏ក្សេម ប្រាសចាកភ័យ តែថាទូក ក្បូន ឬស្ពានសម្រាប់ឆ្លងពីត្រើយអាយ ទៅត្រើយនាយនៃបុរសនោះ មិនមានឡើយ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អន្លង់ទឹកដ៏ធំនេះ មានត្រើយខាងអាយប្រកបដោយសេចក្តីរង្កៀសនិងភ័យ មានត្រើយខាងនាយដ៏ក្សេម ប្រាសចាកភ័យ ទូក ក្បូនឬស្ពានសម្រាប់ឆ្លងពីត្រើយខាងអាយទៅត្រើយខាងនាយក៏គ្មាន បើដូច្នោះ មានតែអាត្មាអញប្រមូលស្មៅ កំណាត់ឈើ មែកឈើ និងចំបើង យកមកចងធ្វើជាក្បូន ហើយអាស្រ័យនូវក្បូននោះ ព្យាយាមដោយដៃនិងជើង ឆ្លងទៅកាន់ត្រើយខាងនាយដោយ



សួស្តីបាន ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បុរសនោះក៏ប្រមូលស្មៅ កំណាត់ឈើ មែកឈើ និងចំបើងមកចងជាក្បូន ហើយបានអាស្រ័យក្បូននោះ ព្យាយាមដោយដៃនិងជើង ឆ្លងទៅកាន់ត្រើយខាងនាយបានដោយសួស្តី កាលបុរសនោះឆ្លងទៅដល់ត្រើយខាងនាយហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ក្បូននេះមានឧបការៈច្រើនដល់អាត្មាអញ ៗ បានអាស្រ័យក្បូននេះហើយ ព្យាយាមដោយដៃនិងជើង ឆ្លងមកដល់ត្រើយដោយសួស្តីបាន បើដូច្នោះ មានតែអាត្មាអញលើកក្បូននេះទូលលើក្បាល ឬលីនឹងកដើរចេញទៅកាន់ទីគួរតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះធ្វើយ៉ាងនេះ បានឈ្មោះថាជាអ្នកធ្វើសេចក្តីសមគួរដល់ក្បូននោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះមិនមែនដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសនោះ ធ្វើដូចម្តេច ទើបបានឈ្មោះថាធ្វើសេចក្តីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះឆ្លងដល់ត្រើយនាយក្នុងទីឯនោះគួរតែត្រិះរិះយ៉ាងនេះថា ក្បូននេះមានឧបការៈច្រើនដល់អាត្មាអញ ៗ បានអាស្រ័យនូវក្បូននេះហើយ ព្យាយាមដោយដៃនិងជើង ឆ្លងមកដល់ត្រើយនាយបានដោយសួស្តី បើដូច្នោះមានតែអាត្មាអញលើកក្បូននេះដាក់លើ

គោក ឬពន្លិចក្នុងទឹក ហើយដើរចេញទៅកាន់ទីគួរតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះដែលធ្វើយ៉ាងនេះបាន ឈ្មោះថាជាអ្នកធ្វើសេចក្ដីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មានឧបមាដូចជាក្បូនដែលតថាគតសម្ដែងហើយ ដើម្បីឱ្យរលាស់ខ្លួនចេញ មិនមែនដើម្បីឱ្យនៅប្រកាន់ឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយដឹងច្បាស់នូវធម៌ មានឧបមាដូចក្បូនដែលតថាគតសម្ដែងហើយ គប្បីលះបង់ធម៌[១] ទាំងឡាយចេញ នឹងចាំបាច់ពោលទៅថ្វីដល់អកុសលធម៌ ។

ក្នុងបិដកលេខ ២២ ,ទំព័រ ១៦៣ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនជាប់ជំពាក់ មិនរីករាយ មិនកួចកាន់ មិនរាប់អាននូវទិដ្ឋិដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ (អដ្ឋកថា = វិបស្សនាសម្មាទិដ្ឋិដែលបរិសុទ្ធព្រោះឃើញតួសភាវធម៌ ដែលផូរផង់ព្រោះឃើញដល់បច្ច័យ ) ដោយអំណាចតណ្ហានិងទិដ្ឋិទេ ម្នាលភិក្ខុទាំងឡាយ តើអ្នកទាំងឡាយយល់ច្បាស់នូវធម៌ដែលមានឧបមាដូចជាក្បូន ដែលតថាគតសម្ដែងហើយដើម្បីនឹងរើខ្លួនចេញចាកអំពីឱឃៈទាំង ៤ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រកាន់ដែរឬទេ? ព្រះករុណា ព្រះអង្គ ។

១. អដ្ឋកថា ថា លះបង់ឆន្ទរាគៈចំពោះសមថៈនិងវិបស្សនា ។



**៦. មគ្គក្នុងឋានៈជាព្រហ្មចរិយធម៌ដើម្បីប្រយោជន៍សុខដល់ពពួកជនច្រើន** ក្នុងបិដកលេខ ៦ ,ទំព័រ ៦៦ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតរួចហើយអំពីអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្ដី[១] ទោះបីជារបស់មនុស្សក្ដី[២] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសោតក៏បានរួចហើយអំពីអន្ទាក់ទាំងអស់ដែរ ទោះបីជារបស់ទេវតាក្ដី ទោះបីជារបស់មនុស្សក្ដី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក ( គឺស្រុកនិគមនិងរាជធានី ហើយសម្ដែងធម៌ ) ដើម្បីជាប្រយោជន៍និងសេចក្ដីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ អ្នកទាំងឡាយកុំទៅពីរអង្គតាមផ្លូវមួយជាមួយគ្នាឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្ដែងធម៌ឱ្យពីរោះបទដើមបទកណ្ដាលនិងបទចុង អ្នកទាំងឡាយចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធប្រកបដោយអត្ថនិងព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយដែលមានធូលីគឺរាគា-ទិក្កិលេសតិចក្នុងភ្នែកក៏មាន សត្វទាំងនោះនឹងសាបសូន្យ (ចាក

១. កាមគុណទាំង ៥ ដ៏ជាទិព្វរបស់ទេវតា ។ ២. កាមគុណទាំង ៥ ជារបស់មនុស្ស។

មគ្គផល) ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយអ្នកបម្រុងត្រាស់-ដឹងធម៌គង់នឹងមាន ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគតក៏នឹងចូលទៅកាន់សេនានិគម ក្នុងឧរុវេលាប្រទេស ដើម្បីសម្តែងធម៌ដែរ ។

**៧- មគ្គក្នុងឋានៈជាព្រហ្មចរិយធម៌ដើម្បីអកុប្បាចេ-តោវិមុត្តិ** ក្នុងបិដកលេខ ២១ ,ទំព័រ ២៣៥ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងខាងចុងនៃមហាសារោបមសូត្រថា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះ មិនមែនមានលាភសក្ការៈនិងសេចក្តីសរសើរជាអានិសង្ស មិនមែនមានសីលសម្បទាជាអានិសង្ស មិនមែនមានសមាធិសម្បទាជាអានិសង្ស មិនមែនមានញាណទស្សនៈ (ទិព្វចក្ខុ ) ជាអានិសង្សតែប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ ចេតោវិមុត្តិគឺការរួចចាកកិលេសនៃចិត្ត បានដល់អរហត្តផលដែលជាធម្មជាតិមិនកម្រើកណា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈនេះ មានអរហត្តផលនោះជាប្រយោជន៍ មានអរហត្តផលនោះជាខ្លឹម មានអរហត្តផលនោះជាទីបំផុត ។

ក្នុងបិដកលេខ ៣៧ , ទំព័រ ៣៦ ព្រះអានន្ទដ៏មានអាយុ បានតបបញ្ហាបីសំណួរ គឺសួរអំពីព្រហ្មចរិយៈ ១ ព្រហ្មចារី ១ ព្រហ្មចរិយបរិយោសាន ១ ។ ម្នាលអាវុសោ មគ្គដ៏ប្រសើរប្រកប



ដោយអង្គ ៨ នេះឯង ហៅថាព្រហ្មចរិយៈ ។ ម្នាលអាវុសោ បុគ្គលឯណាប្រកបដោយមគ្គដ៏ប្រសើរមានអង្គ ៨ នេះ បុគ្គលនោះ ហៅថាព្រហ្មចារី ។ ម្នាលអាវុសោ ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈឯណា នេះហៅថាទីបំផុតរបស់ព្រហ្មចរិយៈ ( ព្រហ្មចរិយបរិយោសាន ) ។

**៨- មគ្គក្នុងឋានៈជាព្រហ្មយាននាំទៅរកជោគជ័យតែម្យ៉ាងប៉ុណ្ណោះ** ក្នុងបិដកលេខ ៣៧ ,ទំព័រ ១៣ ព្រះអង្គទ្រង់ត្រាស់ថា ព្រហ្មយាននេះ រកគុណជាតិដទៃក្រៃលែងជាងគ្មាន កើតព្រមក្នុងខ្លួននៃបុគ្គលណា បុគ្គលនោះជាអ្នកប្រាជ្ញ រមែងចេញចាកលោកបានដោយពិតប្រាកដ មានតែជ័យជម្នះម្យ៉ាងប៉ុណ្ណោះ។

**៩- មគ្គក្នុងឋានៈជាត្រៃសិក្ខា** ក្នុងបិដកលេខ ៤១, ទំព័រ ៣២១ សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័នជិតក្រុងវេសាលី ។ គ្រានោះ វជ្ជីបុត្តកភិក្ខុមួយរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុង

ទីសមគួរ ។ លុះវជ្ជីបុត្តកភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សិក្ខាបទ ១៥០ ដែលសម្រេចហើយនេះមកកាន់ឧទ្ទេសរាល់កន្លះខែ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចនឹងសិក្សា ក្នុងសិក្ខាបទទាំងនោះបានទេ ។ ម្នាលភិក្ខុ ចុះអ្នកអាចសិក្សាក្នុងសិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ បានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអាចនឹងសិក្សា ក្នុងសិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុ បើដូច្នោះ ក្នុងសាសនានេះ អ្នកចូរសិក្សា ក្នុងសិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ចុះម្នាលភិក្ខុ កាលណាបើអ្នកនឹងសិក្សានូវអធិសីលផង សិក្សានូវអធិចិត្តផង សិក្សានូវអធិប្បញ្ញាផង កាលបើអ្នកកំពុងសិក្សានូវអធិសីលផង សិក្សានូវអធិចិត្តផង សិក្សានូវអធិប្បញ្ញាផង អ្នកគង់នឹងបានលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ (មិនខាន ) ព្រោះតែការលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ អ្នកនោះនឹងមិនធ្វើអំពើដែលជាអកុសល ទាំងមិនសេពនូវអំពើដែលលាមក ។ លុះសម័យតមក ភិក្ខុនោះក៏សិក្សាអធិសីលផង សិក្សានូវអធិចិត្តផង សិក្សានូវអធិប្បញ្ញាផង ។ កាលភិក្ខុនោះ



កំពុងសិក្សាអធិសីលផង សិក្សាអធិចិត្តផង សិក្សាអធិប្បញ្ញាផង ភិក្ខុនោះក៏បានលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ ភិក្ខុនោះមិនបានធ្វើអំពើដែលជាអកុសល ទាំងមិនបានសេពនូវអំពើដែលលាមកឡើយ ។

ក្នុងបិដកលេខ ២២ , ទំព័រ ២៩៣ ព្រះនាងធម្មទិន្នាភិក្ខុនី បានឆ្លើយតបបញ្ហាថា ម្នាលអាវុសោវិសាខ ខន្ធទាំង ៣ ប្រការ លោកមិនបានសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរទេ ម្នាលអាវុសោវិសាខ តែអដ្ឋង្គិកមគ្គដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ។ ម្នាលអាវុសោវិសាខ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ ធម៌ទាំងបីនេះលោកសង្គ្រោះចូលក្នុងសីលក្ខន្ធ ។ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ធម៌ទាំងបីនេះ លោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ ។ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ ធម៌ទាំងពីរនេះ លោកសង្គ្រោះចូលក្នុងបញ្ញាខន្ធ ។

**១០. មគ្គក្នុងឋានៈជាធម៌ឱ្យសម្រេចប្រយោជន៍ដ៏ក្រៃលែង** ក្នុងបិដកលេខ ៣៧, ទំព័រ ១៣ សាវត្ថីនិទាន ។ គ្រានោះ ពួកភិក្ខុច្រើនរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់

ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ពួកអន្យតិរ្ថិយបរិព្វាជកសួរខ្ញុំព្រះអង្គទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពួកលោកនៅប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះសមណគោតមដើម្បីប្រយោជន៍អ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គទាំងឡាយក៏ដោះស្រាយដល់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពួកយើងនៅប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះដ៏មានព្រះភាគដើម្បីកំណត់ដឹងនូវទុក្ខ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ កាលបើគេសួរយ៉ាងនេះហើយ ដោះស្រាយយ៉ាងនេះ ឈ្មោះថាពោលតាមពាក្យដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយផង មិនពោលបង្កាច់ព្រះដ៏មានព្រះភាគផង ដោះស្រាយនូវធម៌តាមសមគួរដល់ធម៌ផង ទាំងពាក្យពោលធំតូចនីមួយដែលប្រកបដោយធម៌ ក៏មិនដល់នូវហេតុដែលបណ្ឌិតគប្បីតិះដៀលផងទេឬ ។

ម្នាលភិក្ខុទាំងឡាយ អើ កាលបើគេសួរយ៉ាងនេះហើយ អ្នកទាំងឡាយដោះស្រាយយ៉ាងនេះ ឈ្មោះថាពោលតាមពាក្យ



ដែលតថាគតពោលហើយផង មិនឈ្មោះថាពោលបង្កាច់តថាគតដោយពាក្យមិនពិតផង ដោះស្រាយនូវធម៌តាមសមគួរដល់ធម៌ផង ទាំងពាក្យពោលធំតូចនីមួយដែលប្រកបដោយធម៌ ក៏មិនដល់នូវហេតុដែលបណ្ឌិតគប្បីតិះដៀលផងទេ ព្រោះអ្នកទាំងឡាយនៅប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់តថាគត ដើម្បីកំណត់ដឹងនូវទុក្ខពិត ។

ម្នាលភិក្ខុទាំងឡាយ បើពួកអន្យតិរ្ថិយបរិព្វាជកសួរអ្នកទាំងឡាយ ចុះមគ្គនិងបដិបទាប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខនោះមានដែរឬ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះ អ្នកទាំងឡាយគប្បីដោះស្រាយដល់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ មគ្គនិងបដិបទាប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខនោះមានដែរ ។

ម្នាលភិក្ខុទាំងឡាយ ចុះមគ្គដូចម្តេច បដិបទាដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខនោះ ។ គឺមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ហ្នឹងឯង ។ មគ្គទាំង ៨ តើដូចម្តេច ។ គឺសម្មាទិដ្ឋិ ១ ។ល។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាមគ្គ នេះជាបដិបទាដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះ

ហើយ អ្នកទាំងឡាយគប្បីដោះស្រាយដល់ពួកអន្យតិរ្ថិយបរិព្វាជក ទាំងនោះ យ៉ាងនេះចុះ ។

ក្នុងបិដកលេខ ៣៩, ទំព័រ ២៦២ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា តថាគតក្ដី អ្នកទាំងឡាយក្ដី ដែលអន្ទោលទៅក្នុងជាតិទាំងឡាយនោះៗ អស់កាលដ៏យូរអង្វែង ព្រោះមិនបានឃើញនូវអរិយសច្ចៈ ៤ តាមសេចក្ដីពិត ។ អរិយសច្ច ៤ នោះ តថាគតបានឃើញហើយ តណ្ហាដែលនាំសត្វឱ្យចូលទៅកាន់ភព តថាគតបានដកចោលហើយ ឫសគល់នៃសេចក្ដីទុក្ខ តថាគតបានរំលើងចោលហើយ ភពថ្មីទៀត ក្នុងកាលឥឡូវនេះ មិនមានឡើយ ។

ក្នុងបិដកលេខ ៤០, ទំព័រ ១៧ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកមានទឹកថ្លាស្អាតមិនកខ្វក់ បុរសអ្នកមានចក្ខុឈរនៅមាត់អន្លង់នោះ បានឃើញខ្យង គ្រំ ដុំក្រួស អំបែងព្រមទាំងបានឃើញហ្វូងត្រីហែលទៅមកជាដើម ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះទឹកនោះមិនល្អក់ ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តមិនល្អក់ រមែងបានស្គាល់នូវប្រយោជន៍របស់ខ្លួនផង បានស្គាល់នូវប្រយោជន៍របស់អ្នកដទៃផង បានស្គាល់នូវប្រយោជន៍ទាំងពីរខាងផង ព្រមទាំងធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរក្រៃ-



លែងជាងមនុស្សធម៌ផង ដូច្នោះឯង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុនោះមានចិត្តមិនល្អក់ ។

ក្នុងបិដកលេខ ៤១, ទំព័រ ២៨៥ ព្រះអានន្ទបានសម្ដែងថា បុគ្គលដែលត្រូវរាគៈ ទោសៈ មោហៈគ្របសង្កត់រួបរឹត រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនទាំងពីរខាងខ្លះ រមែងទទួលទុក្ខទោមនស្សប្រព្រឹត្តទៅក្នុងចិត្តខ្លះ ។ កាលលះបង់នូវរាគៈ ទោសៈ មោហៈបានហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួនឯង មិនគិតដើម្បីបៀត-បៀនអ្នកដទៃ មិនគិតដើម្បីបៀតបៀនទាំងពីរខាង រមែងមិនទទួលទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្តឡើយ ។

បុគ្គលដែលត្រូវរាគៈ ទោសៈ មោហៈគ្របសង្កត់រួបរឹត រមែងមិនដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនតាមពិតផង មិនដឹងច្បាស់នូវប្រយោជន៍របស់បុគ្គលដទៃតាមពិតផង មិនដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាងតាមពិតផង ។ កាលលះបង់នូវរាគៈ ទោសៈ មោហៈបានហើយ បុគ្គលរមែងដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនតាមពិតផង ដឹងច្បាស់នូវប្រយោជន៍របស់បុគ្គលដទៃតាមពិតផង ដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាងតាមពិតផង ។

រាគៈ ទោសៈ មោហៈ ជាគ្រឿងធ្វើឱ្យងងឹតដូចខ្វាក់ ធ្វើឱ្យ

មិនមានញាណ ធ្វើឱ្យរលត់បញ្ញា ជាប៉ែកខាងសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានឡើយ ។ អរិយមគ្គប្រកបដោយ អង្គ ៨ ប្រការ ជាផ្លូវប្រតិបត្តិដើម្បីលះរាគៈ ទោសៈ មោហៈនោះឯង ។

ក្នុងបិដកលេខ ២១, ទំព័រ ៩៦ ព្រះបុណ្ណមន្តាណីបុត្តបាន សម្តែងថា ញាណទស្សនវិសុទ្ធិ (គឺមគ្គញ្ញាណ ) មានប្រយោជន៍ ត្រឹមតែអនុបាទាបរិនិព្វាន ។ ព្រហ្មចរិយធម៌ដែលខ្ញុំព្រះករុណា ប្រព្រឹត្តក្នុងសម្នាក់ព្រះដ៏មានព្រះភាគនេះ ដើម្បីអនុបាទាបរិនិព្វាន តែម៉្យាងប៉ុណ្ណោះ ។

## **បទគួរយល់ដឹង**

- រថយន្តជីវិតមានចិត្តជាអ្នកបើកបរ ត្រូវចេះច្បាប់ចរាចរ ហើយអនុវត្តតាម មិនស្រវឹង មិនងោកងក់ ទាំងដែលស្គាល់ផ្លូវច្បាស់ កំណត់ទិសដៅពិតប្រាកដ ។ ចិត្តសំខាន់ណាស់ ក្នុងការនាំរថយន្តជីវិតឱ្យបានដល់ទិសដៅដោយសុវត្ថិភាព ដូច្នេះ ទើបត្រូវតែសិក្សាហ្វឹកហាត់អប់រំចិត្ត មានព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ។

ការសិក្សាព្រះធម៌ដោយសទ្ធា គឺដូចជារៀនច្បាប់បើកបររថយន្ត ។ ភ្លើងក្រហម ភ្លើងបៃតង ភ្លើងទឹកក្រូច ផ្លាកសញ្ញា



គំនូសផ្លូវ កម្រិតល្បឿន ។ល។ អ្នកបើកបររថយន្តត្រូវចេះចាំនិងអនុវត្ត យ៉ាងណា អ្នកបើកបររថយន្តជីវិតនេះ ត្រូវសិក្សាព្រះពុទ្ធោវាទហើយបដិបត្តិតាម យ៉ាងនោះឯង ។ ភ្លើងក្រហមប្រាប់ថាឈប់ ដូចព្រះអង្គត្រាស់ថា បាបទាំងពួងជាអករណីយកិច្ច ភ្លើងបៃតងប្រាប់ថាទៅ ដូចព្រះអង្គត្រាស់ថា ម្នាលនាងសុមនា ហេតុនោះយ៉ាងនេះហើយ ម្នាលនាងសុមនា បុគ្គលគួរឱ្យទានទាំងឡាយ គួរធ្វើបុណ្យទាំងឡាយ ព្រោះបុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលកើតជាទេវតាផង បុណ្យទាំងឡាយជាឧបការៈដល់អ្នកដែលកើតជាមនុស្សផង បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកបួសផង[១] ។

ភ្លើងពណ៌ទឹកក្រូចប្រាប់ថាត្រូវប្រយ័ត្ន ដូចព្រះអង្គត្រាស់ក្នុងអប្បមាទធម៌ទាំងពួង ដូច្នោះដែរ ។ នៅពេលជាក់ព្រះជន្មាយុ-សង្ខាររួចហើយ ព្រះអង្គទ្រង់ប្រទានឱវាទនៅកូដាគារសាលា នាមហាវ័នជិតក្រុងវេសាលីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានសេចក្តីត្រិះរិះតម្កល់ស្មើល្អ ចូរតាមថែរក្សាចិត្តរបស់ខ្លួនឱ្យបានរឿយៗចុះ ។ ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ ភិក្ខុនោះ នឹងលះបង់

១. បិដកលេខ ៤៤, ទំព័រ ៦៦ ។

នូវជាតិសង្សារ ហើយធ្វើនូវព្រះនិព្វានជាទីបំផុតនៃកងទុក្ខបានមិនខានឡើយ[១] ។

ផ្លាកសញ្ញាចរាចរ ដូចសិក្ខាបទទាំងឡាយដែលព្រះអង្គទ្រង់បញ្ញត្ត ទ្រង់អនុញ្ញាត ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ផ្សេងៗ ។ ក្នុងវិនយបិដកលេខ ១,ទំព័រ ៦៥ ព្រះអង្គទ្រង់ត្រាស់ថា តថាគតបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីសេចក្ដីល្អដល់សង្ឃ ១ ដើម្បីនៅសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលមិនអៀនខ្មាស ១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរារាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញុាំងបុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាឱ្យជ្រះថ្លាឡើង ១ ដើម្បីញុាំងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាច្រើនឡើង ១ ដើម្បីឱ្យតម្កល់នៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ១ ។

ខ្សែគំនូសផ្លូវនៅស្រុកខ្មែរ ឱ្យអ្នកបើកបររថយន្តប្រកាន់ស្ដាំ ហើយពេលណាជែងគេទៅមុនបាន ឬពេលណាមិនបាន ត្រូវបើក

១. បិដកលេខ ១៦, ទំព័រ ២៥៧ ។



ផ្លូវទី ១ ឬផ្លូវទី ២ ជាដើម ។ ក្នុងផ្លូវនៃជីវិតមនុស្សយើងត្រូវប្រកាន់ស្ដាំ សម្ដែងសេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព ហើយមិនគប្បីប្រជែងគ្នាដោយខ្វះនូវសេចក្ដីគោរពនេះឡើយ ។ ក្នុងបិដកលេខ ៣០ ,ទំព័រ ៣១ ក្នុងគារវសូត្រ សម័យមួយព្រះដ៏-មានព្រះភាគ ទើបនឹងបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមអជបាលនិគ្រោធ ប្របច្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងទីស្ងាត់ ទ្រង់សំងំនៅ ហើយទ្រង់មានព្រះបរិវិតក្កក្នុងព្រះហឫទ័យកើតឡើងយ៉ាងនេះថា បុគ្គលមិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង រមែងនៅជាទុក្ខ ។ អាត្មាអញគួរធ្វើសក្ការៈ ធ្វើសេចក្ដីគោរព អាស្រ័យនៅនឹងសមណៈឬព្រាហ្មណ៍ណាហ្ន៎ ។ លំដាប់នោះ ព្រះដ៏មាន-ព្រះភាគទ្រង់មានព្រះតម្រិះយ៉ាងនេះថា អាត្មាអញគួរធ្វើសក្ការៈ ធ្វើសេចក្ដីគោរព អាស្រ័យនៅនឹងសមណៈឬព្រាហ្មណ៍ដទៃ ដើម្បីបំពេញនូវសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ និងវិមុត្តិញ្ញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញលេញ តែថាក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងសម្មតិទេពនិងមនុស្សដ៏សេស អាត្មាអញមិនឃើញសមណៈ ឬព្រាហ្មណ៍ដទៃដែលបរិបូណ៌ដោយសីល

ជាដើម ជាងអាត្មាអញ ដែលអាត្មាអញគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅឡើយ ។ បើដូច្នោះគួរអាត្មាអញធ្វើសក្ការៈ ធ្វើសេចក្តីគោរព ចំពោះធម៌ (ព្រះធម្មរតនៈ ) ដែលអាត្មាអញបានត្រាស់ដឹងហើយអាស្រ័យនៅ ។ នៅខាងចុងនៃគារវសូត្រនេះ សហម្បតិព្រហ្មបានពោលថា ព្រះសម្ពុទ្ធទាំងឡាយក្នុងអតីត អនាគត និង បច្ចុប្បន្ន ទ្រង់ធ្វើសេចក្តីសោកនៃជនទាំងឡាយដ៏ច្រើនឱ្យវិនាស សុទ្ធតែគោរពចំពោះព្រះសទ្ធម្ម ។ ព្រោះហេតុដែលព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គទ្រង់គោរពក្នុងព្រះសទ្ធម្ម ដូច្នោះ បុគ្គលអ្នកស្រឡាញ់ខ្លួន ប្រាថ្នានូវភាពនៃខ្លួនជាធំ កាលរលឹកឃើញនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គួរធ្វើនូវសេចក្តីគោរពចំពោះព្រះសទ្ធម្ម ( **សទ្ធម្មោ គរុកាតព្វោ** )។ ក្នុងបិដកលេខ ៣០, ទំព័រ ១៣២ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ចំពោះមានត្ថទ្ធព្រាហ្មណ៍ដូច្នេះថា បុគ្គលមិនគួរធ្វើមានះចំពោះមាតាបិតា បង និងអាចារ្យជាគម្រប់ ៤ ឡើយ គួរប្រកបដោយសេចក្តីគោរពចំពោះបុគ្គលទាំង ៤ នោះ គួរលំអុតលំឱនចំពោះបុគ្គលទាំង ៤ នោះ ព្រោះថា បុគ្គលទាំង ៤ ដែលគេគោរពបូជាដោយល្អហើយនោះ រមែងញុំាងប្រយោជន៍ឱ្យសម្រេច ។ បុគ្គលគួរកម្ចាត់មានះ មិនគួររឹងត្អឹងដោយអនុស័យ គឺមានះនោះ



ចំពោះព្រះអរហន្តដែលមានសេចក្តីត្រជាក់ មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ជាអ្នកប្រសើរនោះឡើយ ។

ស្រវឹងស្រាហើយបើកបររថយន្ត វាបណ្តាលឱ្យមានគ្រោះ-ថ្នាក់ យ៉ាងណា រថយន្តជីវិតនេះ ក៏មានគ្រោះថ្នាក់ដែរ កាលបើចិត្តមានសេចក្តីស្រវឹង ។ ក្នុងបិដកលេខ ៨២, ទំព័រ ១៤៣ ព្រះអង្គទ្រង់សម្តែងអំពីសេចក្តីស្រវឹង ២៧ មុខ គឺស្រវឹងព្រោះជាតិ ១, ព្រោះត្រកូល ១, ព្រោះការមិនមានរោគ ១ , ព្រោះវ័យ ១, ព្រោះជីវិត ១, ព្រោះលាភ ១, ព្រោះសក្ការៈ ១ , ព្រោះការគោរព ១ , ព្រោះជាប្រធាន ១ , ព្រោះបរិវារ ១ , ព្រោះភោគ ១ , ព្រោះវណ្ណៈ ១ , ព្រោះសុតៈ ១ , ព្រោះបដិភាណ ១ , ព្រោះរត្តញ្ញូ (បួសមុនគេ ) ១ , ព្រោះប្រព្រឹត្តបិណ្ឌបាត ១ , ព្រោះហេតុដែលមាក់ងាយមិនបាន ១ , ព្រោះឥរិយាបថ ១ , ព្រោះឫទ្ធិ ១ , ព្រោះយស ១, ព្រោះសីល ១, ព្រោះឈាន ១ , ព្រោះសិល្បសាស្ត្រ ១, ព្រោះកម្ពស់ ១, ព្រោះមាឌ ១ , ព្រោះទ្រង់ទ្រាយសណ្ឋាន ១, ព្រោះសរីរៈពេញលេញ ១ ។ សេចក្តីស្រវឹងគឺជាដំណើរក្នុងភពនៃមច្ចុរាជ ព្រោះត្រូវការ ស្វែងរក ធ្វើកម្មដើម្បីឱ្យបាន ... គឺជាដំណើរលិចលង់ ។ ក្នុងបិដកលេខ ៥២ ,ទំព័រ ៣៧ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា បដិបទាអាស្រ័យនូវលាភផ្សេង បដិបទា

ជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះសម្មា-
សម្ពុទ្ធដឹងច្បាស់នូវហេតុនោះយ៉ាងនេះហើយ មិនគួរត្រេកអរ
ចំពោះសក្ការៈឡើយ គប្បីញ៉ាំងនូវវិវេកឱ្យចម្រើនដោយលំដាប់ ។

អ្នកបើកបរវថយន្ត កាលបើងោកងក់ទាំងដែលកំពុងបើក
បរ ក៏ត្រូវគ្រោះថ្នាក់ភ្លាមមួយរំពេចដែរ ត្រូវបុកអ្វីមួយឬត្រូវចូល
ជ្រោះជាដើម យ៉ាងណា ចំពោះអ្នកបើកបរវថយន្តជីវិតនេះក៏
យ៉ាងនោះដែរ ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់ក្នុងបិដកលេខ ៥២ ,
ទំព័រ ២២ ថា បុគ្គលដែលឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុង
ឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូសមាន
ព្យាយាមធូរថយ កិលេសមាររមែងគ្របសង្កត់នូវបុគ្គលនោះ ដូច
ខ្យល់បោកបក់គ្របសង្កត់នូវដើមឈើទុព្វល ដូច្នោះឯង ។ ក្នុង
បិដកលេខ ៥៤, ទំព័រ ៣១៤ ព្រះអង្គទ្រង់ត្រាស់ថា នរជនមានចិត្ត
ឱនទៅរកព្រះនិព្វាន គប្បីគ្របសង្កត់នូវការដេកលក់ សេចក្ដីខ្ជិល
ច្រអូស ការរួញរា មិនគប្បីដំអក់នៅដោយការធ្វេសប្រហែស
និងមិនគប្បីតម្កល់ខ្លួនក្នុងមានះដ៏ក្រៃលែង គឺការមើលងាយអ្នក
ដទៃឡើយ ។

អ្នកបើកបរវថយន្តត្រូវស្គាល់ផ្លូវទៅរកទិសដៅ យ៉ាងណា
អ្នកបើកបរវថយន្តជីវិតក៏យ៉ាងនោះដែរ ត្រូវដឹងថាផ្លូវគឺសតិប្បដ្ឋាន



៤ ជាផ្លូវទៅកាន់ទីដែលអស់កង្វល់គ្រប់យ៉ាង ។

- ចិត្ត ចេតសិក រូប បរមត្ថធម៌ទាំង ៣ នេះជាសង្ខារធម៌
ចំណែកព្រះនិព្វានជាវិសង្ខារធម៌ ។ ចិត្តកើតហើយរលត់អត់ទៅ
និព្វានទេ ចេតសិកនិងរូបក៏ដូចគ្នា សុទ្ធតែកើតហើយរលត់ទៅវិញ
អត់មានទៅតាំងនៅក្នុងទីណាឡើយ ហើយក៏អត់មានអ្នកណា
ផ្សេងក្រៅអំពីចិត្តចេតសិករូបទៀតទៅនិព្វានដែរ ដូច្នេះជំនួសការ
ខ្វល់នឹងឱ្យខ្លួនយើងទៅព្រះនិព្វាន គឺសតិរលឹកដឹងនូវរូបធម៌ នាម-
ធម៌ តាមសេចក្ដីពិត នេះទើបជាផ្លូវទៅព្រះនិព្វានពិតៗ ព្រោះ
រលត់អស់នូវសេចក្ដីសម្គាល់ថាតួខ្លួនយើងនៅក្នុងលោកនេះ ។ មិន
មែនបង្ខំឬបង្គាប់ឱ្យខ្លួនឯងចម្រើនសតិនោះទេ តែព្រោះជីវិតជា
ប្រក្រតីជាតួធម៌សុទ្ធៗ ជាទីតាំងនៃសតិរលឹក ដូចបុគ្គលមានភ្នែក
កាលដែលបើកភ្នែកឡើងក៏ឃើញរូបតាមធម្មតាៗ ដូច្នោះឯង ។

- ព្រោះការស្ដាប់យល់នូវតួធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់
ត្រាស់សម្ដែង ទើបបានជាបច្ច័យឱ្យសតិរលឹកសិក្សានូវការពិតជា
ប្រក្រតី ដូចភ្នែកជាបច្ច័យនៃការឃើញរូបារម្មណ៍ ដោយឥតបង្ខំ
ឱ្យឃើញនោះឡើយ ដូច្នោះដែរ ។

- ព្រះអង្គទ្រង់ត្រាស់ថា សង្សារវដ្ដវែងឆ្ងាយ សម្រាប់
បុគ្គលល្ងង់ខ្លៅទាំងឡាយដែលមិនដឹងនូវព្រះសទ្ធម្ម[១] ។ ជាទូទៅ

១. បិដកលេខ ៥២, ទំព័រ ៣៤ ធម្មបទ ពាលវគ្គ ។

អ្នកដែលបានស្ដាប់ព្រះធម៌យល់ តែងតែពោលសរសើរព្រះធម៌ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចជាបុគ្គលផ្ងារនូវរបស់ដែលផ្កាប់ ឬបើកបង្ហាញនូវរបស់ដែលកំបាំង ឬក៏ចង្អុលបង្ហាញផ្លូវដល់មនុស្សវង្វេង ពុំនោះសោត ដូចទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានចក្ខុនឹងឃើញរូបទាំងឡាយបាន ធម៌ដែលព្រះគោតម-ដ៏ចម្រើនប្រកាសហើយដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ ។ ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក[១] ។

---

[១] បិដកលេខ ៣០, ទំព័រ ៨៥ ជាដើម ។



# ២. ធម៌ទាំងឡាយកើតពីហេតុ

កាលអំពីព្រះសម្មាសម្ពុទ្ធមិនទាន់បានសម្ដែងព្រះធម៌ ពាក្យថា « ធម៌ទាំងឡាយកើតពីហេតុ » មិនមានក្នុងលោកឡើយ ព្រោះមិនមានអ្នកណាម្នាក់បានត្រាស់ដឹងនូវធម៌តាមពិត ។ កាលដែលមិនបានដឹងថាធម៌ទាំងឡាយកើតពីហេតុ ទើបមានការយល់ខុសផ្សេងៗ ដែលការយល់ខុសទាំងនោះ សុទ្ធតែអាស្រ័យនឹងសេចក្ដីប្រកាន់ថា មានអត្តាតួខ្លួន មានសត្វ មានបុគ្គល ។

ព្រះសារីបុត្តបានស្ដាប់នូវពាក្យនេះឯង ហើយក៏បានអស់នូវការយល់ខុសគ្រប់យ៉ាង គឺព្រះអស្សជិត្ថេរបានសម្ដែងប្រាប់ថា ធម៌ទាំងឡាយណាកើតពីហេតុ ព្រះតថាគតទ្រង់ត្រាស់សម្ដែងនូវហេតុនោះ ។ ពាក្យថា ធម៌ទាំងឡាយណាកើតពីហេតុ គឺបានដល់សង្ខារធម៌ទាំងអស់ដែលសង្គ្រោះចូលក្នុងទុក្ខសច្ច ។ ពាក្យថា ព្រះតថាគតទ្រង់ត្រាស់សម្ដែងនូវហេតុនោះ គឺសម្ដែងប្រាប់ថា តណ្ហាជាហេតុនៃទុក្ខសច្ច ។ ឯការរលត់អស់នូវសច្ចៈទាំងពីរនោះ គឺរលត់ទុក្ខសច្ចៈនិងសមុទយសច្ច ហៅថា និរោធសច្ច ជាអសង្ខតធាតុ ។ មិនមែនរលត់ឯងៗទេ គឺទាល់តែមានអរិយមគ្គ

អង្គ ៨ ជាហេតុ ទើបមាននិរោធសច្ចជាផល ។

សច្ចធម៌ក្នុងលោកមិនផ្គាប់ចិត្តអ្នកណាឡើយ មិនប្រព្រឹត្តទៅតាមការទាមទារ មិនស្តាប់បញ្ជា នេះជាលក្ខណៈនៃសច្ចធម៌ក្នុងលោក ជាអនត្តា ជាធម៌ប្រព្រឹត្តទៅតាមហេតុ ។ កាលដែលបុគ្គលបានសិក្សានូវសច្ចៈ លុះក្នុងសច្ចៈ ព្រមតាមសច្ចៈ លទ្ធផលគឺសុខចិត្ត ។

នៅក្នុងលោកនេះ មិនមានអ្វីណាមួយដែលមិនពិតឡើយ ក្នុងយើង ក្នុងអ្នកដទៃ ព្រមទាំងក្នុងអ្វីៗទៀតគ្រប់យ៉ាង ព្រោះថាអ្វីនោះៗសុទ្ធតែអាស្រ័យបច្ច័យកើតឡើង[១] ។ អ្វីដែលកើតគឺរមែងកើត អ្វីដែលមានគឺរមែងមាន ក្នុងមនុស្សគឺបែបនេះឯង ក្នុងសត្វទាំងឡាយ ធម្មជាតិទាំងឡាយសុទ្ធតែបែបហ្នឹង សុទ្ធតែជាធម៌ពិតទាំងអស់ បើមិនមានហេតុ មិនមានបច្ច័យ គឺមិនកើតឡើងឡើយ។

ក្នុងជីវិតនៃសត្វលោក មនុស្សលោក ទេវលោក ព្រហ្មលោក មិនមានសុខអ្វីឱ្យក្រៃលែងដូចជាសុខចិត្តនេះទេ ។ សុខចិត្តបានសេចក្តីថា ចិត្តមានសេចក្តីសុខ មិនទាក់ទិននឹងអ្វីៗក្នុងលោកនេះច្រើនឡើយ មិនចាំបាច់ទាល់តែមានសម្បត្តិច្រើន របស់ប្រណីតទៅនោះទេ តែចាំបាច់ចិត្តត្រូវមានសទ្ធា ព្រមទាំងគុណ-

១- ក្នុងអត្ថបទនេះ ហេតុនិងបច្ច័យ ប្រើជំនួសគ្នាបាន ។



ធម៌ផ្សេងទៀត ប្រព្រឹត្តទៅជាមួយនឹងការអប់រំចម្រើននូវញាណទស្សនៈ គឺពន្លឺភ្លឺស្វាងនៃចិត្តឃើញថា អ្វីដែលកើតរមែងកើត អ្វីដែលមានរមែងមាន អ្វីដែលបាត់រមែងបាត់ ។

បើមិនមានសទ្ធាទេ ចិត្តពិតជាមិនមានការអប់រំឡើយ ហើយក៏មិនមានសេចក្តីសុខដែរ ។ សទ្ធាបានរំដោះចិត្តចេញពីពួកពាលធម៌ បាបធម៌ ឱ្យចិត្តមកឋិតនៅជិតព្រះរតនត្រ័យ ហើយសិក្សាអប់រំក្នុងពុទ្ធធម៌ ដូចជាព្រះរដ្ឋបាលត្ថេរ ជាកុលបុត្រមានសទ្ធាចេញចាកផ្ទះចូលកាន់ផ្នួសបួសជាបព្វជិត ទីបំផុតក៏ជាព្រះអរហន្តមួយអង្គដែរ ។

ធម៌ទាំងឡាយកើតពីហេតុ មិនមែនគ្រាន់តែជាអ្វីដែលបុថុជ្ជនទាំងឡាយគិតឃើញនោះទេ ។ ធម៌ទាំងឡាយកើតពីហេតុជាសច្ចធម៌ដ៏មានជម្រៅ ជាធម៌សកល អត់មានអត្តា អត់មានសត្វបុគ្គល គ្រាន់តែជាផលនៃហេតុប៉ុណ្ណោះ ។ អភិសង្ខារគឺកម្មវដ្តៈ កើតពីអវិជ្ជាជាបច្ច័យ វិបាកវិញ្ញាណទាំងក្នុងបដិសន្ធិកាលទាំងក្នុងបវត្តិកាល កើតពីអភិសង្ខារជាបច្ច័យ ដូច្នេះជាដើមដែលបុថុជ្ជនគិតមិនឃើញ ទាល់តែអប់រំវិបស្សនាទើបបានឃើញបណ្តើរៗ រហូតដល់ពុទ្ធញ្ញាណទើបជ្រាបដឹងដោយសព្វគ្រប់ ។

ព្រោះមិនដឹងថាអភិសង្ខារគឺកម្មកើតពីអវិជ្ជា ទើបយល់ខុស

ថា ព្រះអាទិទេពជាអ្នកបង្កើតសត្វ ជាអ្នកសាងលោក ។ ព្រោះមិនដឹងថាវិញ្ញាណកើតមានព្រោះកម្មជាបច្ច័យ ទើបយល់ខុសថា វិញ្ញាណនេះស្ទុះអន្ទោលទៅកើតទៀត ។ ព្រោះមិនដឹងថានាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ ទើបត្រេកអរនឹងការបាននាមរូប ដែលនាមរូបនេះជាភារៈធ្ងន់ដ៏ក្រៃលែង ។ ព្រោះមិនដឹងពីការអស់ទៅនៃកម្មព្រោះអស់អវិជ្ជា ទើបមិនដឹងនូវទុក្ខនិរោធគឺការរលត់ទុក្ខតាមពិត ។ ក្នុងបិដកលេខ ២១, ទំព័រ ៦២ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើមក្តី ក្នុងកាលឥឡូវនេះក្តី តថាគតតែងបញ្ញត្តនូវទុក្ខផង នូវការរលត់ទុក្ខផង ។ ព្រះអដ្ឋកថាបញ្ជាក់ថា ព្រះតថាគតនៅឯពោធិមណ្ឌលមិនទាន់ប្រកាសនូវព្រះធម្មចក្កក្តី រហូតមកបានសម្តែងព្រះធម៌ចាប់តាំងពីការប្រកាសនូវព្រះធម្មចក្កក្តី ទ្រង់បញ្ញត្តនូវសច្ចៈ ៤ តែប៉ុណ្ណោះ។

អវិជ្ជាជាបច្ច័យនៃសង្ខារ រហូតដល់ការកើតឡើងនៃកងទុក្ខទាំងអស់នេះហៅថា លោកសមុទយៈ ។ លោកសមុទយៈមានទាំងទុក្ខសច្ច មានទាំងសមុទយសច្ច ។ ចំណែកខាងនិរោធវារៈ បានដល់ការរលត់អស់មិនមានសេសសល់នូវអវិជ្ជា អភិសង្ខារក៏រលត់ រហូតដល់ការរលត់អស់នូវកងទុក្ខទាំងពួង នេះគឺជានិរោធសច្ច ។ និរោធសច្ចមិនមែនជាភង្គៈដែលជាការរលត់ ឬការបែក



ធ្លាយនៃសង្ខារទាំងឡាយនោះទេ ពោលគឺមិនមែនជាឧប្បាទនិរោធឡើយ តែនិរោធសច្ចគឺជាអនុប្បាទនិរោធ បានសេចក្តីថា និរោធព្រោះមិនមានការកើត ឬនិរោធព្រោះអស់បច្ច័យ ឬក៏និរោធព្រោះមិនមានការឃុំឃាំង (និ+រោធ)។ ក្នុងបិដកលេខ ៥២,ទំព័រ ១១៤ ព្រះអង្គគង់នៅទាគល់ព្រះពោធិព្រឹក្ស ពេលដែលទើបតែបានត្រាស់ដឹងថ្មីៗ ទ្រង់ព្រះឧទានថា

ក្នុងកាលណាធម៌ទាំងឡាយប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំងកិលេសឱ្យក្តៅ ជាអ្នកដុតបង់នូវកិលេស ក្នុងកាលនោះ សេចក្តីសង្ស័យទាំងឡាយរបស់ព្រាហ្មណ៍នោះរមែងអស់ទៅ ព្រោះបានដឹងច្បាស់នូវធម៌ព្រមដោយហេតុ ។

ក្នុងទំព័រ ១១៥ ,បិដកលេខ ៥២ ដដែល ទ្រង់ឧទានថា

ក្នុងកាលណា ធម៌ទាំងឡាយប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំងកិលេសឱ្យក្តៅ ជាអ្នកដុតបង់នូវកិលេស ក្នុងកាលនោះ សេចក្តីសង្ស័យទាំងឡាយរបស់ព្រាហ្មណ៍នោះរមែងអស់ទៅ ព្រោះបានដឹងច្បាស់នូវព្រះនិព្វានដែលជាធម៌អស់ទៅនៃបច្ច័យទាំងពួង ។

ក្នុងទំព័រ ១១៧ ,បិដកលេខ ៥២ ដដែល ទ្រង់ឧទានថា

ក្នុងកាលណា ធម៌ទាំងឡាយប្រាកដដល់ព្រាហ្មណ៍ អ្នកមាន

ព្យាយាមញាំងកិលេសឱ្យក្តៅ ជាអ្នកដុតបង់នូវកិលេស ក្នុងកាលនោះ ព្រាហ្មណ៍នោះរមែងកម្ចាត់បង់នូវមារ ព្រមទាំងសេនាមារ ឋិតនៅបីដូចជាព្រះអាទិត្យដែលរះឡើង ធ្វើអាកាសឱ្យរុងរឿងដោយរស្មីរបស់ខ្លួន កម្ចាត់បង់នូវងងឹតហើយឋិតនៅ ដូច្នោះឯង។

កាលដែលមិនទាន់បានសិក្សាក្នុងសច្ចធម៌ គឺប្រាកដជាមិនដឹងថា ធម៌ទាំងឡាយកើតពីហេតុដូចម្តេចនោះឡើយ តែងយល់ថាអ្វីៗកើតឯងៗ ឬយល់ថាខ្លួនឯងជាអ្នកធ្វើឱ្យខ្លួនឯង ពុំនោះទេក៏គិតថាអ្នកដទៃធ្វើឱ្យ ។ ក្នុងបិដកលេខ ៣១,ទំព័រ ៣៩ មានព្រះសូត្រ ១ គួរសិក្សាក្នុងអត្ថបទធម៌ទាំងឡាយកើតពីហេតុនេះគឺ

ខ្ញុំបានស្តាប់មកយ៉ាងនេះថា សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ហើយស្តេចចូលទៅក្នុងក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ អចេលកស្សបៈ បានឃើញព្រះមានព្រះភាគ យាងមកអំពីចម្ងាយលឹមៗ លុះឃើញហើយ ក៏ដើរចូលទៅរកព្រះមាន-ព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។



លុះអចេលកស្សបៈឋិតនៅក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា យើងខ្ញុំនឹងសួរនូវហេតុនីមួយចំពោះព្រះគោតមដ៏ចម្រើន បើព្រះគោតមដ៏ចម្រើនបើកឱកាសដើម្បីការដោះស្រាយប្រស្នារបស់យើងខ្ញុំ ។ ព្រះដ៏មាន-ព្រះភាគត្រាស់តបថា កុំអាលសិនកស្សបៈ កាលនេះជាកាលមិនគួរដល់ប្រស្នាទេ ព្រោះយើងកំពុងចូលមកកាន់ចន្លោះផ្ទះ ។ អចេលកស្សបៈ ក្រាបបង្គំសួរព្រះមានព្រះភាគជាគម្រប់ពីរដងថា យើងខ្ញុំនឹងសួរនូវហេតុនីមួយចំពោះព្រះគោតមដ៏ចម្រើន បើព្រះ-គោតមដ៏ចម្រើន បើកឱកាសដើម្បីការដោះស្រាយនូវប្រស្នារបស់យើងខ្ញុំ ។ កុំអាលសិនកស្សបៈ កាលនេះជាកាលមិនគួរដល់ប្រស្នាទេ ព្រោះយើងកំពុងចូលមកកាន់ចន្លោះផ្ទះ ។ អចេល-កស្សបៈ ក្រាបបង្គំសួរជាគម្រប់បីដង ។ល។ ព្រោះយើងកំពុងចូលមកកាន់ចន្លោះផ្ទះ ។

កាលដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ អចេលកស្សបៈ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា យើងខ្ញុំមិនមានបំណងដើម្បីសួរព្រះគោតមដ៏ចម្រើន ច្រើនរឿងទេ ។ ម្នាលកស្សបៈ អ្នកប្រាថ្នានឹងសួរហេតុណា ចូរសួរចុះ ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងឬអ្វី ។

ព្រះដ៏មានព្រះភាគត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សបៈ ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្តីទុក្ខ គឺបុគ្គលដទៃធ្វើឱ្យឬ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សបៈ ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឱ្យផង ឬអ្វី ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សបៈ ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្តីទុក្ខ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់អ្នកដទៃទេ គឺកើតឡើងដោយឥតហេតុ ឬអ្វី ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សបៈ ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខមិនមានទេឬ ។ ម្នាលកស្សបៈ សេចក្តីទុក្ខមិនមែនជាមិនមានទេ ម្នាលកស្សបៈ សេចក្តីទុក្ខមានដោយពិត ។ បើដូច្នោះ មានតែព្រះគោតមដ៏ចម្រើន មិនស្គាល់ មិនឃើញសេចក្តីទុក្ខទេឬ ។ ម្នាលកស្សបៈ តថាគតមិនមែនជាមិនស្គាល់មិនឃើញសេចក្តីទុក្ខទេ ម្នាលកស្សបៈ តថាគតស្គាល់សេចក្តីទុក្ខដោយពិត ម្នាលកស្សបៈ តថាគតឃើញសេចក្តីទុក្ខដោយពិត ។ ចុះកាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង ឬអ្វី ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សបៈ កាលដែល



ខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្តីទុក្ខ គឺបុគ្គលដទៃធ្វើឱ្យឬ ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សបៈ កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯងផង បុគ្គលដទៃធ្វើឱ្យផងឬ ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សបៈ កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ សេចក្តីទុក្ខ មិនមែនជាអំពើរបស់ខ្លួនឯង មិនមែនជាអំពើរបស់អ្នកដទៃទេ គឺកើតឡើងដោយឥតហេតុឬ ព្រះអង្គត្រាស់ថា កុំពោលយ៉ាងនេះឡើយ កស្សបៈ កាលដែលខ្ញុំសួរថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីទុក្ខ មិនមានទេឬ ព្រះអង្គត្រាស់ថា ម្នាលកស្សបៈ សេចក្តីទុក្ខមិនមែនជាមិនមានទេ ម្នាលកស្សបៈ សេចក្តីទុក្ខមានដោយពិត កាលដែលខ្ញុំសួរថា បើដូច្នោះ មានតែព្រះគោតមដ៏ចម្រើន មិនស្គាល់ មិនឃើញសេចក្តីទុក្ខទេឬ ព្រះអង្គត្រាស់ថា ម្នាលកស្សបៈ តថាគតមិនមែនជាមិនស្គាល់ មិនឃើញសេចក្តីទុក្ខទេ ម្នាលកស្សបៈ តថាគតស្គាល់សេចក្តីទុក្ខដោយពិត ម្នាលកស្សបៈ តថាគតឃើញសេចក្តីទុក្ខដោយពិត បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ប្រាប់សេចក្តីទុក្ខដល់ខ្ញុំផង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្តែងសេចក្តីទុក្ខដល់ខ្ញុំផង ។

ម្នាលកស្សបៈ កាលបើមានសេចក្តីយល់ឃើញខាងដើមថា គេធ្វើ គេក៏ទទួលផល ដូច្នេះ លទ្ធិថា សេចក្តីទុក្ខ គឺបុគ្គលធ្វើដោយខ្លួនឯង ក៏នឹងមាន បុគ្គលកាលពោលយ៉ាងនេះ ឈ្មោះថាប្រកាន់នូវសស្សតទិដ្ឋិនោះ ។ ម្នាលកស្សបៈ កាលបើមានសេចក្តីយល់ឃើញខាងដើមថា អ្នកដទៃធ្វើ អ្នកឯទៀតទទួលផល ដូច្នេះ បុគ្គលដែលត្រូវវេទនាគ្របសង្កត់ ក៏នឹងមានលទ្ធិថា សេចក្តីទុក្ខ គឺបុគ្គលដទៃធ្វើ បុគ្គលកាលពោលយ៉ាងនេះ ឈ្មោះថាប្រកាន់នូវឧច្ឆេទទិដ្ឋិនោះ ។ ម្នាលកស្សបៈ តថាគតមិនប្រកាន់នូវទីបំផុតទាំងពីរនោះឡើយ តែងសម្តែងធម៌ដោយបទកណ្តាលថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ។ល។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នោះ រមែងមានយ៉ាងនេះ ។ ការរលត់នៃសង្ខារ ព្រោះការវិនាសនិងការរលត់ឥតសេសសល់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់សង្ខារ ។ល។ ការរលត់នៃកងទុក្ខទាំងអស់នោះ រមែងមានយ៉ាងនេះ ។

កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អចេលកស្សបៈ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺច្បាស់



ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចបុគ្គលផ្ងារឡើងនូវវត្ថុដែលផ្កាប់ ។ល។ ដោយគិតថា ពួកបុគ្គលមានភ្នែកភ្លឺ នឹងឃើញរូបបាន យ៉ាងណាមិញ ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយដោយអនេកបរិយាយ ក៏យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរឭក បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទាក្នុងសម្នាក់នៃព្រះមាន-ព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សបៈ បុគ្គលណាធ្លាប់ជាអន្យតិរ្ថិយ ប្រាថ្នានូវបព្វជ្ជា ប្រាថ្នានូវឧបសម្បទាក្នុងធម្មវិន័យនេះ បុគ្គលនោះតែងនៅបរិវាសអស់ ៤ ខែសិន លុះបុគ្គលនោះបាននៅបរិវាសកន្លង ៤ ខែហើយ ពួកភិក្ខុដែលមានចិត្តប្រោសប្រាណ កាលបើប្រាថ្នា ទើបបំបួស ទើបឱ្យឧបសម្បទាដើម្បីភិក្ខុភាពបាន ម្យ៉ាងទៀត តថាគតបានដឹងច្បាស់នូវការផ្សេងនៃបុគ្គលដែលគួរនៅបរិវាសនិងមិនគួរនៅបរិវាស ។ អចេល-កស្សបៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើបុគ្គលទាំងឡាយធ្លាប់ជាអន្យតិរ្ថិយ ប្រាថ្នានូវបព្វជ្ជា ប្រាថ្នានូវឧបសម្បទា ក្នុងធម្មវិន័យនេះ តែងនៅបរិវាសអស់ ៤ ខែសិន លុះបុគ្គលនោះនៅបរិវាសកន្លង ៤ ខែហើយ ពួកភិក្ខុដែលមានចិត្តប្រោសប្រាណ កាលបើ

ប្រាថ្នា ទើបបំបួស ទើបឱ្យឧបសម្បទា ដើម្បីភិក្ខុភាពបាន ឯខ្ញុំព្រះអង្គនឹងហ៊ាននៅបរិវាសអស់ ៤ ឆ្នាំ លុះខ្ញុំព្រះអង្គបាននៅបរិវាសកន្លង ៤ ឆ្នាំហើយ សូមពួកភិក្ខុដែលមានចិត្តប្រោសប្រាណ បំបួស ឱ្យឧបសម្បទា ដើម្បីភិក្ខុភាពឱ្យទាន ។

អចេលកស្សបៈ ក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ ។ លុះកស្សបៈមានអាយុ បានឧបសម្បទាហើយ មិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងកម្តៅនូវកិលេស មានចិត្តស្ទុង (ទៅកាន់ព្រះនិព្វាន) ។ កុលបុត្រទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឱ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌ដែលជាទីបំផុតនៃព្រហ្មចរិយធម៌នោះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ហើយក៏បានដឹងច្បាស់ថាជាតិ (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំង-ឡាយ ព្រះកស្សបៈមានអាយុក៏រាប់ថាជាព្រះអរហន្តមួយអង្គដែរ ។



# ៣. អរិយសច្ច ៤

អរិយសច្ច ៤ ជាគោលធម៌សំខាន់ក្នុងព្រះពុទ្ធសាសនាដែលព្រះអង្គទ្រង់ត្រាស់សម្តែង ចាប់ផ្តើមអំពីព្រះធម្មចក្កប្បវត្តនសូត្ររហូតដល់ព្រះបណ្តាំចុងក្រោយ ។

អរិយសច្ច ៤ ជាទីតាំងនៃបញ្ញាក្នុងការដោះស្រាយបញ្ហាគ្រប់យ៉ាងក្នុងជីវិត ព្រោះបង្ហាញអំពីតួបញ្ហា ហេតុនៃបញ្ហា ការអស់បញ្ហា និង ការដោះស្រាយ ។

អរិយសច្ច ៤ ជាធម៌គន្លឹះនៃការដោះស្រាយបញ្ហា ចាត់ការជាមួយនឹងជីវិតរបស់ខ្លួន ដោយបញ្ញាខ្លួនឯង គឺជាការនាំយកនូវសេចក្តីពិតនៃជីវិតមកប្រើជាប្រយោជន៍ ដោយមិនវង្វេងដោះ-ស្រាយតាមបែបបន់ស្រន់ ឬតាមបែបពឹងពាក់របស់ក្នុងលោកនេះដោយអំណាចតណ្ហានោះឡើយ ។

អរិយសច្ច ៤ ជាធម៌ពិតគ្រប់ពេល មិនថាសម័យដែលព្រះពុទ្ធអង្គគង់ព្រះជន្មនៅ ឬសម័យសព្វថ្ងៃនេះឡើយ ព្រោះអរិយសច្ច ៤ នេះ មិនមែនជាបញ្ញត្តិធម៌ទេ គឺជាបរមត្ថធម៌សុទ្ធៗ ឱ្យតែមានជីវិតិន្ទ្រិយគឺមានសច្ចៈ ២ ខាងដើមហើយស្រេច ។

## I~ វិនិច្ឆ័យដោយសុញ្ញតា

១- **ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ**
**ការកោ ន ក្រិយាវ វិជ្ជតិ**
**អត្ថិ និព្វុតិ ន និព្វុតោ បុមា**
**មគ្គមត្ថិ គមកោ ន វិជ្ជតិ ។**

សេចក្តីពិត គឺមានតែទុក្ខប៉ុណ្ណោះ បុគ្គលណាៗ ជាអ្នកទុក្ខមិនមានឡើយ ការធ្វើមាន តែបុគ្គលអ្នកធ្វើមិនមាន ការរលត់មាន តែបុគ្គលអ្នករលត់មិនមាន ផ្លូវមាន តែបុគ្គលអ្នកដើរមិនមាន ។

២- **សុញ្ញតា** បន្តទៀត គឺនៅក្នុងសច្ចៈទាំង ៤ គប្បីជ្រាបនូវសច្ចៈ ២ ខាងដើមថា សូន្យចាកភាពទៀង ភាពស្អាត ភាពសុខ និង ភាពជាអត្តា ។ អមតបទ សូន្យចាកអត្តា ចំណែកមគ្គសច្ច សូន្យចាកភាពទៀង ភាពសុខ និង ភាពជាអត្តា ។

៣- សច្ចៈ ៣ សូន្យចាកនិរោធ ឬនិរោធសច្ចសូន្យចាកសច្ចៈ ៣ ។

៤- សច្ចៈដែលជាហេតុសូន្យចាកសច្ចៈដែលជាផល សូម្បីសច្ចៈដែលជាផលនោះក៏សូន្យចាកសច្ចៈដែលជាហេតុដែរ ។



## II~ វិនិច្ឆ័យដោយកិច្ចនៃញាណ

សច្ចញ្ញាណមាន ២ យ៉ាងគឺ

១- **អនុពោធញ្ញាណ** ញាណដែលដឹងដោយលំដាប់

២- **បដិវេធញ្ញាណ** ញាណដែលចាក់ធ្លុះ ។

បណ្តាញាណទាំង ២ នេះ អនុពោធញ្ញាណ គឺជាលោកិយ រមែងប្រព្រឹត្តទៅក្នុងនិរោធនិងមគ្គ ដោយអំណាចនៃការស្តាប់ជាដើម។ បដិវេធញ្ញាណ គឺជាលោកុត្តរ ធ្វើនិរោធឱ្យជាអារម្មណ៍ ហើយចាក់ធ្លុះសច្ចៈទាំង ៤ ដោយកិច្ចដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយឃើញទុក្ខ បុគ្គលនោះរមែងឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង ដូច្នេះជាដើម ។

ម្យ៉ាងទៀត សច្ចញ្ញាណដែលជាលោកិយនេះ **ទុក្ខញ្ញាណ** រមែងហាមនូវសក្កាយទិដ្ឋិ ដែលកំពុងប្រព្រឹត្តទៅជាបរិយុដ្ឋាននោះ ដោយអំណាចនៃការគ្របសង្កត់ ។ **សមុទយញ្ញាណ** រមែងហាមនូវឧច្ឆេទទិដ្ឋិ ។ **និរោធញ្ញាណ** រមែងហាមនូវសស្សតទិដ្ឋិ ។ **មគ្គញ្ញាណ** រមែងហាមនូវអកិរិយទិដ្ឋិ ។

ម្យ៉ាងទៀត **ទុក្ខញ្ញាណ** រមែងហាមការបដិបត្តិខុសក្នុងផល គឺការដែលបានសម្គាល់ខុសក្នុងបញ្ចក្ខន្ធថាទៀង ថាស្អាត

ថាសុខ និង ថាមានអត្តាតួខ្លួន ។ **សមុទយញ្ញាណ** ហាមការបដិបត្តិខុសក្នុងហេតុ គឺការដែលប្រព្រឹត្តទៅក្នុងការរាប់អានចំពោះអ្វីដែលមិនមែនជាហេតុថាជាហេតុ ដូចជាយល់ថា លោកនេះរមែងប្រព្រឹត្តទៅដោយព្រះជាម្ចាស់ ព្រះព្រហ្ម ព្រះសិវៈ និងអ្វីដទៃទៀត ឬប្រព្រឹត្តទៅដោយខ្លួនឯងជាដើម ។ **និរោធញ្ញាណ** ហាមការបដិបត្តិខុសក្នុងនិរោធ គឺប្រកាន់ក្នុងអរូបលោក ឬក្នុងភូមិដែលជាកំពូលនៃភពជាដើមថាជាព្រះនិព្វាន ។ **មគ្គញ្ញាណ** រមែងហាមការបដិបត្តិខុសក្នុងឧបាយ គឺមានការប្រកាន់ក្នុងផ្លូវដែលមិនបរិសុទ្ធ ដូចជាកាមសុខល្លិកានុយោគ និង អត្តកិលមថានុយោគជាដើម ថាជាមគ្គដ៏បរិសុទ្ធ ។ ព្រោះហេតុនោះ ទើបបណ្ឌិតចងគាថានេះទុកថា

**លោកេ លោកប្បភវេ លោកត្ថគមេ សិវេ ច តទុបាយេ**
**សម្មុយ្ហតិ តាវ នរោ ន វិជានាតិ យាវ សច្ចានិ ។**

នរជន មិនទាន់បានត្រាស់ដឹងនូវសច្ចៈទាំងឡាយដរាបណា គេរមែងវង្វេងក្នុងលោក ក្នុងហេតុដែលនាំឱ្យកើតលោក ក្នុងព្រះនិព្វានដែលជាការរលត់ទៅនៃលោក និង ក្នុងឧបាយនៃការរលត់លោកនោះ ដរាបនោះឯង ។



### III. វិនិច្ឆ័យដោយឧបមា

១- ឧបមាដូចរបស់ធ្ងន់

គប្បីឃើញទុក្ខសច្ចដូចរបស់ធ្ងន់ សមុទយសច្ចដូចការលើកកាន់របស់ធ្ងន់ និរោធសច្ចដូចការដាក់ចុះហើយនូវរបស់ធ្ងន់ មគ្គសច្ចដូចឧបាយជាគ្រឿងដាក់ចុះនូវរបស់ធ្ងន់នោះឯង ។

២- ឧបមាដូចរោគ

គប្បីឃើញទុក្ខសច្ចដូចរោគ សមុទយសច្ចដូចសមុដ្ឋាននៃរោគ និរោធសច្ចដូចការស្ងប់នៃរោគ មគ្គសច្ចដូចភេសជ្ជៈថ្នាំកែរោគ ។

៣- ឧបមាដូចស្រុកអត់បាយ (ទុព្ភិក្ខ)

គប្បីឃើញទុក្ខសច្ចដូចស្រុកអត់បាយ សមុទយសច្ច ដូចភ្លៀងមិនល្អ និរោធសច្ចៈដូចស្រុកសម្បូណ៌បាយ មគ្គសច្ច ដូចការមានភ្លៀងធ្លាក់ល្អ ។

៤- ឧបមាដូចពៀរវេរា ។

៥- ឧបមាដូចដើមឈើមានពិស ។

៦- ឧបមាដូចភ័យ ។

៧- ឧបមាដូចត្រើយអាយ ។

គប្បីឃើញទុក្ខសច្ចដូចត្រើយអាយ សមុទយសច្ចដូច

អន្លង់ទឹកធំ និរោធសច្ចដូចត្រើយនាយ មគ្គសច្ចដូចការព្យាយាម ហែលឱ្យដល់ត្រើយនាយ ដូច្នោះឯង ។

### IV~ វិនិច្ឆ័យដោយសភាគនិងវិសភាគ

១- សច្ចៈទាំងបួន ជាសភាគ គឺមានចំណែកស្មើគ្នា ដោយជារបស់ពិត ដោយជារបស់សូន្យចាកខ្លួន និង ដោយជារបស់ចាក់ធ្លុះបានដោយលំបាក ។ ជាវិសភាគ គឺមានចំណែកមិនស្មើគ្នា ដោយកំណត់លក្ខណៈរបស់ខ្លួន ។

២- សច្ចៈ ២ ដំបូង គឺទុក្ខសច្ចនិងសមុទយសច្ច ជាសភាគ ព្រោះជាធម៌ជ្រៅ ដោយអត្ថថា ចូលដល់បានដោយក្រ និងព្រោះជាលោកិយ ឬជាសាសវធម៌ បានដល់ធម៌ជាអារម្មណ៍នៃអាសវៈ ។ ជាវិសភាគ ព្រោះចែកជាផលនិងហេតុ ម្យ៉ាងទៀត ព្រោះជាធម៌គួរកំណត់ដឹង និងជាធម៌គួរលះ (បរិញ្ញេយ្យបហា-តព្វកិច្ច ) ។ សច្ចៈ ២ ខាងក្រោយ គឺនិរោធសច្ចនិងមគ្គសច្ច ជាសភាគ ព្រោះជាធម៌ជ្រៅ និងព្រោះជាលោកុត្តរ ឬជាអនាសវ-ធម៌ បានដល់ធម៌មិនជាអារម្មណ៍នៃអាសវៈ ។ ជាវិសភាគ ព្រោះជាវិសយ និង វិសយី (និរោធជាវិសយ ព្រោះជាអារម្មណ៍របស់មគ្គ ឯចំណែកមគ្គ ជាវិសយី ព្រោះមាននិរោធ គឺព្រះនិព្វានជា



អារម្មណ៍ ) ។ ម្យ៉ាងទៀត ព្រោះជាធម៌គួរធ្វើឱ្យជាក់ច្បាស់ (សច្ឆិកាតព្វៈ ) និងព្រោះជាធម៌គួរចម្រើន (ភាវេតព្វៈ ) ។

៣- សច្ចៈទី ១ និង សច្ចៈទី ៣ ជាសភាគ ព្រោះជាផល ជាវិសភាគ ព្រោះជាសង្ខតៈនិងអសង្ខតៈ ។ សច្ចៈទី ២ និង សច្ចៈទី ៤ ជាសភាគ ព្រោះជាហេតុ ជាវិសភាគ ព្រោះជាអកុសល និងកុសល ។

៤- សច្ចៈទី ១ និង សច្ចៈទី ៤ ជាសភាគ ព្រោះជាសង្ខតៈ ជាវិសភាគ ព្រោះជាលោកិយនិងលោកុត្តរ ។ សច្ចៈទី ២ និង សច្ចៈទី ៣ ជាសភាគ ព្រោះជា **នេវសេក្ខានាសេក្ខា** ជាវិសភាគ ព្រោះជា **សារម្មណៈ** និង **អនារម្មណៈ** ។

### V~ វិនិច្ឆ័យដោយចតុកៈ

១- ក្នុងចតុកៈនេះ ធម៌ទាំងឡាយដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផលទាំងឡាយឈ្មោះថាជាទុក្ខ ព្រោះជាសង្ខារទុក្ខ ដោយព្រះបាលីថា **យទនិច្ចំ តំ ទុក្ខំ** របស់ណាមិនទៀងរបស់នោះជាទុក្ខ ប៉ុន្តែទុក្ខនេះមិនមែនអរិយសច្ច (សច្ចវិមុត្តិ ) ។

និរោធជាអរិយសច្ច តែមិនមែនជាទុក្ខ ។

អរិយសច្ច ២ បានដល់សមុទយសច្ច និងមគ្គសច្ច គឺជាទុក្ខ ព្រោះការមិនទៀង តែមិនមែនជាទុក្ខអរិយសច្ចដែលកុលបុត្រអ្នកប្រព្រឹត្តនូវព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ គប្បីកំណត់ដឹងនោះឡើយ ។

ចំណែកឧបាទានក្ខន្ធ ៥ វៀរតណ្ហាចេញហើយ គឺទាំងជាទុក្ខ ព្រោះមិនទៀង ទាំងជាទុក្ខអរិយសច្ច ។

ធម៌ដែលសម្បយុត្តដោយមគ្គនិងសាមញ្ញផល មិនមែនជាទុក្ខ ដែលកុលបុត្រអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះដ៏-មានព្រះភាគ គប្បីកំណត់ដឹងនោះឡើយ ទាំងមិនមែនជាទុក្ខ-អរិយសច្ច ។

២- កិលេសដែលជាសមុទយៈ ក្រៅពីតណ្ហា ជាសមុទយៈ ព្រោះអត្ថថា ធ្វើឱ្យកើតទុក្ខ តែមិនមែនសមុទយសច្ច ។

និរោធជាអរិយសច្ច តែមិនមែនជាសមុទយសច្ច ។

ទុក្ខសច្ចនិងមគ្គសច្ច ជាសមុទយៈក៏បាន ព្រោះជាហេតុជាបច្ច័យនៃផលរបស់ខ្លួន តែមិនមែនជាសមុទយសច្ចដែលជាសច្ចៈត្រូវលះបង់នោះឡើយ ។

តណ្ហា គឺទាំងជាសមុទយ ទាំងជាអរិយសច្ចដែលជាសច្ចៈត្រូវលះបង់ ។



ធម៌ដែលសម្បយុត្តដោយមគ្គនិងសាមញ្ញផល មិនមែនជាសមុទយៈដែលគប្បីលះផង ទាំងមិនមែនជាអរិយសច្ចផង (ព្រោះជាសច្ចវិមុត្តិ) ។

៣- សង្ខារនិរោធ និង និរោធសមាបត្តិជានិរោធ តែមិនមែននិរោធអរិយសច្ច ។

សមុទយៈជាអរិយសច្ច តែមិនមែនជានិរោធសច្ច ។

ទុក្ខសច្ច និង មគ្គសច្ចជានិរោធក៏បានដែរ គឺខណៈនិរោធ (ភង្គៈបែកធ្លាយ)។

អសង្ខតធាតុទាំងជានិរោធ ទាំងជាអរិយសច្ច ។

ធម៌ដែលសម្បយុត្តដោយមគ្គនិងសាមញ្ញផល មិនមែនជានិរោធដែលគប្បីជាក់ច្បាស់ ទាំងមិនមែនជាអរិយសច្ច ។

៤- អង្គមគ្គដទៃក្រៅអំពីអរិយមគ្គ ជាមគ្គ តែមិនមែនមគ្គអរិយសច្ច ។

និរោធជាអរិយសច្ច តែមិនមែនជាមគ្គ ។

ទុក្ខ និង សមុទយៈ ជាមគ្គក៏បានដែរ ព្រោះជាផ្លូវទៅកាន់ភព តែមិនមែនជាអរិយមគ្គដែលគួរចម្រើនដើម្បីនិរោធឡើយ ។

និរោធគាមិនីបដិបទា ទាំងជាមគ្គទាំងជាអរិយសច្ចដោយប្រការទាំងពួង ។

ធម៌ដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផល មិនមែនជាមគ្គដែលគប្បីចម្រើន និងមិនមែនជាអរិយសច្ច ។

## VI. វិនិច្ឆ័យដោយអត្ថ

ប្រសិនបើមានពាក្យសួរថា អ្វីដែលជាអត្ថរបស់សច្ចៈនោះ នឹងមានពាក្យតបយ៉ាងពិស្តារថា ភាវៈណា កាលបើបុគ្គលសម្លឹងមើលដោយបញ្ញាចក្ខុ ភាវៈនោះ រមែងមិនវិបរិតដូចជាកលមាយា មិនបញ្ឆោតភ្នែកដូចជាថ្ងៃបណ្ដើរកូន និង មិនជាសភាវៈដែលអ្នកណាៗរកមិនបានដូចអត្តារបស់ពួកអន្យតិរ្ថិយឡើយ ។ ដោយពិតសច្ចៈគឺជាគោចរ (អារម្មណ៍) នៃអរិយញ្ញាណ ជារបស់ពិតប្រាកដមិនវិបរិតដូចជាលក្ខណៈភ្លើង និង ដូចជាធម្មតារបស់សត្វលោក (សត្វលោកត្រូវកើតចាស់ឈឺស្លាប់ជាធម្មតា)ដូច្នោះឯង ។ បណ្ឌិតគប្បីជ្រាបថា នេះជាអត្ថរបស់សច្ចៈ ដូចដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ថា **ឥទំ ទុក្ខន្តិ ខោ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ** ៖ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះទុក្ខ នោះឯងគឺជារបស់ពិត នោះឯងគឺជារបស់មិនខុស នោះឯងគឺជារបស់ដែលមិនទៅជាប្រការដទៃឡើយ ។

ម្យ៉ាងទៀតព្រះអង្គទ្រង់ត្រាស់ថា



**នាពាធកំ យតោ ទុក្ខំ ទុក្ខា អញ្ញំ ន ពាធកំ**
**ពាធកត្តនិយាមេន តតោ សច្ចមិទំ មតំ ។**

ប្រែថា មិនមានការបៀតបៀន មានទុក្ខអំពីណា គឺថាក្រៅអំពីទុក្ខមិនមានការបៀតបៀនឡើយ ព្រោះដូច្នោះ ទុក្ខនេះឯងបណ្ឌិតគប្បីដឹងថា ជាសច្ចៈ ដោយកំណត់អត្ថថា ជាតួបៀតបៀន។

## VII. វិនិច្ឆ័យដោយជាធម៌តែម្យ៉ាងជាដើម

១- ទុក្ខសច្ចទាំងអស់ ឈ្មោះថា តែម្យ៉ាង ព្រោះជាបវត្តិ គឺជាធម៌ប្រព្រឹត្តទៅក្នុងវដ្តៈ ។ ជាពីរយ៉ាង គឺនាម ១ និង រូប ១ ។ ជាបីយ៉ាង គឺ កាមភព ១, រូបភព ១ និង អរូបភព ១ ។ ជាបួនយ៉ាងគឺ អាហារ ៤ ។ ជាប្រាំយ៉ាង គឺ ឧបាទានក្ខន្ធ ៥ ។

២- សមុទយសច្ច តែម្យ៉ាង ព្រោះជាសភាវៈញ៉ាំងវដ្តៈឱ្យប្រព្រឹត្តទៅ ។ ជាពីរយ៉ាង គឺជាធម៌សម្បយុត្តដោយទិដ្ឋិ និងមិនសម្បយុត្តដោយទិដ្ឋិ ។ ជាបីយ៉ាង ដោយចែកជា កាមតណ្ហា ភវតណ្ហា និង វិភវតណ្ហា ។ ជាបួនយ៉ាង គឺជាទោសដែលមគ្គ ៤ គប្បីលះ ។ ជាប្រាំយ៉ាង ដោយចែកតាមអារម្មណ៍ មានសេចក្តីត្រេកអរក្រៃលែងក្នុងរូបជាដើម ។ ជាប្រាំមួយយ៉ាង គឺដោយប្រភេទនៃកងតណ្ហា ៦ ។

៣- និរោធសច្ច តែម្យ៉ាង ព្រោះជាអសង្ខតធាតុ ។ តែដោយបរិយាយ គឺអម និរោធមាន ២ យ៉ាង បានដល់ សឧបាទិសេសនិព្វាន និង អនុបាទិសេសនិព្វាន។ ជាបីយ៉ាង ព្រោះស្ងប់នូវភពទាំង ៣ ។ ជាបួនយ៉ាង ព្រោះជាអារម្មណ៍ឱ្យសម្រេចមគ្គ ៤ ។ ជាប្រាំយ៉ាង ព្រោះស្ងប់សេចក្ដីត្រេកអរក្រៃលែងក្នុង រូបជាដើម ។ ជាប្រាំមួយយ៉ាង ដោយប្រភេទនៃការអស់កងតណ្ហា ៦ ។

៤- មគ្គសច្ច តែម្យ៉ាង ព្រោះជាធម៌គួរចម្រើន ។ ជាពីរយ៉ាង ដោយចែកជា សមថៈ និង វិបស្សនា ឬម្យ៉ាងទៀតជាពីរយ៉ាង ដោយប្រភេទនៃទស្សនៈ និង ភាវនា ។ ជាបីយ៉ាងដោយប្រភេទនៃខន្ធ ៣ មានសីលក្ខន្ធជាដើម ។ ជាបួនយ៉ាង ដោយអំណាចនៃមគ្គ ៤ ។

- សច្ចៈទាំង ៤ មានតែម្យ៉ាង ព្រោះជាធម៌ដែលមានពិត ឬព្រោះជាអភិញ្ញេយ្យធម៌ គឺធម៌ដែលគប្បីដឹងដ៏ក្រៃលែង ។ ពីរយ៉ាង ដោយលោកិយ និង លោកុត្តរ ម្យ៉ាងទៀត ពីរយ៉ាងដោយសង្ខតៈ និង អសង្ខតៈ ។

## VIII~ វិនិច្ឆ័យដោយលំដាប់

១- អរិយសច្ច ៤ ពោលដោយលំដាប់នៃទេសនា គឺ



ទុក្ខសច្ច ជាសច្ចៈដែលដឹងបានងាយជាង ព្រោះជាធម៌គ្រោតគ្រាត និងព្រោះជាធម៌ទូទៅដល់សត្វទាំងអស់ ព្រោះហេតុដូច្នោះ ទើបទ្រង់ត្រាស់សម្ដែងមុន ។ សមុទយសច្ច ត្រាស់ក្នុងលំដាប់នៃទុក្ខសច្ច ដើម្បីសម្ដែងហេតុនៃទុក្ខសច្ចនោះឯង ។ និរោធសច្ចត្រាស់ទុកដោយលំដាប់នៃសមុទយសច្ចនោះ ដើម្បីសម្ដែងឱ្យដឹងថា ព្រោះហេតុរលត់ ទើបផលរលត់ ។ មគ្គសច្ចទ្រង់ត្រាស់សម្ដែងក្នុងទីបំផុត ដើម្បីសម្ដែងឧបាយជាគ្រឿងសម្រេចនូវនិរោធសច្ចនោះ ។

២- ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុក្ខសច្ចមុន ដើម្បីឱ្យកើតសេចក្ដីសង្វេគដល់ពួកសត្វដែលជាអ្នកត្រេកអរ និងប្រាថ្នានូវសេចក្ដីសុខក្នុងភព ។ ត្រាស់សមុទយសច្ច ក្នុងលំដាប់នៃទុក្ខសច្ចនោះ ដើម្បីឱ្យដឹងថា ទុក្ខនោះឯងមិនមានឡើយ បើមិនមានតណ្ហាជាតួសាងទេនោះ មិនមែនព្រោះហេតុខាងក្រៅ មានព្រះជាម្ចាស់ជាដើមជាអ្នកបណ្ដាលឡើយ គឺដោយពិត ទុក្ខមានព្រោះមានតណ្ហា ។ បន្ទាប់មកទៀត ទ្រង់ត្រាស់និរោធសច្ច ដើម្បីឱ្យកើតភាពធូរស្រាល ស្រឡះក្នុងចិត្ត ដោយការបានឃើញការរលាស់ចេញចាកទុក្ខ ។ ជាចុងក្រោយព្រះអង្គសម្ដែងមគ្គសច្ច ជាធម៌ឱ្យដល់នូវនិរោធនោះ ។

ក្នុងបិដកលេខ ២១, ទំព័រ ១៩៣ ព្រះសារីបុត្តសម្តែងថា នៃអ្នកដ៏មានអាយុទាំងឡាយ ស្នាមជើងទាំងឡាយណាមួយរបស់ពួកសត្វដែលឋិតនៅលើផ្ទៃដី ស្នាមជើងទាំងអស់នោះ តែងប្រជុំចុះក្នុងស្នាមជើងដំរី ស្នាមជើងដំរីប្រាកដជាវិសេសជាងស្នាមជើងនៃសត្វទាំងអម្បាលនោះ ព្រោះស្នាមជើងដំរីនោះ ជាស្នាមជើងធំដូចម្តេចមិញ ម្នាលអ្នកដ៏មានអាយុទាំងឡាយ កុសលធម៌ទាំង-ឡាយឯណានីមួយ កុសលធម៌ទាំងអស់នោះ តែងសង្គ្រោះចូលក្នុងអរិយសច្ចទាំង ៤ ដូច្នោះឯង ។

ក្នុងបិដកលេខ ៦, ទំព័រ ៣៤ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ញាណទស្សនៈគឺការដឹងការឃើញតាមពិត គ្រប់បរិវដ្ដៈ ៣ អាការ ១២ ប្រព្រឹត្តទៅក្នុងអរិយសច្ចទាំង-ឡាយ ៤ នេះនៃតថាគត នៅមិនទាន់បរិសុទ្ធត្រឹមណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្តេជ្ញាខ្លួនថាជាអ្នកបានសម្រេចនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ទេវតានិងមនុស្សត្រឹមនោះដែរ ។

ក្នុងបិដកលេខ ១៦, ទំព័រ ១៩៣ ពេលព្រះពុទ្ធអង្គជិតនឹងបរិនិព្វាន ទ្រង់គង់នៅកោដិគ្រាម បានត្រាស់នឹងភិក្ខុទាំងឡាយថា



ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅត្រាច់រង្គាត់ទៅក្នុងសង្សារវដ្តអស់កាលដ៏យូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសច្ចទាំង ៤ ។ ជាបន្តមកដល់ទំព័រ ១៩៥ ព្រះអង្គទ្រង់ត្រាស់ថា

ការត្រាច់រង្គាត់ទៅអស់កាលជាអង្វែងក្នុងជាតិនោះៗឯង ក៏ព្រោះតែមិនបានឃើញនូវអរិយសច្ចទាំង ៤ តាមពិត ។ ចំពោះអរិយសច្ចទាំង ៤ នោះ បើបុគ្គលបានឃើញហើយ ខ្សែតណ្ហាដែលនាំសត្វអំពីភពមួយទៅភពមួយក៏ត្រូវដកចេញបាន ឫសគល់នៃសេចក្តីទុក្ខក៏ត្រូវកាត់ផ្តាច់ហើយ ភពថ្មីទៀតក្នុងកាលឥឡូវនេះមិនមានឡើយ ។

ការសម្តែងអំពីសេចក្តីពិត ទាំងដែលជាប្រយោជន៍ដល់សត្វលោក គឺជាលក្ខណៈនៃពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះ-សម្មាសម្ពុទ្ធ ។ ប្រសិនបើមិនជាប្រយោជន៍ទេ ទោះជាពាក្យពិតហើយក៏ដោយ ក៏ព្រះអង្គមិនសម្តែងឡើយ ។ អរិយសច្ច ៤ នេះឯង គឺជាសេចក្តីពិតដ៏សំខាន់បំផុត កាលដែលព្រះអង្គទ្រង់ប្រកាសសម្តែងនូវអនុបុព្វីកថារួចហើយ ព្រះអង្គតែងតែលើកឡើងនូវអរិយសច្ច ៤ នេះ ញ៉ាំងអ្នកស្តាប់ឱ្យសម្រេចមគ្គផល ។

បុគ្គលដែលមានសទ្ធាចេញចាកផ្ទះចូលកាន់ផ្នួស គ្រប់គ្រង

ជីវិតបានយ៉ាងប្រសើរ រស់នៅជាមួយនឹងព្រះដ៏មានព្រះភាគដោយមិនចាំបាច់បានអ្វីទាំងអស់ពីក្នុងលោកនេះ ប្រព្រឹត្តទៅដើម្បីបានជាក់ច្បាស់នៅក្នុងសច្ចៈ៤ យ៉ាងតែប៉ុណ្ណោះគឺជាការហើយស្រេច។

ក្នុងបិដកលេខ ៤៩, ទំព័រ ៦៥ ព្រះសារីបុត្តបានសម្តែងថា ម្នាលអាវុសោ គុណជាតិណា ដែលបុគ្គលមិនបានដឹង មិនបានឃើញ មិនបានដល់ មិនបានធ្វើឱ្យជាក់ច្បាស់ មិនទាន់បានត្រាស់ដឹងនៅឡើយ បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ គឺដើម្បីដឹង ដើម្បីឃើញ ដើម្បីដល់ ដើម្បីធ្វើឱ្យជាក់ច្បាស់ និង ដើម្បីបានត្រាស់ដឹងនូវគុណជាតិនោះឯង ។ គុណជាតិនោះគឺអរិយសច្ច ៤ បានដល់ទុក្ខសច្ច ១, សមុទយសច្ច ១, និរោធសច្ច ១ និង មគ្គសច្ច ១ ។

ក្នុងបិដកលេខ ២៣ មានព្រះសូត្រមួយឈ្មោះចូឡមាលុង្ក្យោវាទសូត្រ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងប្រាប់នូវសេចក្តីដែលព្រះតថាគតមិនបានសម្តែង និង សេចក្តីដែលព្រះតថាគតទ្រង់ត្រាស់សម្តែង នៅខាងចុងព្រះសូត្រ ទំព័រ ២៦១ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមាលុង្ក្យបុត្រ តថាគតតែងសម្តែងថា នេះជាទុក្ខ នេះជាហេតុនៃទុក្ខ នេះជាការរលត់ទុក្ខ នេះជាសេចក្តីប្រតិបត្តិក្នុងដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលមាលុង្ក្យបុត្រ



ហេតុដូចម្តេចបានជាតថាគតសម្តែងពាក្យនោះ ម្នាលមាលុង្ក្យបុត្រ ព្រោះថា ពាក្យនោះ ប្រកបដោយប្រយោជន៍ ពាក្យនោះជាខាងដើមនៃព្រហ្មចរិយធម៌ ពាក្យនោះប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ ប្រព្រឹត្តទៅដើម្បីរលត់ទុក្ខ ប្រព្រឹត្តទៅដើម្បីស្ងប់រំងាប់ ប្រព្រឹត្តទៅដើម្បីដឹងច្បាស់ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតសម្តែងនូវពាក្យនោះ ។

ក្នុងបិដកលេខ ៣៩ ,ទំព័រ ២៧៣ ពេលមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រៃធ្នង់ ជិតក្រុងកោសម្ពី ។ គ្រានោះឯងព្រះអង្គទ្រង់ចាប់ស្លឹកធ្នង់បន្តិចដោយព្រះហស្ត ហើយទ្រង់ត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ស្លឹកធ្នង់បន្តិចដែលតថាគតចាប់ដោយដៃ និង ស្លឹកធ្នង់ដែលនៅលើដើម[១] តើស្លឹកណាច្រើនជាង ? បពិត្រព្រះអង្គដ៏ចម្រើន ស្លឹកធ្នង់ដែលព្រះដ៏មានព្រះភាគចាប់ដោយព្រះហស្ត មានប្រមាណតិចណាស់ ឯស្លឹកធ្នង់ទាំងនោះដែលនៅលើដើម[២] មានចំនួនច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងហ្នឹងមែនហើយ អ្វីណាដែលតថាគតដឹងច្បាស់ហើយ តែមិនសម្តែងដល់អ្នកទាំង-

១,២ - អដ្ឋកថា = សីលបាវនេ ស្លឹកធ្នង់នៅលើដើមពេញទាំងព្រៃ ។

ឡាយ អ្វីនោះឯងមានចំនួនច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ ចំពោះអ្វីដែលតថាគតមិនសម្តែងនោះ ព្រោះមិនប្រកបដោយប្រយោជន៍ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរំលត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីស្ងប់រំងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង និង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែង គឺអរិយ-សច្ច៤ ព្រះអង្គទ្រង់ប្រកាសដូចនៅខាងចុងនៃមាលុង្ក្យោវាទសូត្រដែរ គឺជាធម៌ពិតហើយមានប្រយោជន៍ដល់ការរួចផុតចាកទុក្ខ ។ ស្លឹកធ្នង់នៅនឹងព្រះហស្តព្រះអង្គតិចណាស់ បើប្រៀបទៅនឹងចំនួនស្លឹកធ្នង់នៅនឹងដើមពេញទាំងព្រៃ ជាការបញ្ជាក់ថា ធម៌ដែលព្រះអង្គទ្រង់ត្រាស់សម្តែងគឺអរិយសច្ច ៤ នេះ មានប្រយោជន៍ដ៏ក្រៃលែង បើបានដឹងនូវអរិយសច្ច ៤ ហើយ មិនចាំបាច់ដឹងអ្វីដទៃទៀតក៏បាន ។ នៅខាងចុងនៃសីលបាសូត្រ គឺព្រះសូត្រដែលព្រះអង្គលើកយកស្លឹកធ្នង់មកប្រៀបធៀបនេះ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គប្បីធ្វើនូវសេចក្តីព្យាយាមដើម្បីដឹងតាមសេចក្តីពិតថា នេះទុក្ខ នេះហេតុនៃ



ទុក្ខ នេះការរលត់ទុក្ខ នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

អរិយសច្ច ៤ ជាគោលធម៌ចាំបាច់ ទាំងសម្រាប់បព្វជិត ទាំងសម្រាប់គ្រហស្ថ ក្នុងបិដកលេខ ៣៩ ,ទំព័រ ២៦៨ ព្រះអង្គទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ជនពួកណាមួយដែលអ្នកទាំងឡាយគប្បីអនុគ្រោះ ឬជនពួកណាជាមិត្តក្តី ជាអមាត្យក្តី ជាញាតិក្តី ជាសាលោហិតក្តី ដែលមានការសម្គាល់នូវពាក្យទូន្មានថាជាពាក្យគួរស្តាប់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរញ៉ាំងជនទាំងនោះឱ្យសមាទាន ឱ្យអាស្រ័យនៅ និង ឱ្យប្រតិស្ឋាននៅក្នុងការត្រាស់ដឹងតាមសេចក្តីពិតនូវអរិយសច្ច ៤ ។

នៅក្នុងគម្ពីរវិសុទ្ធិមគ្គ សច្ចនិទ្ទេស បានចែកពាក្យអរិយសច្ចជា ៤ ន័យគឺ

១- ដែលហៅថាអរិយសច្ច ព្រោះជាធម៌ដែលព្រះអរិយៈទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើមត្រាស់ដឹងឬចាក់ធ្លុះ ។

២- ដែលហៅថា អរិយសច្ច ព្រោះជាសច្ចៈរបស់ព្រះ-អរិយៈ ។ ដូចក្នុងបិដកលេខ ៣៩, ទំព័រ ២៦៩ ព្រះអង្គទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ តថាគតជាអរិយបុគ្គលក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ទាំងមនុស្សជាសម្មតិទេព និង មនុស្ស

ដ៏សេស ព្រោះហេតុនោះ សច្ចៈ ៤ ទើបហៅថាអរិយសច្ច[១] ។

៣- ដែលហៅថា អរិយសច្ច ព្រោះបានសម្រេចជាព្រះ-អរិយៈ ដោយសារបានត្រាស់ដឹងនូវសច្ចៈទាំងឡាយនោះ ។ ដូចក្នុងបិដកលេខ ៣៩, ទំព័រ ២៦៥ ព្រះអង្គទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ តថាគតដែលឈ្មោះថា អរហន្តសម្មាសម្ពុទ្ធ ព្រោះតថាគតបានត្រាស់ដឹងនូវសច្ចៈ ៤ នេះ តាមសេចក្តីពិត ។

៤- ដែលហៅថាអរិយសច្ច ព្រោះជាសច្ចៈយ៉ាងអរិយៈ គឺយ៉ាងពិតមិនប្រែប្រួល ។ ដូចក្នុងបិដកលេខ ៣៩, ទំព័រ ២៦៩ ព្រះអង្គទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ ជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ព្រោះហេតុនោះ បានជាតថាគត ហៅថា អរិយសច្ច[២] ។

## បទគួរយល់ដឹង

- ទុក្ខសច្ចគួរកំណត់ដឹង មិនមែនត្រូវលះបង់ទេ នេះជាកិច្ចនៃអរិយមគ្គ ។ កាលណាបើមិនបានកំណត់ដឹងនូវទុក្ខទេ រមែង

១- អដ្ឋកថា ៖ អរិយសច្ចៈទាំងឡាយនោះ, ឈ្មោះថាជារបស់ព្រះអរិយៈ ព្រោះព្រះតថាគតជាព្រះអរិយៈទ្រង់ត្រាស់ដឹងនិងត្រាស់សម្តែងហើយ ។ ២- វិសុទ្ធិមគ្គ ៖ ពាក្យថាអរិយៈក្នុងទីនេះមានសេចក្តីថា ពិតប្រាកដមិនប្រែប្រួល ។



ប្រកាន់ថាខ្លួនយើងជាអ្នកមាននូវសេចក្តីទុក្ខ ម្ល៉ោះហើយ តណ្ហាក៏ចេញមុខស្វែងរកសេចក្តីសុខដើម្បីលះទុក្ខ។ ព្រោះតណ្ហាជាបច្ច័យ សកម្មភាពដែលជាអភិសង្ខារក៏បានកើតឡើង ។

- ព្រហ្មចរិយធម៌នេះប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខ ។ កាលណាបើទុក្ខប្រាកដឡើងជាតួសង្ខារធម៌សុទ្ធ ការស្វែងរកសុខមកលះទុក្ខមិនមានឡើយ ដូច្នេះការកំណត់ដឹងនូវទុក្ខដោយការអប់រំសតិប្បដ្ឋាន គឺជាបដិបត្តិធម៌កម្ចាត់បង់នូវតណ្ហាព្រមទាំងអវិជ្ជា ។ ព្រោះមិនមានការស្វែងរកដោយតណ្ហា អភិសង្ខារក៏មិនមានដែរ នេះជាការអស់ទៅនៃកម្ម ។

- ការអស់ទៅនៃកម្មភពនិងឧបបត្តិភព គឺជាការរលត់ភព ជាអសង្ខតធាតុ ជាវិសង្ខារ ជាអប្បច្ចយា ធម្មា ។

- ការអប់រំចម្រើនសតិប្បដ្ឋាន ជាបដិបត្តិធម៌កំណត់ដឹងនូវទុក្ខ ។ ទុក្ខជាសភាវធម៌ មិនមែនជាសត្វឡើយ ការឃើញ ការឮ ។ល។ ការនឹកគិត ការសោយ ការចាំ ទាំងអស់នេះគឺជាទុក្ខ ។ បញ្ញាចម្រើនឡើងជាមួយនឹងការអប់រំសតិប្បដ្ឋាន បានកំណត់ដឹងទុក្ខទៅតាមកម្រិតនៃបរិញ្ញា តាំងអំពីវិបស្សនានៅទន់ខ្សោយរហូតដល់មានកម្លាំង ទីបំផុតមគ្គញ្ញាណក៏បានកើតឡើង ។ មគ្គញ្ញាណនេះ ធ្វើកិច្ចទាំង ៤ ព្រមគ្នាក្នុងអរិយសច្ច គឺធ្វើកិច្ចកំណត់ដឹង

ទុក្ខ ធ្វើកិច្ចលះបង់ហេតុនៃទុក្ខ ធ្វើកិច្ចជាក់ច្បាស់នូវព្រះនិព្វានជាអសង្ខតធាតុ និងធ្វើកិច្ចអប់រំមគ្គ គឺចម្រើនខ្លួនឯងដែលជាតួមគ្គ ។ មគ្គញ្ញាណមាន ៤ គឺសោតាបត្តិមគ្គញ្ញាណ ១, សកទាគាមិមគ្គញ្ញាណ ១, អនាគាមិមគ្គញ្ញាណ ១ និង អរហត្តមគ្គញ្ញាណ ១ ក្នុងមគ្គញ្ញាណមួយៗ ធ្វើកិច្ច ៤ យ៉ាងក្នុងអរិយសច្ច ទើបរាប់រួមទៅជាកិច្ច ១៦ ហៅថា សោឡសកិច្ច ។

- ក្នុងបិដកលេខ ៣៩ , ទំព័រ ២៧១ ព្រះគវម្បតិត្ថេរដ៏មានអាយុ បានសម្តែងធម៌ដល់ពួកភិក្ខុដូច្នេះថា ម្នាលអាវុសោទាំងឡាយ ពាក្យនេះខ្ញុំបានស្តាប់មកក្នុងទីចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ខ្ញុំបានទទួលក្នុងទីចំពោះព្រះភក្ត្រនៃព្រះដ៏មានបុណ្យថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ បុគ្គលនោះឈ្មោះថា ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង ។



# ៤- ធម៌ទាំងអស់ជាអនត្តា

ព្រះពុទ្ធសាសនា ប្រកាសគោលសំខាន់នៃសភាវធម៌ទាំងអស់ក្នុងលោកថាជាអនត្តា សេចក្តីប្រកាសនេះមិនមានក្នុងលទ្ធិសាសនាដទៃណាឡើយ ។ រហូតមកដល់សព្វថ្ងៃនេះ កាលណាបើឮពាក្យថាអនត្តា គឺយើងដឹងថាជាពាក្យក្នុងព្រះពុទ្ធសាសនា ដូចពាក្យថាផ្លូវកណ្តាល ធម៌ទាំងឡាយកើតពីហេតុ និង អរិយសច្ច ៤ ដែរ ពាក្យទាំងអស់នេះមាននៅតែក្នុងព្រះពុទ្ធសាសនាប៉ុណ្ណោះ ។

ពាក្យថាអនត្តាធម៌នេះ បន្ទាប់ពីបានស្តាប់ឮក្នុងគម្ពីរព្រះពុទ្ធសាសនាមក គឺត្រូវបានជាក់ច្បាស់ដោយបញ្ញាផ្ទាល់ខ្លួន កាលណាបើបញ្ញាត្រូវបានអប់រំចម្រើន ។ នាមធម៌ រូបធម៌ ក្នុងជីវិតរាល់ថ្ងៃ មានប្រក្រតីប្រាកដតាមទ្វារទាំង ៦ មានទ្វារភ្នែកជាដើម គឺជាទីតាំងនៃការអប់រំចម្រើនបញ្ញា នាមរូបនេះឯងដែលប្រាកដនូវលក្ខណៈជាអនត្តាដល់បញ្ញា ។

ព្រោះឋិតនៅក្នុងសេចក្តីសម្គាល់ថាជាអត្តាតួខ្លួន ទើបសត្វលោកត្រូវរវល់នឹងខ្លួនឯង ត្រូវប្រកាន់ត្រូវហួងហែង ត្រូវមានសកម្មភាពសព្វបែបយ៉ាងតាមអំណាចនៃសេចក្តីប្រាថ្នា ជាចំណែក

នៃវដ្តសង្សារ ប៉ុន្តែកាលដែលបានស្តាប់ព្រះធម៌ក្នុងព្រះពុទ្ធសាសនា ជាបច្ច័យឱ្យចម្រើនបញ្ញា ឃើញធម៌ទាំងឡាយមិនមែនជាអត្តា បញ្ញាក៏ត្រូវអស់ នេះជាចំណែកនៃវិវដ្ដៈ ពោលគឺមគ្គសច្ចនិង និរោធសច្ច ។

ក្នុងបិដកលេខ ៣០, ទំព័រ ១៩ ព្រះនាងសេលាភិក្ខុនីបាន ពោលប្រាប់មារមានចិត្តបាបថា អត្តភាពនេះអត់មានអ្នកណាតាក់-តែងទេ ទីតាំងនៃសេចក្តីទុក្ខនេះ ឥតមានអ្នកណាធ្វើទេ កើតឡើង បានព្រោះអាស្រ័យហេតុ រលត់ទៅវិញព្រោះបែកធ្លាយហេតុ ។ គឺដូចជាពូជណាមួយដែលគេព្រោះក្នុងស្រែ រមែងដុះឡើងបាន ព្រោះអាស្រ័យនូវធម្មជាតិពីរយ៉ាង គឺរសនៃផែនដីមួយ ជ័រនៃគ្រាប់ពូជនោះមួយ យ៉ាងណាមិញ ធម៌ទាំងនេះគឺខន្ធ ធាតុនិងអាយតនៈ ៦ កើតឡើងបានព្រោះអាស្រ័យហេតុ រលត់ទៅវិញព្រោះបែក ធ្លាយនៃហេតុ យ៉ាងនោះឯង ។

បិដកលេខ ៣០, ទំព័រ ២២ ព្រះនាងវជិរាភិក្ខុនី បានពោល ថា ម្នាលមារទិដ្ឋិរបស់អ្នកយល់ថា សត្វមែនឬ នេះជាគំនរនៃ សង្ខារធម៌សុទ្ធ ក្នុងគំនរនៃសង្ខារធម៌សុទ្ធនេះ អ្នករកសត្វមិន ឃើញទេ ។ ព្រោះអាស្រ័យអង្គសម្ភារៈទាំងឡាយមានកង់ ទូក ប្រែកជាដើមចូលគ្នា ទើបមានពាក្យហៅថារថដូច្នេះកើតឡើង



បាន យ៉ាងណាមិញ កាលបើខន្ធគឺកងគំនរនៃរូបធម៌និងនាមធម៌ មានហើយ ការសន្មតថាសត្វដូច្នេះក៏មានដែរ យ៉ាងនោះឯង ។ មានតែទុក្ខទេដែលកើតឡើង មានតែទុក្ខទេដែលតាំងនៅ មានតែ ទុក្ខទេដែលវិនាសប្រែប្រួលទៅ ធម្មជាតិដទៃក្រៅអំពីទុក្ខមិនមាន អ្វីកើត ធម្មជាតិដទៃក្រៅអំពីទុក្ខមិនមានអ្វីរលត់ឡើយ ។

អនត្តាគឺជាសង្ខារធម៌ដែលសូន្យចាកអត្តាតួខ្លួនឯង គ្រាន់ តែជាផលនៃបច្ច័យប៉ុណ្ណោះ ដូចពន្លឺថ្ងៃអាស្រ័យព្រះអាទិត្យ ឬដូច ថ្ងៃបណ្តើរកូន ។ អ្វីៗដែលអាស្រ័យបច្ច័យកើតឡើង មិនដែលមាន ខ្លួនឯងទេ ។ ក្នុងលោកនេះ អ្វីៗទាំងអស់សុទ្ធតែអាស្រ័យបច្ច័យ ទើបកើតឡើងបាន ។

បើសង្ខារធម៌ជាអនត្តាទៅហើយ ចាំបាច់ពោលថ្វីចំពោះ វិសង្ខារធម៌គឺព្រះនិព្វាន ថាជាអត្តានោះ ព្រោះវិសង្ខារគឺព្រះនិព្វាន នៅត្រង់ការអស់បច្ច័យដោយអំណាចអរិយមគ្គ ។

អនត្តាធម៌ ប្រាសចាកម្ចាស់ មិនធ្វើជាតួខ្លួនឱ្យអ្នកណាៗ ឡើយ បើជាសង្ខារធម៌ គឺវាគ្រាន់តែជាក្បួនឬដំណើរនៃធម៌សុទ្ធៗ ប្រព្រឹត្តទៅតាមហេតុ តាមបច្ច័យ ។ អនត្តា គឺមិនមានអ្នកណាជា ម្ចាស់ ឬមិនជារបស់អ្នកណា និង មិនជាតួខ្លួននៃអ្នកណាៗឡើយ។

អនត្តាធម៌ មិនប្រព្រឹត្តទៅក្នុងអំណាច គឺមិននៅក្នុងអំណាចនៃអ្នកណាៗ ពោលគឺគ្មានអ្នកណា មានអំណាចបង្គាប់បញ្ជា ឬទាមទារឱ្យយ៉ាងនេះ យ៉ាងនោះបានឡើយ ។

អ្វីដែលត្រូវកើតរមែងកើត អ្វីដែលត្រូវមានរមែងមាន អ្វីដែលត្រូវរលត់រមែងរលត់ នេះជាលក្ខណៈនៃសង្ខារធម៌ដែលប្រព្រឹត្តទៅតាមបច្ច័យ និង ប្រព្រឹត្តទៅតាមធម្មនិយាមគឺទំនៀមរបស់សង្ខារធម៌ដែលត្រូវរលត់រលាយទៅវិញ ដូចជាផ្លេកបន្ទោរពួដ៏អាកាស ដូច្នោះឯង ។

លក្ខណៈនៃសង្ខារបានជាអារម្មណ៍នៃបញ្ញា រមែងធ្វើឱ្យចិត្តប្រកបដោយបញ្ញានោះ មានសេចក្ដីសុខ ពោលគឺសុខចិត្ត ។

សុខចិត្តជាមួយនឹងការពិតដែលកំពុងមាន កំពុងប្រាកដកំពុងរស់នៅជាបច្ចុប្បន្ន ។

សុខចិត្តដែលមានលំនឹង គឺសុខចិត្តជាមួយនឹងការសិក្សាធម៌ពិត ឃើញថាមិនមានអ្វីដែលមិនពិតនោះទេ ។

ការពិតនៃជីវិត ពោលដោយបរមត្ថគឺអត់មានអ្នកណាធ្វើឱ្យយើងទេ ទាំងដែលយើងក៏មិនបានធ្វើឱ្យខ្លួនឯងដែរ វាជាសេចក្ដីពិតរបស់ជីវិតហ្នឹងតែម្ដង បើមិនឱ្យជីវិតអីចឹងទេ តើឱ្យជីវិតយ៉ាងដូចម្ដេចទៅវិញ ព្រោះជីវិតគឺជាធម៌ដែលប្រព្រឹត្តទៅតាមតែ



បច្ច័យ ។

យើងក៏មិនចង់ឱ្យជីវិតនេះ អត់មានការពិតនោះដែរ ព្រោះការពិតវាជាយុត្តិធម៌សម្រាប់ឱ្យយើងសុខចិត្ត ។ ការពិតនៃជីវិតមិនប្រព្រឹត្តទៅតាមអ្នកណាៗទេ វាត្រឹមត្រូវទៅតាមបច្ច័យគ្រប់គ្រា ។

បដិបត្តិធម៌កំពូលក្នុងព្រះពុទ្ធសាសនានេះ គឺរៀនរស់នៅឱ្យជាសុខជាមួយនឹងធម៌បច្ចុប្បន្ន ទោះជាធម៌បច្ចុប្បន្នហ្នឹងជាអ្វីក៏ដោយ ។

សប្បាយចិត្តព្រោះបានអ្វីៗក្នុងលោកនេះ មិនដូចជាការបានដឹងសេចក្ដីពិតហើយសុខចិត្តនោះឡើយ ព្រោះការសប្បាយចិត្តដោយសារការបានអ្វីៗក្នុងលោក វាជាការពឹងរបស់ខាងក្រៅប្រព្រឹត្តទៅដោយចំណង់តណ្ហា ត្រូវការស្វែងរក មិនរួចពីការខកចិត្ត សោកសៅ ក្ដៅក្រហាយនោះទេ ឯចំណែកសេចក្ដីសុខក្នុងចិត្តព្រោះសិក្សាការពិតវិញ វាជាទីពឹងខ្លួនឯង អប់រំជានិច្ចនូវសតិបញ្ញា មិនថាអារម្មណ៍របស់ចិត្តនោះបែបណា ក៏នៅតែរក្សាចិត្តឱ្យជាសុខដោយខ្លួនឯង មិនពឹងអារម្មណ៍ដែលជារបស់ខាងក្រៅនោះឡើយ ។

ធម៌មានហើយតើ ! គ្រប់អង្គ គ្រប់គ្នា គ្រប់វេលា មានអ្នកណាអត់មានធម៌នោះ ។ ក្ដៅ ញ័រ ចិត្តឃើញ ចិត្តឮ ចិត្តនឹកគិត

សោយសុខ សោយទុក្ខ កង្វល់ក្នុងចិត្ត សោកសៅ ក្តៅក្រហាយ
ចាំរឿង ច្រណែន ។ល។ សុទ្ធតែជាតួធម៌ទាំងអស់ ទៅរកធម៌
ឯណាទៀត តើអ្វីទៅជាធម៌ដែលទៅរកនោះ ។ ចង់រកធម៌ស្ងប់
ចង់ចម្រើនភាវនា ចង់សម្រេចធម៌ពិសេស ចំណង់ទាំងអស់នេះក៏
ជាតួធម៌ស្រេចទៅហើយ ។ ការដែលបានដឹងថា ឥឡូវនេះ ធម៌
មានហើយ ការដឹងនេះជាការរលឹកត្រូវ ឃើញត្រូវជាបញ្ញាចក្ខុ
មិនមានការសង្ស័យក្នុងធម៌បដិបត្តិតទៅទៀត អស់ចំណង់ដែល
ចង់បានធម៌ហើយទៅធ្វើធម៌ ដូច្នេះ ដូច្នោះ ។

មានអ្វីដែលមិនមែនជាធម៌ ធម៌ជាកុសល ធម៌ជាអកុសល
ធម៌ជាអព្យាក្រឹត ។ ធម៌អភិធម្មមិនមែននៅក្នុងគម្ពីរទេ គឺនៅក្នុង
ជីវិតគ្រប់អង្គ គ្រប់គ្នា តួធម៌ប្រាកដតាមពិតព្រោះមានសតិថ្នាក់
សតិប្បដ្ឋាន ។ បដិបត្តិធម៌ មិនមែនរៀបចំបព្វៈនេះ បព្វៈនោះក្នុង
សតិប្បដ្ឋានសូត្រដើម្បីឱ្យសតិរលឹកទេ មិនមែនធ្វើធម៌ សាងធម៌
ចង់បានធម៌អ្វីទាំងអស់ បដិបត្តិធម៌គឺមានសតិរលឹកដឹងដល់តួធម៌
ដែលកំពុងប្រាកដ ឃើញធម៌ដោយបញ្ញាចក្ខុ ជាតួធម៌ពិតៗកំពុង
មាន កំពុងប្រាកដ ទោះជាធម៌អ្វីក៏ជាធម៌ដែរ អត់ត្រូវការធម៌ដទៃ
មកជំនួស គ្រាន់តែមិនមានសេចក្តីប្រកាន់ចំពោះធម៌ជាបច្ចុប្បន្ន
ដែលកំពុងកើតមានប្រាកដនោះថាជាតួខ្លួន ឬថាជារបស់ខ្លួន



ប៉ុណ្ណោះ នេះជានិស្សរណប្បដិបត្តិ គឺបដិបត្តិដោយការរលាស់
ចោល ឬបហានប្បដិបត្តិ គឺបដិបត្តិដោយការលះបង់ ជាការអប់រំ
ចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ។

បដិបទាវិសុទ្ធិ គឺសេចក្តីបរិសុទ្ធក្នុងដំណើរផ្លូវ ជាដំណើរ
ចេញអំពីលោកនេះ បានដល់សតិថ្នាក់សតិប្បដ្ឋាននេះឯង ។ សតិ
ថ្នាក់សតិប្បដ្ឋាន នាំមកនូវវិបស្សនាញាណនិងមគ្គញ្ញាណ ព្រោះ
សតិថ្នាក់សតិប្បដ្ឋាន បានចង្អុលប្រាប់តួធម៌តាមពិតឱ្យបញ្ញាសិក្សា
ឱ្យបញ្ញាមានការចម្រើន ។ បដិបទាវិសុទ្ធិ អត់ត្រូវការធម៌អ្វីដទៃ
ទាំងអស់ ទោះជាកំពុងសោយអារម្មណ៍ជាទុក្ខ ក៏មិនត្រូវការ
សុខវេទនាមកជំនួស ទោះជាកំពុងមានអកុសលចិត្តណាមួយ ក៏
មិនត្រូវការកុសលចិត្តមកជំនួស ព្រោះធម៌ទាំងអស់ប្រាកដ
លក្ខណៈស្មើគ្នាជាសង្ខតធម៌ មិនមានអ្នកណាបានឬមាននូវធម៌
ទាំងអស់នោះឡើយ ។

# ៥. មនុស្សប្រសើរដោយការហ្វឹកហាត់

ព្រះពុទ្ធសាសនា មានលក្ខណៈសំខាន់ម្យ៉ាងទៀតគឺ ដាស់-តឿនឱ្យមនុស្សហ្វឹកហាត់អប់រំ កសាងសមត្ថភាពរបស់ខ្លួន ។

មនុស្សជាសត្វដ៏វិសេសអាចអប់រំបាន សិក្សាបាន នេះជាចំណុចសំខាន់របស់មនុស្ស ។ សង្កត់ន័យបន្ថែមថា មនុស្សទាល់តែហ្វឹកហាត់ទើបបានប្រសើរ គឺប្រសើររហូតដល់ថ្នាក់កំពូល ប្រសើរជាងទេវតា ព្រះឥន្ទ្រ ព្រះព្រហ្មទៅទៀត ប៉ុន្តែបើមនុស្សមិនហ្វឹកហាត់អប់រំទេ ប្រាកដជាអន់ជាងសត្វតិរច្ឆាន គួរឱ្យខ្លាចជាងខ្លាចសត្វព្រៃ ដូច្នេះទើបគោលការណ៍អប់រំមនុស្ស គឺជាកិច្ចសំខាន់បំផុតរបស់ព្រះសម្មាសម្ពុទ្ធ ។

ព្រះពុទ្ធអង្គទ្រង់បានបំពេញកិច្ចដ៏សំខាន់នេះឯង គឺព្រះអង្គទ្រង់ប្រកាសឥស្សរភាពឱ្យដល់មនុស្ស ។ តាំងអំពីមុនការត្រាស់-ដឹងរបស់ព្រះអង្គ មនុស្សនាំគ្នាផ្ញើជីវិត ផ្ញើជោគវាសនារបស់ខ្លួនទៅលើទេវតា ទៅលើព្រហ្ម ដោយយល់ថា ទេវតាឬព្រហ្មជាអ្នកបណ្ដាលជោគជតារាសី ឬថាជាអ្នកចាត់ចែងកំណើតអ្វីៗឱ្យដល់ខ្លួន ម៉្លោះហើយមនុស្សទើបមានការបន់ស្រន់បួងសួង ធ្វើពលិកម្ម



ផ្សេងៗ រហូតដល់ថ្នាក់សម្លាប់សត្វ សម្លាប់មនុស្ស ដើម្បីបូជាដល់ទេវតា សូមឱ្យខ្លួនរួចផុតពីទោសភ័យ គ្រោះថ្នាក់ឧបទ្រពចង្រៃនានា ហើយសូមឱ្យទេវតាប្រទានរង្វាន់ជាលាភជាយសផ្សេងៗដែលខ្លួនត្រូវការទៀតផង ។ ដល់ពេលព្រះអង្គទ្រង់ប្រសូត ព្រះ-អង្គបានប្រកាសឥស្សរភាពរបស់មនុស្ស ដោយព្រះអង្គបានបន្លឺនូវអាសភិវាចា គឺជាវាចាដ៏អង់អាចថា « យើងជាកំពូលនៃលោក យើងជាបុគ្គលប្រសើរជាងគេក្នុងលោក យើងជាចម្បងជាងគេទាំងអស់ក្នុងលោក » នេះគឺវាចាប្រកាសនូវឥស្សរភាពនៃព្រះអង្គ ហើយក៏ជាការប្រកាសជំនួសមនុស្សទាំងឡាយផងដែរ គឺតទៅមនុស្សយើងត្រូវហ្វឹកហាត់ ត្រូវអប់រំ ត្រូវឱ្យចម្រើនទៅដោយចំណេះដឹងនិងគុណធម៌ គឺមនុស្សអាចជួយខ្លួនឯងបាន មនុស្សអាចណែនាំទូន្មានប្រៀនប្រដៅដល់ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្មបានទៀតផង មិនចេះតែអង្វរករទេវតានោះឡើយ ។

មនុស្សដែលស្ថិតនៅក្នុងការហ្វឹកហាត់ គឺត្រូវមានតថាគត-ពោធិសទ្ធា គឺជឿថា ពោធិបានដល់បញ្ញា អាចធ្វើឱ្យមនុស្សបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដូច្នេះបញ្ញាអាចឱ្យសម្រេចបានជាមនុស្សប្រសើរបន្តបន្ទាប់ចុះពីព្រះសម្មាសម្ពុទ្ធមក ជាអនុពុទ្ធ ឬសាវកពុទ្ធ ហ្នឹងឯង ។

លក្ខណៈនៃមនុស្សអ្នកហ្វឹកហាត់អប់រំគឺ ទន់ក្រៅ រឹងក្នុង ។ ទន់ក្រៅ បានដល់ចរិយាការប្រព្រឹត្តរៀបរយ រាបសា ទន់ដោយសេចក្តីគោរពឱនលំទោនសមរម្យ ទន់ដោយការឱ្យទាន ទន់ដោយពាក្យសម្តីពីរោះស្មោះត្រង់ ទន់ដោយជួយក្នុងការងារជាប្រយោជន៍ ទន់ដោយតម្កល់ខ្លួនស្មើគឺមិនវាយឫកចើងម៉ើងឆ្មើងឆ្មៃ និង ទន់ព្រោះមានសីលជានិច្ច ប្រៀបដូចជាផ្កាដែលស្រស់ស្អាតហើយមានក្លិនក្រអូបដូច្នោះឯង ។ រឹងក្នុង បានដល់រឹងដោយគុណធម៌ មាននូវអធិដ្ឋានគុណមាំទាំច្បាស់លាស់ ដូចព្រះបរមពោធិសត្វព្រះអង្គរឹងមាំក្នុងព្រះហឫទ័យ ពេញពោរដោយអធិដ្ឋានធម៌ រហូតដល់បានត្រាស់ជាព្រះសម្មាសម្ពុទ្ធមែនៗ ប្រៀបដូចជាផ្កាយដែលប្រព្រឹត្តទៅនៅតែក្នុងផ្លូវរបស់ខ្លួនដូច្នោះ មិនដូចជាស្លឹកឈើជ្រុះរសាត់តាមខ្យល់បក់នោះឡើយ ។

មនុស្សដែលបានលាភដ៏ប្រសើរបំផុត គឺបានទទួលយកព្រះធម៌ជាឱវាទរបស់ព្រះសម្មាសម្ពុទ្ធមកហ្វឹកហាត់អប់រំ ទូន្មានខ្លួនហ្នឹងឯង ។ ព្រះពុទ្ធបរមគ្រូទ្រង់ប្រកាសសម្តែងប្រាប់នូវការពិតជាសច្ចធម៌នៃជីវិត ជាការពិតក្នុងលោក ចំណែកសត្វលោកដែលជាអ្នកស្តាប់ អ្នករៀនដោយល្អ ក៏បាននូវចំណុចហ្វឹកហាត់ អប់រំបញ្ញាឱ្យចាក់ធ្លុះទៅក្នុងការពិតនោះៗ ជាមួយគ្នានឹងការដែលបាន



ចាក់ធ្លុះក៏លះបង់នូវអវិជ្ជា ។

អ្នកដែលចោទព្រះពុទ្ធសាសនា ចាប់ទោសរឿងនេះ រឿងនោះព្រោះមិនបានវិភាគទៅលើព្រះធម៌ដែលព្រះអង្គទ្រង់សម្តែង។ ព្រះពុទ្ធគ្រប់ព្រះអង្គត្រាស់ដឹង ហើយត្រាស់សម្តែងតែអំពីការពិតប៉ុណ្ណោះ សត្វលោកដែលបានស្តាប់បានទទួលយកឱវាទព្រះធម៌ ក៏មានជីវិតរស់នៅជាមួយនឹងការពិត មិនងងឹតហើយក៏មិនចាញ់បោកលោកនេះដែរ បើដូច្នេះតើខុសត្រង់ណា ?

មានតែការរស់នៅជាមួយនឹងសេចក្តីល្ងង់ប៉ុណ្ណោះ ដែលសត្វលោកប្រព្រឹត្តខុស គិតខុស និយាយខុស ដែលគួរឱ្យរង្កៀសចំពោះការរស់នៅបែបនេះណាស់។ ព្រះពុទ្ធទ្រង់ត្រាស់ថា ព្រហ្មចរិយធម៌នេះប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខ ព្រោះទុក្ខពិត បើមិនដឹងទុក្ខតាមពិតទេ តណ្ហាក៏ស្វែងរកសុខទាំងល្ងង់ខ្លៅ ហើយក៏ធ្លាក់ចូលក្នុងរណ្តៅទុក្ខដដែល មិនរួចផុតចាកជាតិជរាមរណៈឡើយ។ កាលដែលបានកំណត់ដឹងថាអ្វីជាទុក្ខតាមពិតហើយ បញ្ញាក៏បានបំពេញកិច្ចរបស់បញ្ញា ដោយមិនត្រូវមករង្កៀសអ្វីចំពោះកិច្ចនៃបញ្ញា ក្រែងថាចាត់ការខុសយ៉ាងនេះ យ៉ាងនោះឡើយ ។

កាលបើព្រះសម្មាសម្ពុទ្ធ គ្រាន់តែត្រាស់សម្តែងប្រាប់អំពីសភាវធម៌តាមពិត ប្រាប់ថានេះទុក្ខ នេះការរលត់ទុក្ខតាមពិត

ប៉ុណ្ណឹង ដើម្បីឱ្យសត្វលោកបានដឹងហើយមានជីវិតរស់នៅជាមួយនឹងបញ្ញា តើត្រូវចោទប្រកាន់ព្រះពុទ្ធសាសនា ទម្លាក់កំហុសឱ្យយ៉ាងម៉េចទៅ ។

អ្នកដែលដាក់កំហុសឱ្យព្រះពុទ្ធសាសនា ចោទថា ព្រះពុទ្ធសាសនានាំឱ្យមនុស្សក្រ ធ្វើឱ្យប្រទេសមិនជឿនលឿន ឬនាំឱ្យនគររួមតូចជាដើម តើបានសិក្សាព្រះពុទ្ធសាសនាពិតៗហើយឬនៅ ? កុំច្រឡំការប្រព្រឹត្តខុសរបស់បុគ្គលនេះនោះ ថាជាកំហុសនៃព្រះពុទ្ធសាសនាឱ្យសោះ ព្រោះការប្រព្រឹត្តខុសផ្សេងៗនៃបុគ្គលអាស្រ័យកិលេសជាហេតុទេតើ ។

គួរតែជ្រះថ្លាក្រៃលែងចំពោះព្រះពុទ្ធដីកា ព្រោះថា រឿងដែលត្រូវដឹងមានប៉ុនណា ព្រះពុទ្ធញ្ញាណក៏មានប៉ុណ្ណឹងដែរ ព្រះពុទ្ធញ្ញាណមានប៉ុនណា រឿងដែលត្រូវដឹងក៏មានតែប៉ុណ្ណឹងដែរ ប៉ុន្តែ ព្រះពុទ្ធអង្គទ្រង់សម្តែងតែពាក្យពិតហើយមានប្រយោជន៍ប៉ុណ្ណោះ ។ ម្យ៉ាងទៀត ព្រះហឫទ័យបរិសុទ្ធមិនមានអ្វីដែលធ្វើឱ្យព្រះអង្គត្រាស់ណែនាំខុសនោះទេ ទាំងព្រះមហាករុណាគុណប្រមាណមិនបានថែមទៀត ។

ជាធម្មតារបស់សត្វលោក តែងមានការខ្វះខាត ទាំងចំណេះដឹងទាំងគុណធម៌ អ្នកដែលចោទប្រកាន់ព្រះពុទ្ធសាសនា



ចាប់កំហុសរឿងនេះរឿងនោះ ក៏ដូចគ្នា សុទ្ធតែស្ថិតនៅក្នុងចំណោមអ្នកខ្វះខាតហ្នឹងឯង ។ ក្នុងកាលដែលព្រះអង្គគង់ព្រះជន្មនៅឡើយ ក៏មានច្រើនដែរចំពោះអ្នកពោលចាប់កំហុសព្រះពុទ្ធអង្គផ្ទាល់ព្រះភក្ត្រ ប៉ុន្តែត្រូវបានទទួលយកនូវភាពភ្លឺស្វាងត្រឡប់មកវិញ តាមរយៈនៃព្រះពុទ្ធគុណព្រមដោយព្រះធម៌ទេសនារបស់ព្រះអង្គ ខ្លះក៏បានចូលកាន់ផ្នួសភ្លាមៗ សម្រេចដល់ទីបំផុតនៃការហ្វឹកហាត់ គឺការអស់កង្វល់ ខ្លះបានកាន់យកឧបនិស្ស័យនៃការហ្វឹកហាត់មកសម្រេចដល់ការអស់កិលេស ក្នុងសម័យកាលនៃព្រះបាទធម្មាសោកជាដើម ។

ក្នុងសម័យកាលនេះ បើមិនបានអានព្រះត្រៃបិដកទេ តើមកវាយតម្លៃព្រះពុទ្ធសាសនាដូចម្តេចទៅ ? ហើយបើមិនមានការសិក្សាបដិបត្តិទេ ស្រាប់តែមកគិតថាបានស្គាល់ព្រះពុទ្ធសាសនាច្បាស់ បានស្គាល់ព្រះសម្មាសម្ពុទ្ធច្បាស់ នេះជាការគិតខុសហើយ។

អ្នកដែលស្គាល់ព្រះសម្មាសម្ពុទ្ធច្បាស់គ្រាន់បើ[១] គឺអ្នកដែលបានឃើញធម៌ពិត ព្រោះធម៌ពិតជាទីតាំងនៃបញ្ញាត្រាស់ដឹង ដូច្នេះកាលដែលបានឃើញធម៌ពិត ទើបដឹងថាព្រះពុទ្ធទ្រង់ជាបុគ្គលត្រាស់ដឹងមែន ។

---

១-គឺក្រៅពីព្រះសម្មាសម្ពុទ្ធអត់មានបុគ្គលណាជ្រាបគុណព្រះសម្មាសម្ពុទ្ធសព្វគ្រប់ឡើយ។

ព្រះពុទ្ធសាសនា អប់រំគំនិតមនុស្ស ជាប្រយោជន៍ឱ្យគំនិតផលិតសេចក្ដីសុខផ្ដល់ឱ្យជីវិត ដោយមិនចាំបាច់ទាល់តែមានអ្វីៗជាខាងក្រៅច្រើននោះឡើយ ។ មនុស្សយើងច្រើនណាស់ ដែលខំចំណាយពេលរាល់ថ្ងៃដើម្បីស្វែងរកសេចក្ដីសុខ តាមរយៈទ្រព្យសម្បត្តិ មុខមាត់កិត្តិយស ប៉ុន្តែគួរឱ្យស្ដាយត្រង់ដែលមិនបានអប់រំចិត្តគំនិត បែរជាមកអង្គុយគិតឱ្យកើតទុក្ខក្នុងរឿងផ្សេងៗ ដូចជាគិតច្រណែននឹងគេ គិតស្អប់ គិតខឹងជាដើម ឬគិតភ័យព្រួយយ៉ាងនេះ យ៉ាងនោះ គឺវាជាគំនិតដែលសម្រាប់សាងតែសេចក្ដីទុក្ខឱ្យខ្លួនឯង ។ គិតឱ្យទុក្ខបានទុក្ខ គិតឱ្យសុខបានសុខ ដូច្នេះគំនិតពិតជាសំខាន់សម្រាប់ជីវិតខ្លួនឯងណាស់ ការអប់រំហ្វឹកហាត់ចិត្តគំនិតឱ្យចេះគិតត្រូវតាមព្រះធម៌ អាចនាំមកនូវលោកុត្តរសុខបានទៀតផង ។



# ៦. សត្វលោកប្រព្រឹត្តទៅតាមកម្ម

នៅក្នុងព្រះពុទ្ធសាសនា មានការសម្ដែងអំពីដំណើរជីវិតនៃសត្វលោកទាក់ទងនឹងអំពើកម្មដែលខ្លួនឯងបានធ្វើមក បើពោលដោយបរមត្ថគឺបដិច្ចសមុប្បាទធម៌ហ្នឹងឯង ។

កម្មដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែង ម្យ៉ាងគឺដើម្បីមិនឱ្យបែងចែកមនុស្សដោយជាតិកំណើត ត្រូវបែងចែកដោយការប្រព្រឹត្តក្នុងបច្ចុប្បន្នហ្នឹងឯង ។ ក្នុងបិដកលេខ ២៥,ទំព័រ ២២២ ព្រះអង្គទ្រង់ត្រាស់ថា មនុស្សថោកទាបមិនមែនព្រោះជាតិកំណើតទេ ទាំងដែលជាព្រាហ្មណ៍ក៏មិនមែនព្រោះជាតិកំណើតដែរ ។ មនុស្សថោកទាបព្រោះកម្មគឺការងារដែលធ្វើក្នុងបច្ចុប្បន្ន ទាំងដែលជាព្រាហ្មណ៍ក៏ព្រោះកម្មដែរ ។ ជាអ្នកស្រែក៏ព្រោះកម្ម ជាអ្នកសិល្បៈក៏ព្រោះកម្ម ជាពាណិជក៏ព្រោះកម្ម ជាអ្នកបម្រើគេក៏ព្រោះកម្ម ជាចោរក៏ព្រោះកម្ម ជាទាហានក៏ព្រោះកម្ម ជាអ្នកបូជាក៏ព្រោះកម្ម ... ។ អ្នកប្រាជ្ញទាំងឡាយ បានឃើញច្បាស់នូវធម៌ដែលអាស្រ័យបច្ច័យកើតឡើង ជាអ្នកឆ្លាតឈ្លាសក្នុងវិបាករបស់កម្ម រមែងឃើញកម្មតាមសេចក្ដីពិតយ៉ាងនេះថា សត្វលោកតែង

ប្រព្រឹត្តទៅតាមកម្ម ពពួកជនតែងប្រព្រឹត្តទៅតាមកម្ម សត្វទាំងឡាយដែលជាប់នៅក្នុងកម្មទើបប្រព្រឹត្តទៅបាន ដូចជារទេះដែលមានភ្លៅទើបបរទៅបាន យ៉ាងនោះឯង ។

នៅក្នុងព្រះពុទ្ធសាសនា បានសម្តែងរំលឹកដាស់តឿនឱ្យមនុស្សធ្វើការងារ ដូចជានៅក្នុងប្រយោជន៍បច្ចុប្បន្នព្រះអង្គត្រាស់ថា ឧដ្ឋានសម្បទា ប្រែថា ដល់ព្រមដោយការប្រឹងប្រែងធ្វើការងារដែលប្រាសចាកទោស ។ មនុស្សសាងការងារ ការងាររមែងសាងមនុស្ស ។ មនុស្សរក្សាធម៌ ធម៌រមែងរក្សាមនុស្ស ។ តើមានទេវតាព្រះឥន្ទ ព្រះព្រហ្មណាមករៀបចំជីវិតមនុស្សឱ្យជាក់ស្តែងដូចជាអំពើកម្មដែលខ្លួនឯងបានធ្វើ ។ មនុស្សនរក មនុស្សប្រេត មនុស្សតិរច្ឆាន អាស្រ័យកម្មបច្ចុប្បន្ន ព្រះអង្គត្រាស់សម្តែងឱ្យវៀរចាកអបាយមុខគ្រប់យ៉ាង ស្រីស្រាល្បែង សេពគប់បាបមិត្ត ទាំងខ្ជិលផង ព្រោះអបាយមុខធ្វើឱ្យមនុស្សដល់នូវសេចក្តីវិនាស ។ ចំណែកមនុស្សទេវតា ដោយសារមានសទ្ធា សីល សុតៈ ចាគៈ និង បញ្ញា រីឯមនុស្សព្រហ្ម ព្រោះមានព្រហ្មវិហារធម៌ មិនត្រឹមតែមានមនុស្សទេវតា មនុស្សព្រហ្មប៉ុណ្ណោះទេ សូម្បីមនុស្សបរិសុទ្ធបានដល់ព្រះអរហន្តក៏មានដែរ ។

ម្យ៉ាងទៀត នៅក្នុងព្រះពុទ្ធសាសនាដែលសម្តែងអំពីកម្ម



ធ្វើឱ្យមនុស្សចេះទទួលខុសត្រូវចំពោះខ្លួនឯង ពីព្រោះជីវិតនេះមានមួយផ្នែកធំជាផលវិបាករបស់កម្ម ។

មិនមែនទុក្ខព្រួយក្នុងចិត្តជាផលវិបាកនៃបាបកម្មនោះទេ សោកសៅក្តៅក្រហាយ ភ័យខ្លាចទុក្ខព្រួយ គឺជាតួអកុសលចិត្តសុទ្ធៗតែម្តង ដែលកើតឡើងអាស្រ័យតួតណ្ហាឧបាទានជាបច្ច័យ ចំណែកឯការសប្បាយចិត្តចំពោះរឿងអ្វីមួយ ក៏មិនមែនជាតួវិបាកនៃកុសលកម្មអ្វីនោះដែរ ការសប្បាយចិត្តនេះជាតួលោភៈដែលមានលក្ខណៈត្រេកអរជាប់ជំពាក់ ឬជាតួកុសលចិត្តដែលរីករាយក្នុងការធ្វើល្អ មានចេតនាស្រស់ថ្លា ។

មនុស្សយើងអាចមានការយល់ច្រឡំចំពោះសុខ ឬទុក្ខក្នុងចិត្តថាជាផលវិបាករបស់កម្មចាស់ ការយល់ច្រឡំដូច្នេះ វាជាគ្រឿងរារាំងដល់ការបដិបត្តិកម្ចាត់អកុសលក្នុងចិត្ត ឬរារាំងដល់ការបដិបត្តិចម្រើននូវកុសលធម៌ ។ តាមពិត សេចក្តីទុក្ខក្នុងចិត្តជាអកុសលធម៌ត្រូវលះបង់ដោយសតិសម្បជញ្ញៈ សេចក្តីសុខដោយលោភៈក៏ត្រូវលះបង់ដោយសតិសម្បជញ្ញៈដែរ រីឯសេចក្តីសុខជាកុសលវិញ គួរដល់ការអប់រំចម្រើនដោយសតិសម្បជញ្ញៈ រហូតដល់លោកុត្តរកុសល ។

សតិសម្បជញ្ញៈមានឧបការគុណដ៏ក្រៃលែង ចាត់ការរៀបចំ

និងដោះស្រាយចំពោះអ្វីៗក្នុងជីវិតនេះ ឱ្យប្រព្រឹត្តទៅបានត្រឹមត្រូវសព្វគ្រប់ ។ សតិសម្បជញ្ញៈ មានយោនិសោមនសិការជាអាហារ យោនិសោមនសិការមានសទ្ធាជាអាហារ សទ្ធាមានការស្តាប់នូវព្រះសទ្ធម្មជាអាហារ ឯការស្តាប់ព្រះសទ្ធម្មទៅបានអាស្រ័យការសេពគប់សប្បុរសជាអាហារ[១] ។

កាលបើមិនមានសតិសម្បជញ្ញៈទេ ក៏មិនមានអ្វីនាំឱ្យមានការសង្រួមឥន្ទ្រិយដែរ ការមិនសង្រួមឥន្ទ្រិយ នាំឱ្យមានទុច្ចរិត ៣ យ៉ាង ទុច្ចរិត ៣ យ៉ាងនាំឱ្យមាននីវរណធម៌ ៥ ពេញបរិបូណ៌ នីវរណធម៌ ៥ ពេញបរិបូណ៌នាំឱ្យមានអវិជ្ជាពេញបរិបូណ៌ អវិជ្ជាពេញបរិបូណ៌នាំឱ្យមានភវតណ្ហាពេញបរិបូណ៌ ។

ក្នុងបិដកលេខ ២៦, មានព្រះសូត្រខាងដើមឈ្មោះ ទេវ-ទហសូត្រ ដោយក្នុងកាលនោះ ព្រះដ៏មានព្រះភាគទ្រង់គង់នៅទេវទហនិគមរបស់ពួកសក្យៈក្នុងដែនសក្កៈ ។ ក្នុងព្រះសូត្រដ៏វែង ៥០ ទំព័រ ព្រះអង្គទ្រង់ប្រារព្ធការយល់ខុសរបស់ពួកនិគ្រន្ថ ដែលយល់ថា ការសោយអារម្មណ៍ឯណានីមួយ ជាសុខក្តី ជាទុក្ខក្តី មិនសុខមិនទុក្ខក្តី សុទ្ធតែអាស្រ័យកម្មចាស់ទាំងអស់ ។ មិច្ឆាទិដ្ឋិ

១. អាហារ = បច្ច័យដែលនាំមកនូវផលនោះៗ ។ អាហារនៃធម៌ទាំងនោះនៅក្នុងបិដក លេខ ៥០, ទំព័រ ២៤៦-២៦១ ។



នេះហៅថាបុព្វេកតវាទ ។ ពួកនិគ្រន្ថនាំគ្នាបដិបត្តិធ្វើខ្លួនឱ្យទុក្ខលំបាកដ៏ក្រៃលែង ដោយយល់ថាធ្វើដូច្នេះទើបអស់ទៅនៃកម្មចាស់នោះ ។ នៅក្នុងព្រះសូត្រនេះ ព្រះដ៏មានព្រះភាគទ្រង់បានសម្តែងអំពីសេចក្តីព្យាយាមដ៏ត្រឹមត្រូវនៃពួកភិក្ខុក្នុងសាសនា គឺមិនទៅធ្វើខ្លួនឱ្យទុក្ខលំបាក ដោយស្វែងរកយកទុក្ខមកគ្របសង្កត់ខ្លួនឥតប្រយោជន៍ឡើយ មិនលះបង់នូវសេចក្តីសុខដែលប្រកបដោយធម៌ គ្រាន់តែពិចារណាប្រើប្រាស់បច្ច័យ ៤ ដោយមិនជ្រុលជ្រប់ចំពោះសេចក្តីសុខនោះៗ ហើយអកុសលធម៌ក៏សាបសូន្យទៅ កុសលធម៌ក៏ចម្រើនឡើង គឺភិក្ខុបដិបត្តិកម្ចាត់តណ្ហាដែលជាហេតុនៃទុក្ខ ។

សុខទុក្ខក្នុងជីវិតសត្វលោក មិនមែនសុទ្ធតែជាផលវិបាករបស់កម្មចាស់នោះទេ ជាកុសល ជាអកុសល ជាកិរិយា សុទ្ធតែមានវេទនាប្រកបជាមួយតាមសមគួរទាំងអស់ ។ អកុសលវិបាកខ្លះមិនមានអ្វីធ្ងន់ធ្ងរទេ បើមិនប្រកបដោយទុក្ខទោមនស្សតាមផ្លូវចិត្តទេនោះ បដិបត្តិធម៌ប្រព្រឹត្តទៅដោយធម៌សន្តោស ដោយសេចក្តីអត់ធន់ ព្យាយាម មានសតិសម្បជញ្ញៈ មានបញ្ញាកំណត់ដឹងការពិត ជាសុខក្នុងចិត្ត ជីវិតសប្បាយៗ ។

អកុសលវិបាកកាយវិញ្ញាណ ទើបប្រកបដោយទុក្ខវេទនា ហៅថា ទុក្ខផ្លូវកាយ សូម្បីទុក្ខផ្លូវកាយក៏ជាទីតាំងនៃសតិប្បដ្ឋាន

វិបស្សនា  អង្គខ្លះបានសម្រេចព្រះអរហត្តផលក្នុងពេលកំពុងទុក្ខវេទនាខ្លាំងក្លា ហើយក៏បរិនិព្វានទៅ ។

ដូច្នេះ សូមពុទ្ធបរិស័ទយល់អំពីកម្មចាស់ឱ្យបានច្បាស់លាស់ត្រឹមត្រូវ  កុំចេះតែផ្តេកផ្តួលទៅលើកម្មចាស់  ទាល់ច្រករអ្វីរទាំអស់សង្ឃឹមនោះឡើយ  ត្រូវប្រយ័ត្នគំនិត  កុំឱ្យធ្លាក់ចូលក្នុងលទ្ធិរបស់ពួកនិគ្រន្ថដោយមិនដឹងខ្លួន ។

ដែលថាព្រះពុទ្ធសាសនាសម្តែងអំពីកម្ម  ធ្វើឱ្យមនុស្សចេះទទួលខុសត្រូវចំពោះខ្លួនឯង  ព្រោះក្នុងជីវិតមនុស្សយើងម្នាក់ៗមានការពិតជាបរមត្ថ  អ្វីជាផលវិបាករបស់កម្ម  កាលដែលកើតឡើងគឺត្រូវតែកើតតាមកម្មជាបច្ច័យ ។ ដែលថាឱ្យចេះទទួលខុសត្រូវចំពោះខ្លួនឯងនេះ  គ្រាន់តែជាវោហារឱ្យចេះសិក្សាការពិតតែប៉ុណ្ណោះ កុំឱ្យយល់ខុសថាអ្នកដទៃធ្វើកម្ម ខ្លួនយើងទទួលផលកម្ម។ ជីវិតម្នាក់ៗ មានហេតុ មានផលរៀងៗខ្លួន អ្វីដែលកើតគឺរមែងកើត អ្វីដែលមានគឺរមែងមាន ជីវិតនេះបើមិនមានផលវិបាករបស់កម្មទេ តើមានអ្វីដែលជាតួបដិសន្ធិទៀតទៅ ។ កម្មឱ្យមានបដិសន្ធិហើយឱ្យកើតភវង្គតៗ ឱ្យមានវិបាកក្នុងទ្វារ ៦ រួចហើយកម្មជាបច្ច័យឱ្យចុតិទៀត មិនមែនចេះតែស្លាប់ឯងៗ ឬអ្នកណាចេះតែមកឱ្យស្លាប់នោះទេ ចំណែករូបកាយដែលនៅរស់នេះ មានមួយផ្នែកធំ



សុទ្ធតែជាកម្មជរូបគឺរូបដែលកើតអំពីកម្ម ។

ពិតមែនតែមនុស្សបដិសន្ធិដោយកុសលវិបាក  ប៉ុន្តែនៅក្នុងបវត្តិកាលក៏មានអកុសលវិបាកផងដែរ ។ បើការពិតក្នុងជីវិតយ៉ាងនេះ យើងមិនទទួលការពិតយ៉ាងម៉េច ត្រូវទៅក្តៅក្រហាយជាមួយនឹងអ្នកណា  វាដូចជាយើងដើរទាត់កន្ទោរអ៊ីចឹង  ចេះទៅបន្ទោសកូនចៅថាទុកកន្ទោរផ្តេសផ្តាស  ត្រង់ដែលខ្លួនយើងអ្នកដើរមិនមើល មិនគិតថាផ្តេសផ្តាសឡើយ ។

ទោះជាវោហារប្រាប់ថា  ឱ្យចេះទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានធ្វើក៏ដោយ  ប៉ុន្តែមិនមែនដល់ថ្នាក់ត្រូវក្តៅក្រហាយនឹងអំពើកម្មដែលឆ្គាំឆ្គងកន្លងហួសហើយនោះៗទេ  ត្រូវសិក្សាការពិតឱ្យគំនិតចូលក្នុងផ្លូវកណ្តាល  ឱ្យមានការយល់ត្រូវថា  កម្មកើតអំពីហេតុរបស់កម្ម  អ្នកធ្វើកម្មមិនមានទេ  ផលវិបាករបស់កម្មរមែងកើតអំពីកម្ម អត់មានអ្នកណាជាមនុស្ស ឬជាទេវតា មកជាអ្នកទទួលផលវិបាកនៃកម្មឡើយ  យ៉ាងនេះទើបឈ្មោះថា  ជាអ្នកទទួលខុសត្រូវចំពោះខ្លួនឯងដោយមិនលម្អៀង  និងមិនមានការយល់ខុស ។

ប្រការមួយទៀត  ព្រះពុទ្ធសាសនាសម្តែងអំពីកម្មដើម្បីឱ្យចេះពឹងខ្លួនឯង  មិនចេះតែពឹងអ្វីៗជាខាងក្រៅ  បន់ស្រន់បួងសួង

អង្វរករសូមពរពីទេវតានោះៗឡើយ ។ សេចក្តីពិតនៃជីវិតសុទ្ធតែជាធម៌ហេតុផល សេចក្តីសម្រេចកើតអំពីការធ្វើ ការអប់រំ រហូតដល់ការសម្រេចនោះ បានជាព្រះសម្មាសម្ពុទ្ធទៀតផង ។

មនុស្សយើងបានរស់ហើយគួរតែចេះស្កប់ស្កល់ ព្រោះសេចក្តីសុខពិតប្រាកដមិនមែននៅក្នុងលោកនេះទេ តណ្ហាជាហេតុនៃសេចក្តីទុក្ខ គួរបែរមករកសេចក្តីសុខដោយការអប់រំចិត្តបំពេញបុណ្យកុសលឱ្យជាទីនឹករលឹករីករាយ អប់រំបញ្ញារស់នៅជាសុខជាមួយនឹងការពិត ។ រស់នៅជាមួយញាតិមិត្តនិងអ្នកដទៃមានសេចក្តីសុខព្រោះច្រើនដោយមេត្តា រស់នៅម្នាក់ឯងមានសេចក្តីសុខជាមួយនឹងវិវេកធម៌ ឃើញអនិច្ចលក្ខណៈចំពោះសង្ខារ ការអស់ទៅនៃតណ្ហាឈ្នះអស់នូវទុក្ខទាំងពួង ។ សេចក្តីសុខពិតប្រាកដមិនមាននៅក្នុងលោកនេះទេ ប៉ុន្តែការអស់ទៅនៃតណ្ហាជាការអស់ទៅនៃទុក្ខទាំងពួង នុ៎ះឯងជាសន្តិបទ ។

សរុបអត្ថន័យទ្រឹស្តីកម្មផលមាន ៣ ប្រការដូចដែលបានរៀបរាប់មកហើយ :

១- កម្មបែងចែកមនុស្សឱ្យថោកទាប ឬខ្ពង់ខ្ពស់ តាមតែអំពើជាក់ស្តែងក្នុងបច្ចុប្បន្ន មិនគប្បីប្រកាន់វណ្ណៈឡើយ ។

២- គប្បីទទួលខុសត្រូវទៅតាមសេចក្តីពិត ព្រោះក្នុងជីវិត



ម្នាក់ៗ មានផលវិបាករបស់កម្មរៀងៗខ្លួន ឃើញបដិច្ចសមុប្បាទ-ធម៌ប្រព្រឹត្តទៅជាវដ្តៈ ៣ គឺកិលេសវដ្តៈ ១, កម្មវដ្តៈ ១ និង វិបាក-វដ្តៈ ១ មិនគប្បីទម្លាក់ទោសដាក់អ្នកដទៃ ហើយខឹងស្អប់គុំកួនទៅនោះទេ ។

៣- ឱ្យចេះជួយខ្លួនឯងតាមការប្រព្រឹត្តកុសលកម្ម រហូតដល់កំណត់ដឹងបញ្ចក្ខន្ធឃើញធម៌តាមពិត អត់មានខ្លួនឯងជាអត្តាសម្រាប់ឱ្យទេវតាឬព្រះជាម្ចាស់ជួយឡើយ ។ ធ្វើជាមនុស្សមិនត្រូវទន់ខ្សោយ ចេះតែបន់ស្រន់មេឃដីនោះទេ ។

ចំណុចដែលគួរចងចាំនូវលក្ខណៈនៃព្រះពុទ្ធសាសនា ដែលសម្តែងអំពីកម្ម គឺកិច្ចការណាដែលធ្វើទៅហើយនាំឱ្យកុសលធម៌ចម្រើនឡើង អកុសលធម៌សាបសូន្យទៅ គ្រប់កិច្ចការទាំងអស់នោះគឺតាំងនៅក្នុងឱវាទនៃព្រះសម្មាសម្ពុទ្ធ ដូចក្នុងសក្កប្បញ្ហសូត្រ បិដកលេខ ១៧ ចាប់ពីទំព័រ ២១៨ រហូតដល់សក្កទេវរាជបានសម្រេចសោតាបត្តិផលហើយត្រាស់សួរបញ្ហាបន្តទៀត ។

# ៧- បញ្ញាជាកំពូលធម៌

ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់ថា តាំងអំពីដើមមកក្តី ឥឡូវនេះក្តី តថាគតសម្តែងតែអំពីទុក្ខនិងការរលត់ទុក្ខប៉ុណ្ណោះ[១] ។ នេះជាការសម្តែងបញ្ជាក់ឱ្យឃើញដល់គុណធម៌កំពូលខ្ពស់បំផុត នៅក្នុងព្រះពុទ្ធសាសនាគឺបញ្ញា ព្រោះការដែលបានចាក់ធ្លុះ ត្រាស់ដឹងនូវអរិយសច្ចធម៌ ជាតួបញ្ញា ។

ក្នុងបិដកលេខ ៥០, ទំព័រ ២៣២ ព្រះអង្គទ្រង់ត្រាស់ថា ធម៌ទាំងឡាយទាំងពួងមានបញ្ញាជាធម៌ប្រសើរខ្ពង់ខ្ពស់ (បញ្ញុត្តរា សព្វេ ធម្មា) ។ ក្នុងការដែលពិនិត្យមើលលក្ខណៈនៃព្រះពុទ្ធ-សាសនា តើមានអ្វីជាគោលការណ៍បដិបត្តិខ្ពស់បំផុតនិងកាន់យកនូវប្រយោជន៍ជាទីបំផុតនោះ យើងនឹងបានឃើញដល់តួបញ្ញា ដែលជាការត្រាស់ដឹងចាក់ធ្លុះនូវអរិយសច្ចទាំង ៤ ហ្នឹងឯង ។

ក្នុងលទ្ធិសាសនាដទៃខ្លះយកការជឿជាគោលបដិបត្តិ មិនចាំបាច់សង្ស័យ មិនចាំបាច់សួរ យើងថាអ្វីៗនៅលើព្រះជាម្ចាស់ នៅលើទេវតា អ្នកទាំងឡាយជឿទៅ និងយកជាទីពឹងទៅ មិនត្រូវ

១- បិដកលេខ ២១, ទំព័រ ៦២ និង អដ្ឋកថា ។



ពឹងខ្លួនឯងទេ ... ។

ក្នុងលទ្ធិសាសនាដទៃខ្លះទៀតយកត្រឹមការប្រព្រឹត្តសីលនិងវត្តជាគោលបដិបត្តិ ជាលទ្ធិ ជាសាសនា គឺគេយល់ថាសីលនិងវត្តប្បដិបត្តិនេះ នឹងនាំឱ្យបានទៅដល់សេចក្តីបរិសុទ្ធ ផុតទុក្ខផុតភ័យ ដូចជាសីលនិងវត្តរបស់ពួកនិគ្រន្ថជាដើម ប៉ុន្តែចំណុចនេះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថាសីលព្វតបរាមាសៈ ។

ក្នុងលទ្ធិសាសនាមួយទៀត យកសមាធិជាគោលការណ៍ខ្ពស់បំផុត ដែលគេយល់ថានឹងបានដល់នូវភាពទៀងដ៏ខ្ពង់ខ្ពស់ ខ្លួនរបស់គេនឹងចូលទៅក្នុងបរមាត្មន ... ។

នៅក្នុងព្រះពុទ្ធសាសនា ព្រះអង្គទ្រង់ត្រាស់ធម៌ជាឧបការដល់បញ្ញា មានសទ្ធា មានសីល មានវីរិយៈ មានសមាធិជាដើម ដែលធម៌ទាំងនេះទីបំផុតត្រូវគ្រប់គ្រងដោយបញ្ញា សហការគ្នាកម្ចាត់បង់នូវកិលេស ។ ធម៌ជាឧបការមានដូចជា :

ក្នុងបិដកលេខ ៥២, ព្រះធម្មបទ ពុទ្ធវគ្គ ទំព័រ ៦១ ព្រះអង្គទ្រង់ត្រាស់ក្នុងធម៌ **ពហុំ វេ សរណំ យន្តិ** ក្នុងគាថាខាងចុងមានសេចក្តីថា លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹក ហើយឃើញនូវអរិយសច្ចទាំង ៤ ដោយបញ្ញាដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម ... បុគ្គលនោះរមែងរួចចាកទុក្ខ

ទាំងពួងបាន ។ នេះជាការសម្ដែងឱ្យឃើញថា សទ្ធាមានឧបការៈដល់បញ្ញា ដែលជាបញ្ញាទម្លាយកិលេស ។

នៅក្នុងអដ្ឋកថា សល្លេខសូត្រ[១] សម្ដែងអំពីបាទរបស់វិបស្សនាដូច្នេះថា តាមពិត សមាបត្តិ ៨ នៃបុគ្គលក្រៅព្រះពុទ្ធ-សាសនា គឺជាបាទរបស់វដ្តៈតែប៉ុណ្ណោះ ឯចំណែកនៅក្នុងព្រះ-ពុទ្ធសាសនាវិញ សូម្បីតែសរណគមន៍ ក៏គប្បីជ្រាបថា ជាបាទនៃលោកុត្តរធម៌បាន ។ ទានដែលបុគ្គលឱ្យដល់អ្នកមានត្រៃសរណ-គមន៍ក្នុងព្រះពុទ្ធសាសនា មានផលច្រើនជាងទានដែលឱ្យដល់បុគ្គលក្រៅព្រះពុទ្ធសាសនាដែលបានសមាបត្តិ ៨ អភិញ្ញា ៥ ព្រោះថា នៅក្នុងទក្ខិណាវិភង្គសូត្រ[២] ព្រះដ៏មានព្រះភាគទ្រង់សំដៅយកសេចក្ដីនេះ ទើបព្រះអង្គត្រាស់ថា ទក្ខិណាដែលមានផលគុណដោយសែនកោដិដែលទាយកគប្បីបាន ព្រោះឱ្យទានដល់បុគ្គលក្រៅព្រះពុទ្ធសាសនា ជាអ្នកប្រាសចាកសេចក្ដីត្រេកអរក្នុងកាមទាំងឡាយ ប៉ុន្តែទក្ខិណាមានផលរាប់មិនបានប្រមាណមិនអស់ដែលទាយកគប្បីបាន ព្រោះឱ្យទានដល់អ្នកបដិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ។ តាមពិត អ្នកបដិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ក្នុងទក្ខិណាវិភង្គសូត្រនោះ ព្រះអង្គទ្រង់

១. សល្លេខសូត្រនៅក្នុងបិដកលេខ ២០ ។ ២. នៅក្នុងបិដកលេខ ២៨ ។



សំដៅយកចាប់តាំងអំពីការដល់ព្រះត្រៃសរណគមន៍ជាដើមទៅ ។

ចំណែកសីលដែលមានឧបការៈដល់ការចម្រើនបញ្ញា នៅក្នុងបិដកលេខ ៣៨, ទំព័រ ៦៤ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧត្តិយៈ កាលបើអ្នកនឹងមានសីលស្អាតល្អ មានទិដ្ឋិត្រង់ល្អ ហើយ ម្នាលឧត្តិយៈ លំដាប់អំពីនោះទៅ អ្នកត្រូវអាស្រ័យសីល តម្កល់នៅក្នុងសីល ហើយចម្រើននូវសតិប្បដ្ឋាន ៤ ចុះ ។ នៅក្នុងទំព័រ ៧៨[១] ព្រះអានន្ទបានសម្ដែងថា ម្នាលភទ្ទៈដ៏មានអាយុ សីលជាកុសលទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងហើយ សីលជាកុសលទាំងនោះ ព្រះអង្គទ្រង់ត្រាស់កំណត់ដើម្បីចម្រើននូវសតិប្បដ្ឋាន ៤ ។

ចំណែកសមាធិមានឧបការៈដល់ការអប់រំបញ្ញា ព្រះអង្គត្រាស់ថា[២] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចម្រើនសមាធិ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានចិត្តតម្កល់នឹង រមែងដឹងច្បាស់តាមសេចក្ដីពិត ។ ចុះដឹងច្បាស់នូវអ្វីតាមសេចក្ដីពិត ។ ដឹងច្បាស់តាមសេចក្ដីពិតថានេះជាទុក្ខ នេះជាហេតុជាទីកើតឡើងនៃទុក្ខ នេះជាទីរំលត់ទុក្ខ នេះជាបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរធ្វើ

១. បិដកលេខ ៣៨ ដដែល ។ ២. បិដកលេខ ៣៩, ទំព័រ ២២៦ ។

សេចក្ដីព្យាយាមថា នេះជាទុក្ខ គួរធ្វើសេចក្ដីព្យាយាមថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ គួរធ្វើសេចក្ដីព្យាយាមថា នេះជាទីរំលត់ទុក្ខ គួរធ្វើសេចក្ដីព្យាយាមថា នេះជាបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។

បុគ្គលមានត្រឹមតែសទ្ធាឬជំនឿ គឺនៅមានការឃ្លេងឃ្លោងងាករេរជានិច្ច មកអំពីមិនទាន់បានឃើញច្បាស់ដោយបញ្ញានូវអ្វីៗដែលខ្លួនឯងបានជឿនោះ ព្រោះហេតុដូច្នោះ ទើបនៅក្នុងព្រះពុទ្ធសាសនានេះ មានកិច្ចដែលត្រូវជួយរក្សាសទ្ធាគ្នា ឬជួយអ្នកដែលមិនទាន់មានសទ្ធាឱ្យមានសទ្ធាឡើង តាមរយៈបដិបត្តិក្នុងព្រះវិន័យនិងការសម្ដែងធម៌ជាដើម ។ ព្រះវក្កលិមានសទ្ធាខ្លាំងក្លាចំពោះព្រះពុទ្ធអង្គ ប៉ុន្តែនៅមិនទាន់ជួយខ្លួនឯងរួចបាន គឺទាល់តែបានឃើញធម៌ដោយបញ្ញាដ៏ប្រពៃ ទើបអស់ការញាប់ញ័រឃ្លេង-ឃ្លោង ។ អ្នកដែលចោលព្រះពុទ្ធសាសនាទៅចូលកាន់សាសនាដទៃ ព្រោះក្នុងពេលដែលកាន់ព្រះពុទ្ធសាសនានោះ មានតែសទ្ធាអាស្រ័យបច្ច័យខាងក្រៅផ្សេងៗ ដោយខ្វះបញ្ញាឃើញធម៌ដែលជាបច្ច័យខាងក្នុងដ៏រឹងមាំ ។ ដូចដែលព្រះពុទ្ធអង្គត្រាស់ថា បុគ្គលឆ្លងអន្លង់បានដោយសទ្ធា[១] ក៏គឺសទ្ធាប្រកបដោយសោតាបត្តិមគ្គ[២]

១. បិដកលេខ ៥៤,ទំព័រ ៦២ ។ ២. អដ្ឋកថាពន្យល់សេចក្ដី ។



ដូច្នេះទើបឈប់ចូលកាន់សាសនាដទៃទៀតជារៀងរហូត ។

បុគ្គលមានសីលនិងមាននូវវត្តប្បដិបត្តិក្នុងព្រះពុទ្ធសាសនា ចំណុចខ្លះហាក់ដូចជាធ្វើខ្លួនឱ្យទុក្ខលំបាកឯងៗ ប៉ុន្តែតាមពិតនៅក្នុងព្រះពុទ្ធសាសនា មិនមែនយកសេចក្ដីទុក្ខលំបាកជាសីលឬជាវត្តប្បដិបត្តិនោះទេ សុខក៏បាន ទុក្ខក៏បាន សំខាន់ឱ្យតែអកុសលធម៌សាបសូន្យទៅ កុសលធម៌ចម្រើនឡើង ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧត្តិយៈ លំដាប់អំពីនោះទៅ អ្នកត្រូវអាស្រ័យសីល តម្កល់នៅក្នុងសីល ហើយចម្រើននូវសតិប្បដ្ឋាន ៤ ចុះ[១] ។ មានចំណុចខ្លះសីលនិងវត្តក៏ប្រព្រឹត្តទៅព្រមដោយសេចក្ដីលំបាកផ្លូវកាយផងដែរ ប៉ុន្តែនេះ ដូចជាអ្នកឈឺតមចំណីទាស់អ៊ីចឹង ព្រោះកាលបើរស់នៅដោយភាពសុខស្រួលក្នុងសេនាសនៈប្រណីតៗជាដើម ចិត្តរមែងរាយមាយ អកុសលធម៌រមែងចម្រើនឡើង ឯកុសលធម៌បែរទៅជាសាបសូន្យវិញ គឺគប្បីដោះស្រាយដោយការវៀរចាក ដូច្នេះការតមចំណីទាស់ ពិតជាមានប្រយោជន៍ណាស់ដល់ការរក្សាសុខភាព យ៉ាងណា សីលនិងវត្តក្នុងព្រះពុទ្ធសាសនា ទាក់ទងនឹងការរស់នៅ ការប្រើប្រាស់បច្ច័យ ៤ ការអាស្រ័យសេពគប់នឹងបុគ្គលជាដើម គឺប្រព្រឹត្តទៅ

១. បិដកលេខ ៣៨, ទំព័រ ៦៤ ។

ដើម្បីអកុសលធម៌សាបសូន្យទៅ កុសលធម៌ចម្រើនឡើង ចិត្តតាំងមាំមិនរាយមាយ ជាប្រយោជន៍យ៉ាងនោះឯង ទោះជាមានសេចក្តីទុក្ខលំបាកផ្លូវកាយខ្លះៗក៏ដោយ[១] ។

នៅក្នុងអដ្ឋកថាសល្លេខសូត្រ ពន្យល់សេចក្តីក្នុងព្រះសូត្រត្រង់បាទវិបស្សនាថា សមាបត្តិ ៨ របស់បុគ្គលក្រៅព្រះពុទ្ធសាសនា ត្រឹមតែជាបាទនៃវដ្តៈប៉ុណ្ណោះ ។ សេចក្តីនេះ សូមឱ្យពុទ្ធបរិស័ទគិតបន្តិចថា ហេតុអ្វីបានជាក្នុងព្រះពុទ្ធសាសនានេះ សមាបត្តិ ៨ ជាបាទនៃវិបស្សនា ។ គឺមិនមែនគ្រាន់តែបានស្តាប់ថា ខន្ធ ៥ មិនទៀង ជាទុក្ខ ជាអនត្តា មានការកើតរលត់ប៉ុណ្ណឹងនោះទេ តើខន្ធ ៥ នៅទីណា មិនទៀងហ្នឹង តើមិនទៀងយ៉ាងម៉េច កើតរលត់ដូចម្តេច ។ ដូច្នេះ ទាល់តែបុគ្គលមានប្រក្រតីអប់រំចម្រើនសតិប្បដ្ឋាន ទើបសមាបត្តិ ៨ នោះៗ បានជាបាទនៃវិបស្សនា ។ ទោះជាមិនមាននូវសមាបត្តិ ៨ ណាមួយ ក៏នៅតែមានបាទវិបស្សនាដែរ ជាពិសេសគឺបានស្តាប់យល់ថា អ្វីជាតួធម៌ពិតៗដែលធម៌ពិតនោះ ជាទីតាំងនៃសតិរលឹក ជាអារម្មណ៍នៃវិបស្សនា ។ មានសច្ចញ្ញាណកើតឡើងដឹងថា នេះជាធម៌ពិត ធម៌ពិតមានគ្រប់ព្រះអង្គគ្រប់គ្នា ដោយឥតគិតថាត្រូវធ្វើអ្វីទៀតទាំង-

១. គួរពិនិត្យក្នុងបិដកលេខ ២៦, ក្នុងទំព័រ ២៩ ចំណុចលេខ ១៤ និងទំព័រ ៣១ ចំណុច ១៥ ។



អស់ ព្រោះធម៌មានហើយតើ ។ អ្នកដែលបានយល់ដឹងធម៌ពិត គឺមានតែអ្នកបានស្តាប់ បានសិក្សាក្នុងព្រះពុទ្ធសាសនានេះប៉ុណ្ណោះ ព្រោះដូច្នេះហើយ ទើបអដ្ឋកថា សល្លេខសូត្រសម្តែងថា សូម្បីតែសរណគមន៍ក៏គប្បីជ្រាបថា ជាបាទនៃលោកុត្តរធម៌បានដែរ ។

ដែលព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចម្រើនសមាធិ ព្រោះភិក្ខុដែលមានចិត្តតម្កល់នឹងរមែងដឹងច្បាស់តាមសេចក្តីពិត ។ ព្រះអដ្ឋកថាប្រាប់ថា ព្រោះភិក្ខុទាំងនោះសាបសូន្យនូវសមាធិ ។ ព្រះអង្គត្រាស់ឱ្យភិក្ខុនោះៗមានសមាធិឡើងវិញ ដើម្បីបានជាឧបការៈក្នុងការដឹងច្បាស់នូវសច្ចធម៌។ ធម៌ដែលជាបាទ ជាបទដ្ឋាន ជាឧបការៈដល់វិបស្សនាមានច្រើនទៀតណាស់ មិនមែនមានតែផ្នែកសមាបត្តិ ៨ នោះទេ ទាំងដែលផ្នែកខ្លះមិនអាចអត់បានទៀតផង ដូចជាការត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធ និងការត្រាស់សម្តែងធម៌ឱ្យសត្វលោកកំណត់ដឹងនូវទុក្ខជាដើម ម្យ៉ាងទៀតចាំបាច់នៅត្រង់ឧបនិស្ស័យនៃបុណ្យមួយអង្គៗម្នាក់ៗ ដែលមិនអាចខ្វះបាន ។ តាមបុគ្គលជាក់ស្តែង អត់មានសមាបត្តិ ៨ ក៏អាចដឹងច្បាស់ចាក់ធ្លុះនូវសច្ចធម៌បានដែរ សឹងមានចំនួនច្រើនដ៏លើសលប់ទៀតផង ។

បើជាប្រក្រតីនៃជីវិតធម្មតា មិនមានសតិរលឹកដឹងតួធម៌ ឬ

តួធម៌ពិតៗមិនប្រាកដលក្ខណៈទេ តើសមាធិអ្វីទៅដែលអាចឱ្យចម្រើនវិបស្សនាបាន ? អាឡារតាបសបានសមាបត្តិ ៧ ឧទក-តាបសបានសមាបត្តិ៨ ម៉េចក៏មិនឃើញធម៌តាមពិតទៅ? ផ្ទុយមកវិញ សម្មាសមាធិជាមួយនឹងសម្មាសតិថ្នាក់សតិប្បដ្ឋាន វិបស្សនាក៏បានដំណើរការណ៍យ៉ាងល្អ សម្រេចអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ តាមឧបនិស្ស័យដែលមានគ្រប់គ្រាន់ ។

អ្វីៗមិនមែនចេះតែបានតាមចង់ទេ លុះត្រាតែមានហេតុត្រឹមត្រូវគ្រប់គ្រាន់ គិតមើលតែតំណែងព្រះអគ្គសាវ័ក អសីតិ-មហាសាវ័ក ឯតទគ្គបុគ្គល ។ល។ ប្រសិនបើយឺតនៅទេវលោកត្រឹមតែ ១ ថ្ងៃនៃទេវលោកនោះ ព្រះសម្មាសម្ពុទ្ធបរិនិព្វានចោលបាត់ ប៉ុន្តែនេះសុទ្ធតែបុណ្យបារមីរៀបចំមកឱ្យទាំងអស់ រួមផ្សំនឹងបុណ្យបច្ចុប្បន្នផង ។ ចំណែកពុទ្ធបរិស័ទយើងសម័យសព្វថ្ងៃ ក៏អាស្រ័យបុណ្យជាបច្ច័យមិនតូចឡើយ ដែលបានមកដល់ព្រះរតន-ត្រ័យនេះ ធំជាងការបានសមាបត្តិ ៨ អភិញ្ញា ៥ ក្រៅព្រះពុទ្ធ-សាសនាទៅទៀត ព្រោះមានបាទនៃលោកុត្តរធម៌។ បើពុទ្ធបរិស័ទបានដឹងធម៌ឥឡូវនេះ ដែលគ្រប់អង្គគ្រប់គ្នាកំពុងតែមានគ្រប់គ្រាន់មានស្រាប់ហើយ គ្រប់ពេលវេលាទាំងអស់ មិនមានអង្គណាអ្នកណាអត់ធម៌ទេ ដូច្នេះពុទ្ធបរិស័ទប្រាកដជាបានដឹងថា អ្នក



ត្រាស់ដឹងធម៌ ឃើញធម៌ទាំងអស់ ទាំងក្នុងអតីតកាល បច្ចុប្បន្ន-កាល និង អនាគតកាល គឺសុទ្ធតែបានដឹងធម៌ដូច្នេះឯង ។ ធម៌ដែលគ្រប់អង្គ គ្រប់គ្នាមាន គឺជាធម៌យ៉ាងសាមញ្ញធម្មតា ប៉ុន្តែធ្វើឱ្យពុទ្ធបរិស័ទដែលជាអ្នកឃើញធម៌នោះឯង លែងត្រូវការចង់បានធម៌អ្វីទៀតទាំងអស់ ព្រោះធម៌មានហើយ ទាំងដែលត្រូវលះបង់ទៀតផង ទើបសេចក្តីត្រូវការចង់បានធម៌ដទៃមិនមាន ។

សតិប្បដ្ឋាន ៤ កាយ វេទនា ចិត្ត ធម៌ គឺតួធម៌ដែលគ្រប់អង្គគ្រប់គ្នាកំពុងតែមាននេះឯង កាលដែលពុទ្ធបរិស័ទឃើញធម៌តាមពិត ប្រាកដជាមិនលើកយកសតិប្បដ្ឋានសូត្រ បព្វៈនេះ បព្វៈនោះ មកសង្ស័យនោះទេ ពីព្រោះធម៌ដែលគ្រប់អង្គ គ្រប់គ្នាកំពុងតែមាននេះ មិនមែនជាធម៌អ្វីដទៃក្រៅអំពីសតិប្បដ្ឋាន ៤ ឡើយ ។

សរុបសេចក្តីនៃបញ្ញាក្នុងព្រះពុទ្ធសាសនា ដែលជាបញ្ញាសម្រាប់ពុទ្ធបរិស័ទទូទៅអប់រំចម្រើន គឺបញ្ញាឃើញតួធម៌តាមសេចក្តីពិត ទាំងដែលជាបញ្ញាអាស្រ័យកុសលធម៌គ្រប់យ៉ាងតាមសមគួរជាបច្ច័យ ហៅថាវិបស្សនា ក៏បាន រហូតដល់មគ្គប្បញ្ញាជាលោកុត្តរ ។

# ៨. កំណត់ដឹងទុក្ខ ដើរតាមផ្លូវសុខ

ក្នុងបិដកលេខ ៣៧, ទំព័រ ១៤ ពីរបន្ទាត់ខាងក្រោម ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ... ព្រោះអ្នកទាំងឡាយ នៅប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់តថាគតនេះ ដើម្បីកំណត់ដឹងនូវទុក្ខពិត ។

ព្រះពុទ្ធសាសនា ណែនាំអប់រំឱ្យស្គាល់លោកនិងជីវិតតាមសេចក្ដីពិត ។ កាលដែលបានដឹង បានស្គាល់លោកនិងជីវិតតាមសេចក្ដីពិតហើយ ក៏រមែងរស់នៅជាសុខព្រោះប្រាសចាកនូវសេចក្ដីប្រកាន់ ទាំងដំណើរជីវិតក៏ប្រព្រឹត្តទៅក្នុងផ្លូវដ៏ប្រសើរទៀតផង ដូចនៅក្នុងបិដកលេខ ៣៧, ទំព័រ ១៥ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុះមគ្គដូចម្ដេច បដិបទាដូចម្ដេច ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវទុក្ខនោះ គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការហ្នឹងឯង ។

នៅក្នុងព្រះពុទ្ធសាសនា ពាក្យថាទុក្ខនេះ យើងឃើញនៅក្នុងពួកធម៌ត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ជាពិសេសនៅក្នុងគោលធម៌ដ៏សំខាន់ក្នុងព្រះពុទ្ធសាសនាគឺអរិយសច្ចធម៌ ៤ បានដល់



ទុក្ខសច្ច សមុទយសច្ច និរោធសច្ច និង មគ្គសច្ច ។ កាលណាបើមនុស្សទាំងឡាយបានអាន ឬបានស្ដាប់ឮនូវគោលធម៌ត្រៃលក្ខណ៍ និងអរិយសច្ច ៤ ហើយ ប៉ុន្តែមិនបានពិចារណាឱ្យជ្រៅ បែរទៅជាមានគំនិតយល់ខុសថា ព្រះពុទ្ធសាសនាមើលលោកនេះក្នុងផ្នែកអាក្រក់ ឱ្យឃើញថាជាទុក្ខអត់មានសុខឡើយ ។

តាមពិត ព្រះពុទ្ធសាសនាប្រដៅឱ្យយើងស្គាល់ទុក្ខ ប៉ុន្តែព្រះសម្មាសម្ពុទ្ធ ព្រះអង្គមិនបានប្រដៅឱ្យយើងកើតទុក្ខនោះទេ មានតែប្រដៅឱ្យយើងបដិបត្តិចេញពីសេចក្ដីទុក្ខ ពោលឱ្យខ្លីមកគឺកំណត់ដឹងទុក្ខ ដើរតាមផ្លូវសុខ ។

យើងមើលក្នុងបដិបទាជាទូទៅ ព្រះពុទ្ធសាសនាប្រកាសអំពីដំណើរជាសុខ ដែលដើរទៅរកសេចក្ដីសុខពិតប្រាកដ ផ្ទុយអំពីលទ្ធិសាសនាដទៃខ្លះ ដែលប្រកាសថា សេចក្ដីសុខទាល់តែដើរតាមផ្លូវធ្វើខ្លួនឱ្យទុក្ខលំបាកទើបបានដល់ ។

ព្រះពុទ្ធសាសនាសម្ដែងអំពីបដិបទាទៅរកសន្តិសុខ គឺការរួចផុតពីទុក្ខ តាមរយៈសទ្ធា សីល ការមិនក្ដៅក្រហាយស្ដាយក្រោយ បាមោជ្ជ បីតិ បស្សទ្ធិ សុខ សមាធិ និង យថាភូតញ្ញាណ-ទស្សនៈគឺឃើញលោកនេះនិងជីវិតនេះតាមសេចក្ដីពិត រហូតដល់អរិយមគ្គជាលោកុត្តរ ដែលជាការសម្រេចដល់ទីបំផុតទុក្ខ ។

ក្នុងអរិយសច្ច ៤ យ៉ាង ទុក្ខសច្ចព្រះអង្គត្រាស់ថា ត្រូវកំណត់ដឹង ប៉ុន្តែបដិបទានៃជីវិតមិនមែនទុក្ខសច្ចទេ គឺមគ្គសច្ចទេតើ ។ ដូច្នេះទើបយើងត្រូវយល់ព្រះពុទ្ធសាសនា កុំឱ្យច្រឡំពាក្យថាកំណត់ដឹងទុក្ខនិងពាក្យថាកើតទុក្ខ ពីព្រោះ បញ្ញាដែលកំណត់ដឹងទុក្ខ គឺជាបញ្ញាដែលលះបង់ហេតុនៃសេចក្ដីទុក្ខ មានត្រូវកើតទុក្ខអ្វីទៀត មានតែរលត់ទុក្ខប៉ុណ្ណោះ ។

ព្រះពុទ្ធសាសនា មិនបានប្រដៅឱ្យមើលលោកនេះនិងជីវិតនេះក្នុងផ្នែកអាក្រក់នោះទេ ប៉ុន្តែប្រដៅឱ្យមើលតាមសេចក្ដីពិតឱ្យមានជីវិតរស់នៅជាសុខជាមួយនឹងការពិត ពោលគឺមានជីវិតរស់នៅក្នុងបដិបទាដ៏បរិសុទ្ធ ។ គ្រប់ព្រះអរិយបុគ្គលទាំងអស់ដែលបានចូលកាន់ភូមិព្រះអរិយៈ សុទ្ធតែបានឃើញលោកនេះតាមសេចក្ដីពិត ។

នៅវត្តស្រុកស្រែមួយបានប្រារព្ធពិធីបុណ្យឆ្លងខ្លោងទ្វារនិងសមិទ្ធិនានាក្នុងវត្ត ដល់ពេលរសៀលត្រូវសម្ដែងធម៌ស្រាប់តែមានភ្លៀងយ៉ាងខ្លាំងព្រមដោយខ្យល់បោកបក់ រង់ចាំដល់ពេលអន់ភ្លៀងទើបបានសម្ដែងធម៌ ។ មានក្រដាសសំណួរមួយទទឹកភ្លៀងផង តែអាចនៅអានអក្សរបាន ជាសំណួររបស់ក្មេងប្រុសម្នាក់ដែលបានបញ្ជាក់ប្រាប់ថា ខ្លួនគេរស់នៅជាមួយនឹងម្ដាយបែកអំពីឪពុក តើ



ខ្ញុំត្រូវធ្វើដូចម្ដេចចំពោះអ្នកមានគុណទាំងពីរ ? អ្នកណាមានគុណជាងអ្នកណា ? ខ្ញុំចង់ឱ្យឪពុកម្ដាយខ្ញុំនៅជុំគ្នាណាស់ ខ្ញុំអត់ចង់ឱ្យគាត់បែកគ្នាទេ ... ។ នេះគឺជាសំបុត្រសំណួរមួយដែលធ្វើឱ្យចាស់ៗមួយចំនួនរំជួលចិត្តស្រក់ទឹកភ្នែក នឹកអាណិតកូនឬក៏នឹកស្រណោះខ្លួនឯងយ៉ាងម៉េចក៏មិនដឹងដែរ ។

